ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



- ប្រទេសថៃ និង ឆាកល្ខោនជម្លោះគ្រាប់មីននៅតាមព្រំដែន
- ប៊ូ ម៉េង គឺជាវិចិត្រករ និងជាអតីតអ្នកទោសដែលរួចរស់ជីវិតពីគុកទួលស្លែង បានទទួលមរណភាព

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ៣២០ ខែសីហា ឆ្នាំ២០២៦

# ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា



ផ្ទាំងគំនូរបង្ហាញពី ប៊ូ ម៉េង កំពុងគូររូប ប៉ុល ពត ក្រោមការឃ្លាំមើលពីកងសន្តិសុខមន្ទីរស-២១។ នៅក្នុងបន្ទប់ ប៊ូ ម៉េង គូរគំនូរ គឺមានក្រុមអ្នកទោសដែលជាជាងចម្លាក់ សិល្បករ និងជាងឈើ ហើយពេលនោះ ជាងចម្លាក់កំពុងឆ្លាក់រូប ប៉ុល ពត។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

## មាតិកា

### សំបុត្រ

◆ ប្រទេសថៃ និង ឆាកល្ខោនជម្លោះ ..................១
◆ ជញ្ជាំង៖ ការឈ្លានពានរបស់ទាហានថៃ.........២
◆ ប៊ូ ម៉េង គឺជាវិចិត្រករ និងជាអតីតអ្នកទោស......៤

### ផ្នែកឯកសារ

◆ ចំពោះ បងមុត គោរពស្នេហា ......................៨
◆ ធុច លីម ហ៊ិត៖ កងនេសាទភូមិភាគពាយ័ព្យ ...៩
◆ ផែនការសម្លាប់ប្រពន្ធរបស់ខ្មែរក្បត់ ...........១២

### ផ្នែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ

◆ ព្រះរាជបណ្ណាល័យ ហ្វូងម៉ែនៃមជ្ឈមណ្ឌលឯកសារកម្ពុជា បោះពុម្ពសៀវភៅថ្មីមានចំណងជើងថា .១៥
◆ ខ្សែជីវិតរបស់វីរកងទ័ព ថន ពិទិ ............. ១៩
◆ វីរកងទ័ព ខ្វាំ សុផល............................. ២២
◆ យិន សុធារី៖ ប្រជាជនភៀសសឹក............. ២៥
◆ ស្ត្រីមេម៉ាយ និងជាប្រជាជនភៀសសឹកថៃ..... ២៨
◆ ខ្មែរក្រហមឈប់ឱ្យខ្ញុំបង្រៀនសិស្ស ........... ៣១
◆ លួចបេះផ្លែនោនមកស្ងោរហូបដើម្បីរស់..... ៣៣
◆ រៀបការក្នុងរបបខ្មែរក្រហម .....................៣៥
◆ ខ្មែរក្រហមសម្លាប់ប្តីខ្ញុំ ព្រោះធ្លាប់ធ្វើជា........ ៣៧
◆ នួន មិន៖ ត្រូវគ្រាប់កាំភ្លើងតែមិនស្លាប់ ....... ៣៩
◆ ភៀសខ្លួនពីកម្ពុជាក្រោម មករស់នៅ........... ៤២
◆ ព្រះរាជបណ្ណាល័យ ហ្វូងម៉ែនៃមជ្ឈមណ្ឌលឯកសារកម្ពុជាបន្តផ្តល់របទេះរុញ......................... ៤៥

### ផ្នែកវេទិកាពិភាក្សាសាធារណៈ

◆ យើងទាំងអស់គ្នាកំពុងរស់នៅលើ «ចំណុចពណ៌ខៀវស្លេក» តែមួយ តើហេតុអ្វីបានជាយើង..... ៥០
◆ យុវនារីក្នុងស្រុកអន្លង់វែងទស្សនកិច្ចសិក្សាទៅកាន់សារមន្ទីរផ្ទះ តាម៉ុក ...............................៥៣
◆ សិស្សសាលាបឋមសិក្សា ប៊ុនរ៉ានី ហ៊ុនសែន កោះថ្ម មកទស្សនាពិព័រណ៍រូបថត និងសិក្សា..៥៥

### ផ្នែកស្រាវជ្រាវរកគ្រួសារ

◆ លោក ហែម បូរ៉ាវុធ ស្វែងរកសាច់ញាតិ...... ៥៩
◆ ជាតិនេះ ខ្ញុំបិះតែនឹងស្លាប់ចំនួន១៤លើក (ត) .. ៦១

**រក្សាសិទ្ធិ**
មជ្ឈមណ្ឌលឯកសារកម្ពុជា
អនុញ្ញាតឱ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ៣៧៥៣.មប្រក
ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨
រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា

**ស្នេរលេខនេះ ៖** ឆាំង យុ, សុភ័ក្ត្រ ភាណា, ធី គីមហុង, រីម ពេជ្រដារ៉ូ, មឿន ស្រីណុច, ថុន ស្រីពេជ្រ, ជីម សុខគា លី សុខឃាង, សិលា បញ្ញាវុធ, ស្រេង លីដា, ស៊ាង ចិន្តា, ព្រំ ដល្លា, មេក វិន, ឈុំ រ៉ា, ផេង ពង្សរ៉ាស៊ី និង សៀវ សុផុន
**អ្នកនិពន្ធ និងស្រាវជ្រាវ៖** មីន សាណាស់ **អ្នកបកប្រែ៖** លឹម អ៊ិភីង និង ជ័យ ចាន់ស៊ីណែត **និពន្ធនាយកទូទៅ៖** សោម ប៊ុនថន
**ជំនួយការនិពន្ធនាយក៖** ដារ៉ារដ្ឋ មេត្តា **ក្រាហ្វិកកុំព្យូទ័រ៖** លី សេនសូនី ឡា **គ្រប់គ្រងការចែកផ្សាយ៖** ឆេង វ៉េង
Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiasri.org

# ប្រទេសថៃ និង ឆាកល្ខោនជម្លោះ គ្រាប់មីននៅតាមព្រំដែន

ឆាំង យុ



*ទាហានថៃផ្ទោងគ្រាប់ចូលប្រាសាទព្រះវិហារ អំឡុងពេលឈ្លានពានទឹកដីកម្ពុជា ចន្លោះពីខែកក្កដា ដល់ខែធ្នូ ឆ្នាំ២០២៥។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

*ជាក់ស្តែង ទាហានថៃគួរតែមានការប្រុងប្រយ័ត្នខ្ពស់ជាងនេះចំពោះបញ្ហាគ្រាប់មីនដែលស្ថិតនៅក្នុងដែនដីរបស់ខ្លួន។ កត្តានេះហាក់ដូចជាចម្លែកនៅពេលដែលភាគីថៃអះអាងថា កម្ពុជាកំពុងដាក់គ្រាប់មីននៅលើទឹកដីថៃ ហើយសហគមន៍អន្តរជាតិហាក់ដូចជាស្តាប់ ឬមានទំនោរជឿលើការអះអាង រួមទាំងតំបន់ដែលធ្លាប់ស្ថិតក្រោមការកាន់កាប់របស់យោធាខ្មែរក្រហម ហើយទាហានថៃបានដាក់ពង្រាយកម្លាំងទាហានរបស់ខ្លួនយ៉ាងច្រើននៅក្នុងតំបន់នោះទៀតផង។ ក្នុងស្ថានភាពបែបនេះ ការដាក់គ្រាប់មីនថ្មីគួរតែជារឿងពិបាក ឬអាចនិយាយបានថាស្ទើរតែមិនអាចធ្វើទៅបាន។*

*សម្រាប់ទាហានថៃ បញ្ហានេះគ្រាន់តែជាការសម្តែងល្ខោននយោបាយ និងការធ្វើសមយុទ្ធយុទ្ធសាស្ត្រនយោបាយពោលគឺជាល្បែងនយោបាយមួយ។ ប៉ុន្តែសម្រាប់ប្រទេសកម្ពុជា នេះគឺជាការតស៊ូប្រដាប់អាវុធពិតប្រាកដ ដែលកំពុងបន្តអស្ថិរភាព និងឈានទៅជិតដល់ការគំរាមកំហែងដល់ការរស់រានមានជីវិត និងអនាគតរបស់ជាតិ។ ប្រទេសកម្ពុជាគួរតែចាត់ទុកបញ្ហានេះជាបញ្ហាប្រឈមដ៏សំខាន់មួយ សម្រាប់ជំរុញនូវការធ្វើទំនើបកម្ម និងការពង្រឹងសមត្ថភាពរបស់ខ្លួន។*

# ជញ្ជាំង៖ ការឈ្លានពានរបស់ទាហានថៃ

**ឆាំង យុ**



ទាហានថៃសាងសង់របងនៅតាមបណ្តោយព្រំដែនកម្ពុជា។ (ប្រភព៖ បាងកកប៉ុស្តិ៍)

ការសាងសង់ជញ្ជាំង គឺមានសារសំខាន់ប៉ុន្តែវាក៏អាចបង្កជាគ្រោះថ្នាក់បានដែរ។ ជញ្ជាំងផ្តល់នូវការការពារសន្តិសុខ និងខណ្ឌចែកមនុស្សជាពីរផ្នែកផ្សេងគ្នា នៅពេលមានមូលហេតុភាពស្របច្បាប់ និងចាំបាច់ដែលអាចធ្វើជាមូលដ្ឋានសមស្របសម្រាប់ការសាងសង់ជញ្ជាំង។ ជញ្ជាំងគឺមិនត្រឹមតែអាចសាងសង់ឡើងបានពីឥដ្ឋ លោហធាតុ ឬបេតុងតែប៉ុណ្ណោះទេ។ ការសាងសង់ជញ្ជាំងក៏អាចជាការគិតបែបអរូបី និងជាឧបករណ៍ផ្លូវចិត្តមួយដ៏មានអត្ថន័យ ដោយសារហេតុផលល្អៗទាំងអស់ខាងលើ។

ទោះបីជាការសាងសង់ជញ្ជាំងអាចបំពេញមុខងារស្របច្បាប់ និងបម្រើគោលបំណងចាំបាច់មួយចំនួនយ៉ាងណាក្តី ការសាងសង់ជញ្ជាំងអាចត្រូវបានប្រើប្រាស់ខុសគោលបំណង ឬភាន់ច្រឡំថាជាឧបករណ៍ក្លែងក្លាយបាំងមុខដើម្បីផ្តល់ភាពស្របច្បាប់ដល់គោលនយោបាយ និងសកម្មភាពទាំងឡាយណាដែលខុសច្បាប់ គ្មានការចាំបាច់ និងបង្កផលប៉ះពាល់។

ភាពខុសគ្នាយ៉ាងខ្លាំងរវាងប្រភេទជញ្ជាំងទាំងពីរនេះគឺសច្ចធម៌ស្ថិតស្ថេរជាអមតៈមួយដែលថា អំណាចក្នុងការសាងសង់ជញ្ជាំង មិនមែនមានន័យថា

ជញ្ជាំងនោះមានភាពស្របច្បាប់ ឬមានតម្រូវការចាំបាច់នោះឡើយ។ មូលដ្ឋានច្បាប់ ភាពស្របច្បាប់ និងតម្រូវការចាំបាច់ផ្នែកសីលធម៌ដែលជាក់ស្តែងត្រូវតែមានមុនដំណើរការនៃការសាងសង់ជញ្ជាំងជាមុន។ ចំណុចនេះគឺប្រទេសថៃកំពុងប្រព្រឹត្តកំហុស។ ការសាងសង់ជញ្ជាំងព្រំដែនរបស់ទាហានថៃមិនត្រូវបានទទួលស្គាល់ថាស្របតាមច្បាប់អន្តរជាតិនោះទេ ហើយការសាងសង់នេះគ្មានភាពស្របច្បាប់នៅក្នុងចំណោមប្រជាជនដែលត្រូវបានគេខណ្ឌដោយជញ្ជាំងនេះដែរ។ ជាក់ស្តែងការសាងសង់ជញ្ជាំងនេះគឺគ្រាន់តែសម្រាប់បម្រើឱ្យផលប្រយោជន៍រយៈពេលខ្លីរបស់ក្រុមឥស្សរជនថៃ ដែលបានកេងចំណេញពីភាពតានតឹងជាមួយប្រទេសកម្ពុជា ដើម្បីសម្រេចរបៀបវារៈនយោបាយរបស់ខ្លួនតែប៉ុណ្ណោះ។

ទាហានថៃអាចសាងសង់ជញ្ជាំងនេះបាន ប៉ុន្តែប្រវត្តិសាស្ត្របានបង្ហាញឱ្យឃើញហើយថា ជញ្ជាំងទាំងឡាយណាដែលខ្វះមូលដ្ឋានច្បាប់ ភាពស្របច្បាប់ និងតម្រូវការចាំបាច់ផ្នែកសីលធម៌ ឬការអនុវត្តជាក់ស្តែង នៅទីបំផុតនឹងដួលរលំ និងបរាជ័យជាក់ជាមិនខាន។



ទាហានថៃសាងសង់របងនៅតាមបណ្តោយព្រំដែនកម្ពុជា។ (រូបថត៖ កាសែតបាងកកប៉ុស្តិ៍)

# ប៊ូ ម៉េង គឺជាវិចិត្រករ និងជាអតីតអ្នកទោស ដែលរួចរស់ជីវិតពីគុកទួលស្លែង បានទទួលមរណភាព

**សោម ប៊ុនថន**



ប៊ូ ម៉េង កំពុងគូរគំនូរនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងឆ្នាំ២០០៨។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ប៊ូ ម៉េង គឺជាវិចិត្រករ និងជាអតីតអ្នកទោសដែលរួចរស់ជីវិតពីការសួរចម្លើយ ការធ្វើទារុណកម្ម និងសម្លាប់នៅមន្ទីរសន្តិសុខស-២១ ឬ គុកទួលស្លែង បានទទួលមរណភាពក្នុងអាយុ៨៥ឆ្នាំ ដោយសារជំងឺដាច់សរសៃឈាមខួរក្បាល កាលពីថ្ងៃសុក្រ ទី១៨ ខែសីហា ឆ្នាំ២០២៦ នៅផ្ទះរបស់គាត់ស្ថិតនៅក្នុងភូមិធម្មត្រ័យ ឃុំផ្សារដែក ស្រុកពញាឮ ខេត្តកណ្ដាល ប្រទេសកម្ពុជា។

ប៊ូ ម៉េង មានឈ្មោះដើម ប៊ូ ម៉ុងសៀង កើតនៅថ្ងៃទី៤ ខែមេសា ឆ្នាំ ១៩៤១ ក្នុងគ្រួសារកសិករនៅខេត្តកំពង់ចាម។ នៅអាយុ៥ឆ្នាំ ប៊ូ ម៉ុងសៀង ត្រូវបានបញ្ជូនឱ្យទៅរស់នៅក្នុងវត្តអារាមព្រះពុទ្ធសាសនា។ ម៉ុងសៀងបានរៀនគូររូបដោយខ្លួនឯង ហើយក្រោយមកបានធ្វើជាអ្នកគូរផ្ទាំងរូបភាពផ្សាយពាណិជ្ជកម្មសម្រាប់រោងភាពយន្ត។ នៅក្នុងឆ្នាំ១៩៦៥ ប៊ូ ម៉ុងសៀង បានរៀបការជាមួយប្រពន្ធឈ្មោះ ម៉ា យឿន។ នៅឆ្នាំ១៩៧០ គាត់បានប្ដូរឈ្មោះពី ប៊ូ ម៉ុងសៀង មក ប៊ូ ម៉េង វិញ ខណៈពេលគាត់ រួមជាមួយប្រពន្ធចូលបម្រើបដិវត្តន៍ខ្មែរក្រហមតាមរយៈជនជាតិខ្មែរដើមកំណើតវៀតណាមម្នាក់។ អ្នកទាំងពីរបានចូលរួមជាមួយចលនាបដិវត្តន៍ខ្មែរក្រហម ដោយសារតែការទម្លាក់គ្រាប់របស់អាមេរិកលើប្រទេសកម្ពុជា និងការឃោសនាអំពាវនាវឱ្យប្រជាជនគាំទ្រសម្ដេចព្រះ នរោត្តម សីហនុ ដែលត្រូវបានទម្លាក់ចេញពីអំណាចនៅក្នុងរដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ដឹកនាំដោយ លន់ នល់។

ប៊ូ ម៉េង និងប្រពន្ធបានបម្រើការនៅក្នុងអង្គភាពភ័ស្តុភារសេនាធិការភូមិភាគឧត្តរ ស្ថិតក្រោមការគ្រប់គ្រងរបស់ ឆុន។

នៅពេលកងទ័ពបដិវត្តន៍ខ្មែរក្រហម ទទួលជ័យជម្នះលើរបប លន់ នល់ ឆ្នាំ១៩៧៥ ប៊ូ ម៉េង និងប្រពន្ធត្រូវបានបញ្ជូនចូលទៅក្នុងទីក្រុងភ្នំពេញ។ ប៊ូ ម៉េង បម្រើការនៅផ្នែកភ័ស្តុភារសេនាធិការភាគឧត្តរ ដែលមានទីតាំងនៅខាងជើងស្ពានជ្រោយចង្វារ ក្នុងទីក្រុងភ្នំពេញ។ អំឡុងពេលនោះ ប៊ូ ម៉េង ធ្លាប់បានទៅគូរគំនូរអំពីគ្រឿងម៉ាស៊ីនសម្រាប់បង្រៀនដល់កម្មាភិបាល នៅសាលាបច្ចេកទេសឫស្សីកែវ។

នៅក្នុងខែមិថុនា ឆ្នាំ១៩៧៧ ប៊ូ ម៉េង និងប្រពន្ធឈ្មោះ ម៉ា យឿន ត្រូវបានអង្គការចាប់ខ្លួនពីការដ្ឋានលត់ដែកថ្មី ស្ថិតនៅប៉ែកខាងត្បូងឆៀងខាងលិចទីក្រុងភ្នំពេញបញ្ជូនមកមន្ទីរសន្តិសុខស-២១។ ប៊ូ ម៉េង បានស្តាប់ឮសំឡេងប្រពន្ធរបស់គាត់អង្វរសន្តិសុខដើម្បីទុកជីវិត ខណៈដែលគាត់ត្រូវបានចងបិទភ្នែកដោយក្រណាត់។ នៅពេលនោះ មានមនុស្សជាច្រើនត្រូវបានសន្តិសុខចាប់ខ្លួនដែរ ហើយ ប៊ូ ម៉េង មិនដឹងថាមានដើមហេតុអ្វីដែលនាំឱ្យកងសន្តិសុខចាប់ខ្លួនគាត់ទេ។ ប្រពន្ធរបស់ ប៊ូ ម៉េង ឈ្មោះ ម៉ា យឿន ត្រូវកងសន្តិសុខយកទៅឃុំឃាំងនៅបន្ទប់ផ្សេងពីគាត់។ ប៊ូ ម៉េង និងប្រពន្ធត្រូវចាប់ខ្លួនខណៈពេលដែលខ្មែរក្រហមកំពុងបោសសម្អាត«ខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង» នៅភូមិភាគឧត្តរ ដែលមាន កុយ ធួន គឺលេខាភូមិភាគ និងជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មត្រូវបានចាប់ខ្លួនរួចទៅហើយ។ ចាប់តាំងពីពេលនោះមកប៊ូ ម៉េង ត្រូវបែកពីប្រពន្ធនិងកូនប្រុសស្រីពីរនាក់របស់គាត់។ ប្រពន្ធរបស់ប៊ូ ម៉េង ត្រូវកងសន្តិសុខយកទៅសម្លាប់នៅវាលពិឃាតបឹងជើងឯកចំណែកកូនទាំងពីររបស់គាត់មិនដែលបានទទួលដំណឹងឡើយ។

បន្ទាប់ពីថតរូប និងធ្វើប្រវត្តិរូបសង្ខេបរួចហើយ កងការពារអ្នកទោសបានបញ្ជូន ប៊ូ ម៉េង ទៅដាក់នៅក្នុងអគារ «គ» ជាន់ទី២ រួមជាមួយអ្នកទោសប្រមាណ៣០នាក់ផ្សេងទៀត។ ប៊ូ ម៉េង ត្រូវបាននាំយកទៅសួរចម្លើយនៅក្នុងផ្ទះល្វែងមួយដែលស្ថិតនៅខាងមុខបរិវេណនៃអគារមន្ទីរសន្តិសុខស-២១ អស់រយៈពេលប្រមាណពីរសប្តាហ៍។ នៅពេលនោះមានអ្នកសួរចម្លើយបួននាក់ ប៉ុន្តែនៅក្នុងចំណោមនោះ ប៊ូ ម៉េង នៅចងចាំមនុស្សម្នាក់គឺឈ្មោះ ហ៊ ដែលជាអនុប្រធានមន្ទីរស-២១។ អ្នកសួរចម្លើយបានសួរគាត់ថា ឯងបានចូលសេ-អ៊ី-អា, កា-ហ្សេ-បេ ជាមួយអ្នកណា? នៅឆ្នាំណា? ប៊ូ ម៉េង បានឆ្លើយតបវិញថា «ខ្ញុំមិនដឹងថា សេ-អ៊ី-អា កា-ហ្សេ-បេ ជាអ្វីទេ»។ ដោយសារតែ ប៊ូ ម៉េង នៅតែឆ្លើយរបៀបនេះច្រើនលើកច្រើនសា អ្នកសួរចម្លើយបានទះកំផ្លៀង និងវាយធ្វើទារុណកម្មគាត់ នឹងបន្ទះរនាបឫស្សីរហូតហូរឈាមពេញខ្នង និងសន្លប់។ នៅពេលដែល ប៊ូ ម៉េង មានរបួស អ្នកសួរចម្លើយបានបញ្ជូនគាត់ទៅផ្នែកពេទ្យក្នុងមន្ទីរសន្តិសុខស-២១។ ពេទ្យបានព្យាបាលរបួសលើខ្នងរបស់គាត់ដោយលាងសម្អាតជាមួយទឹកអំបិល។

បន្ទាប់ពីព្យាបាលរបួសរួចហើយ ឆ្មាំគុកបានយក ប៊ូ ម៉េង ទៅសួរចម្លើយបន្តទៀត។ ប៊ូ ម៉េង បានរៀបរាប់ថា អ្នកសួរចម្លើយនៅតែសួរគាត់នូវសំណួរដដែល ហើយគាត់នៅតែឆ្លើយចម្លើយដដែលៗ។

ប៊ូ ម៉េង បន្តថា សន្តិសុខតែងតែធ្វើទារុណកម្មជាច្រើនប្រភេទទៅលើអ្នកទោស។ អ្នកទោសត្រូវបានដាក់ឃ្នាងទាំងខ្សែៗ ហើយអ្នកទោសប្រុស និងអ្នកទោសស្រីត្រូវបានឃុំឃាំងនៅក្នុងបន្ទប់ដោយឡែកពីគ្នា។ ប៊ូ ម៉េង ធ្លាប់បានឃើញឆ្មាំគុកម្នាក់ឡើងទន្ទ្រាំលើទ្រូងអ្នកទោសប្រុសម្នាក់នៅក្នុងបន្ទប់ជាមួយគាត់ រហូតដល់អ្នកទោសនោះស្លាប់។

ដោយសារតែមិនមានចម្លើយគ្រប់គ្រាន់សម្រាប់រាយការណ៍ទៅប្រធានមន្ទីរសន្តិសុខស-២១ អ្នកសួរចម្លើយបានសម្លុត ប៊ូ ម៉េង ថា «អង្គការភ្នែកម្នាស់មិនដែលចាប់អ្នកណាខុសទេ។ ឯងជាជាងគំនូរ ឯងច្បាស់ជាមានទាក់ទងជាមួយខ្សែ សេ-អ៊ី-អា របស់អាមេរិកាំងហើយ។ ឥឡូវឯងឆ្លើយតាមអញប្រាប់»។ ប៊ូ ម៉េង មិនបានចាំថាចម្លើយសារភាពរបស់គាត់មានចំនួនប៉ុន្មានទំព័រទេ ប៉ុន្តែគាត់និយាយថា ចម្លើយទាំងអស់នោះសុទ្ធតែប្រឌិតឡើងដោយអ្នកសួរចម្លើយទាំងស្រុង។ ដោយសារការធ្វើទារុណកម្មនៅមន្ទីរស-២១ ធ្វើឱ្យត្រចៀកម្ខាងរបស់ ប៊ូ ម៉េង ថ្លង់ និង

បន្សល់ទុកនូវស្លាកស្នាមរបួសជាច្រើនកន្លែងនៅលើខ្លួនរបស់គាត់។ ស្ថិតនៅក្រោមការធ្វើទារុណកម្មធ្ងន់ធ្ងរ ទីបំផុត ប៊ូ ម៉េង បានឆ្លើយសារភាពដោយមិនពិតថាគាត់គឺជាភ្នាក់ងាររបស់ សេ-អ៊ី-អា។ ដូចជាអ្នកទោសដទៃទៀតដែរ គាត់បានប្រាប់ឈ្មោះមនុស្សដែលគាត់បានប្រឌិតឡើងថាជាបណ្តាញចារកម្ម ហើយឈ្មោះទាំងនោះជួនកាលបានបណ្តាលឱ្យមានការចាប់ខ្លួនជាបន្តបន្ទាប់ទៀត។

បន្ទាប់ពីផ្អាកការសួរចម្លើយ ប៊ូ ម៉េង ប្រមាណមួយខែ ឆ្មាំគុកបានប្រកាសរកអ្នកចេះគូរគំនូរដើម្បីគូររូប ប៉ុល ពត។ ប៊ូ ម៉េង បានស្ម័គ្រចិត្ត ហើយឆ្មាំគុកបាននាំ ប៊ូ ម៉េង ទៅជួប កាំង ហ្កេចអ៊ាវ ហៅ ឌុច ប្រធានមន្ទីរសន្តិសុខស-២១។ ឌុច បានសម្លុត ប៊ូ ម៉េង ថា«បើគូររូបមិនដូចទេ នឹងយកអ្ហែងទៅវាយចោល»។ អំឡុងពេលដែល ប៊ូ ម៉េង ជាប់ឃុំនៅក្នុងមន្ទីរសន្តិសុខស-២១ គាត់គូររូប ប៉ុល ពត បានចំនួនបួនផ្ទាំង។ ដោយសារតែមានជំនាញគូរគំនូរ ទើបធ្វើឱ្យការរស់នៅរបស់ ប៊ូ ម៉េង បានប្រសើរជាងមុន និងគ្រាន់បើជាងអ្នកទោសដទៃទៀត។



ប៊ូ ម៉េង (រូបខាងឆ្វេង) កំពុងគូរគំនូរ និងលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងឆ្នាំ២០០៤។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ប៊ូ ម៉េង បានរំឭកថា «នៅក្នុងគុក ខ្ញុំបានឮសំឡេងមនុស្សយំ» និងស្រែកថា «ម៉ែជួយកូនផង ម៉ែជួយកូនផង!»។

នៅក្នុងបញ្ជីឈ្មោះអ្នកទោសចំនួន២៤នាក់នៃមន្ទីរស-២១ ធ្វើនៅថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៧៨ ដែលមានចំណងជើងថា«អ្នកទោសដែលនៅប្រើការបាន» នៅត្រង់លេខរៀងទី១២ បានសរសេរថា «ប៊ូ ម៉េង អាយុ៣៧ឆ្នាំ មកពីអគ្គភាពឧស្សាហកម្មរដ្ឋ មានតួនាទីជាយុទ្ធជនសាលាបច្ចេកទេសឫស្សីកែវ ជាជាងគំនូរ ចូលឆ្នាំ១៩៧៧»។ នៅក្នុងឯកសារដដែលនេះមានឈ្មោះអតីតអ្នកទោសនៃមន្ទីរស-២១ ដែលនៅរស់រានមានជីវិតនៅក្រោយឆ្នាំ១៩៧៩ ដូចជា៖ វ៉ុយ ណាគង់ ជាងឈើ, ហេង ណាត ជាងឆ្លាក់, អៀម ចាន់ ជាងឆ្លាក់, អ៊ីង ប៉ិច ជាងជួសជុលរថយន្ត។ ចំណែកឯ ជុំ ម៉ាញ ហៅ ម៉ី អតីតអ្នកទោសម្នាក់ទៀតដែលនៅរស់រានមានជីវិតពីមន្ទីរស-២១ ដែរនោះ មិនត្រូវបានកត់ត្រាចូលក្នុងបញ្ជីនេះទេ ប៉ុន្តែបានកត់ត្រានៅក្នុងបញ្ជីដោយឡែកមួយទៀត មានចំណងជើងថា «អ្នកទោសមកពីក្រសួងកាត់ដេររដ្ឋ»។ នៅផ្នែកខាងមុខឈ្មោះ ជុំ ម៉ាញ់ ហៅ ម៉ី មានចំណាររបស់គណៈមន្ទីរស-២១ ចារថា«ទុកសិន»។

ចាប់តាំងពីចាកចេញពីមន្ទីរសន្តិសុខស-២១ ប៊ូ ម៉េង មិនដែលត្រឡប់មកកន្លែងជូរចត់នេះទេ ព្រោះធ្វើឱ្យគាត់មានការរន្ធត់ និងនឹកឃើញដល់រឿងរ៉ាវដែលបានកន្លងផុតទៅ ហាក់ដូចជានៅថ្មី។

ប៊ូ ម៉េង បានបន្តចិញ្ចឹមជីវិតដោយការគូរផ្ទាំងគំនូរនៅលើជញ្ជាំងទាក់ទងពុទ្ធប្រវត្តិ និងសាសនានៅតាមព្រះវិហារ និងវត្តអារាម។

ប៊ូ ម៉េង បានរៀនសូត្រផ្នែកគំនូរក្រោយវិចិត្រករ ញឹក ឌឹម មួយជំនាន់ ហើយគាត់តែងតែសង្កេតមើលគំនូររបស់វិចិត្រករបរទេសម្នាក់ឈ្មោះ ពីកាសូ។ ប៊ូ ម៉េង អាចគូររូបភាពបានគ្រប់ប្រភេទ ហើយគំនូរដែលគាត់ស្រឡាញ់បំផុតគឺរូបផ្កា និងរូបស្ត្រី។ ប៊ូ ម៉េង មានចំណេះផ្នែកគូរគំនូរ។ ចាប់តាំងពីដឹងក្តីមក ម៉េង មាននិស្ស័យខាងគូររូបភាព ហើយរហូតដល់ធំឡើង

គាត់នៅតែប្រកបរបរគូររូបភាពនៅតាមវត្តអារាមជាច្រើនដើម្បីផ្គត់ផ្គង់ជីវភាព។

នៅថ្ងៃទី២២ ខែមករា ឆ្នាំ២០០៣ ប៊ូ ម៉េង បានធ្វើដំណើរមកកាន់សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែងម្តងទៀតដើម្បីបង្ហាញដល់ប្រជាជនកម្ពុជា និងពិភពលោកអំពីការធ្វើទារុណកម្មដ៏សាហាវឃោរឃៅរបស់ខ្មែរក្រហមមកលើរូបគាត់។ អ្វីដែលគាត់សម្រេចចិត្តមកបំភ្លឺនៅពេលនោះ គឺដោយសារតែអត្ថបទមួយរបស់ទស្សនាវដ្តី«ស្វែងរកការពិត» នៃមជ្ឈមណ្ឌលឯកសារកម្ពុជា លេខ២២ ខែតុលា ឆ្នាំ២០០២ បានចុះផ្សាយអំពីរូបថតរបស់គាត់ដែលបានថតរួមជាអតីតអ្នកទោស៦នាក់ទៀត។

ប៊ូ ម៉េង បានទទួលទស្សនាវដ្តីស្វែងរកការពិតដែលមានចុះផ្សាយអំពីរឿងរ៉ាវរបស់គាត់ តាមរយៈព្រះចៅអធិការវត្តសម្ពៅ នៅក្នុងខេត្តស្វាយរៀង។ ប៊ូ ម៉េង បាននិយាយនៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែងថា «ខ្ញុំមិនទាន់ស្លាប់ទេ។ ខ្ញុំគឺជាជនរងគ្រោះនៅទីនេះ។ ខ្ញុំចង់ឃើញតុលាការកាត់ទោសមេខ្មែរក្រហម ហើយខ្ញុំនឹងធ្វើជាសាក្សី»។ ប៊ូ ម៉េង បានវិលត្រឡប់មកគុកទួលស្លែងវិញ បន្ទាប់ពីមន្ទីរឃុំឃាំងនេះត្រូវបានប្រែក្លាយទៅជាសារមន្ទីរ ហើយពេលនោះ ប៊ូ ម៉េង រកឃើញរូបគំនូរបញ្ឈររបស់ប៉ុល ពត មួយផ្ទាំងដែលគូរមិនទាន់រួច ដែលគាត់ធ្លាប់បានបោះបង់ចោលនៅក្នុងគំនរឧបករណ៍ធ្វើទារុណកម្មមាន ខ្សែតី រំពាត់ និងច្រវាក់។

នៅក្នុងឆ្នាំ២០០៩ ប៊ូ ម៉េង បានចូលធ្វើជាសាក្សីនៅក្នុងសំណុំរឿងការកាត់ទោសប្រធានមន្ទីរសន្តិសុខ ស-២១ គឺ កាំង ហ្គេចអ៊ាវ ហៅ ឌុច ដែលត្រូវបានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាកាត់ទោសឱ្យជាប់ពន្ធនាគារអស់មួយជីវិតពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ដែលបណ្តាលឱ្យមានមនុស្សប្រមាណ១៤,០០០នាក់ស្លាប់ ដោយសារការចោទប្រកាន់ ការចាប់ខ្លួន ការសួរចម្លើយ ការធ្វើទារុណកម្ម និងការបញ្ជូនទៅសម្លាប់យ៉ាងឃោរឃៅនៅវាលពិឃាតជើងឯក។

ប៊ូ ម៉េង បានវិលត្រឡប់មកសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង ឬអតីតមន្ទីរសន្តិសុខស-២១ ហើយបានប្រាប់រឿងរ៉ាវនៅក្នុងរបបខ្មែរក្រហមទៅកាន់អ្នកមកទស្សនា តាមរយៈសៀវភៅរបស់គាត់ដែលមានចំណងជើង «ប៊ូ ម៉េង៖ អ្នករស់រានមានជីវិតពីមន្ទីរឃុំឃាំង ស-២១ សរសេរដោយ ហ៊ុយ វណ្ណៈ កែសម្រួលដោយ សិត ម៉ៃដែន គឺជាអ្នកកាសែតដ៏ល្បីនៅញូវយ៉កថាម និងបោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងឆ្នាំ ២០១០។

បន្ទាប់ពី ប៊ូ ម៉េង បានទទួលមរណភាពទៅ នៅក្នុងចំណោមអតីតអ្នកទោសរួចជីវិតពីមន្ទីរ ស-២១ ទាំង៧ នាក់ គឺនៅសល់តែ ជុំ ម៉ី ម្នាក់តែប៉ុណ្ណោះដែលនៅរស់រានមានជីវិតក្នុងពេលបច្ចុប្បន្ន។



រូបគំនូរ ប៊ូ ម៉េង និងប្រពន្ធឈ្មោះ ម៉ា យឿន ត្រូវកងសន្តិសុខចងបិទមុខ រួចបញ្ជូនមកមន្ទីរសន្តិសុខ-២១ នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ១៩៧៧។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



រូបគំនូរ ប៊ូ ម៉េង និងប្រពន្ធឈ្មោះ ម៉ា យឿន នៅពេលកងសន្តិសុខមន្ទីរ ស-២១ នាំមកថតរូប មុននឹងបញ្ជូនទៅសួរចម្លើយ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ទូរលេខ១០៤
៤២៩

# ចំពោះ បងមុត គោរពស្នេហា

ដកស្រង់ចេញពីឯកសារ D០១៩០៦ ដោយ សោម ប៊ុនថន

**ចំពោះសភាពការណ៍**

១- ចំពោះសភាពការណ៍ខាងជុំវិញផ្នែកគោកក្នុងរយៈប៉ុន្មានថ្ងៃនេះមិនមានបញ្ហាអីទេ ឯផ្នែកប្រព័ន្ធកោះ ទាំងកោះកុង កោះវៃចាស់-ថ្មី និង កោះសេះ តែពេលយប់ថ្ងៃ២.១១ សភាពការណ៍ផ្នែកនៅខាងកើតកោះវៃថ្មី យើងឃើញមានកប៉ាល់មួយគ្រឿង តែទៅធ្វើការមិនឃើញមានទេ វាត្រឡប់ទៅវិញបាត់ៗ

២- ចាប់ពីថ្ងៃ ៦.១១.៧៧ រហូតថ្ងៃ ៨.១១.៧៧ សុំយោបល់បងធ្វើការ ហ៊ឹកហាត់ទៅសមុទ្រ ចែកជា២ផ្នែក៖

១) ហាត់ធ្វើនាវាចរណ៍តាមសមុទ្រ

២) ហ៊ឹកហាត់ដាក់ស្តែង ដោយបាញ់គ្រាប់ក្រៅកាណុងសមរភូមិ ហ៊ឹកហាត់ៗ

ទិសឥសាន ម.៩០

៣- សភាពការណ៍ស្រូវស្រែឥឡូវនេះ យើងកំពុងតែប្រូតស្រូវប្រែតទៅទៀត ព្រោះស្រូវមានការទុំបន្តគ្នាជាប់ ខាងជើងថ្នល់ ក៏ដូចខាងត្បូងថ្នល់ ផ្នែកបញ្ហាវាំងស្ងួត យើងកំពុងតែម៉ានវិធានការ និងបាចស្រែណាដែលមានភាពស្ងួត ឯក្រៅពីនេះចំពោះទឹកមិនមានបញ្ហាអីបោទធ្ងន់ប៉ុន្មានទេៗ



ថ្ងៃ៥.១១
រឿន
ទទួលថ្ងៃ៥.១១.៧៧
ម៉ោង ១៥ ៣០នាទី

រូបពាក់មួកនៅខាងស្តាំ និងចាប់ដៃ៖ អៀង សារី ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដឹកនាំគណៈប្រតិភូចុះត្រួតពិនិត្យកងទ័ពជើងទឹកៗ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ធុច លីមហ៊ត ៖ កងនេសាទ ភូមិភាគពាយ័ព្យ

**មីន សាណាស់**



*ទូកនេសាទនៅកំពង់ផែកំពង់សោម ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ អំឡុងឆ្នាំ១៩៧៨។*
*(ហ្គុនណា បឺយស្រ្តម/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

ធុច លីមហ៊ត ភេទប្រុស អាយុ២៥ឆ្នាំ (ក្នុងឆ្នាំ១៩៧៧) កើតនៅភូមិរំដួល ឃុំស្វាយជ្រោំ ស្រុកសង្កែ តំបន់៤។ ឪពុកម្តាយរបស់ លីមហ៊ត គឺជាឈ្មួញទិញអង្ករយកទៅលក់នៅតាមតំបន់ទន្លេសាប។ នៅពេលមានអាយុ៩ឆ្នាំ លីមហ៊ត ត្រូវឪពុកម្តាយបញ្ជូនឱ្យចូលរៀននៅសាលាបឋមសិក្សាអ៊ុត្តសាលា។ ពេលឡើងដល់ថ្នាក់ទី៧ (សង្គមចាស់) គាត់បានបន្តការសិក្សានៅវិទ្យាល័យបាត់ដំបង ហើយនៅថ្នាក់ទី៦គាត់ប្តូរមករៀននៅវិទ្យាល័យអ៊ិាបឃុតរយៈពេលមួយឆ្នាំ ទើបផ្លាស់ទៅខាងវិទ្យាល័យបាត់ដំបងវិញ។ នៅឆ្នាំ១៩៧០ពេល លីមហ៊ត រៀនដល់ថ្នាក់ទី៥ គាត់បានចូលធ្វើជាកុម្ម៉ង់ដូវិទ្យាល័យបាត់ដំបងដែលមានឈ្មោះ កាន់ថា គឺជាមេក្រុមកុម្ម៉ង់ដូ។ កាន់ថា បានអប់រំ លីមហ៊តឱ្យស្អប់លទ្ធិកុម្មុយនីស្ត និងស្រឡាញ់របបសេរី។

នៅឆ្នាំ១៩៧១ លីមហ៊ត បានចូលក្នុងកម្លាំងសេ-អ៊ី-អា តាមរយៈឈ្មោះ កាន់ថា និង ឈ្មោះ គួចខៀម សាស្រ្តាចារ្យប្រចាំវិទ្យាល័យបាត់ដំបង និងបច្ចុប្បន្នជាប្រជាជននៅភូមិក្តាំងផា ឃុំខ្ពប ស្រុកខ្ពប តំបន់៤។ ពិធីស្បថចូលក្នុង សេ-អ៊ី-អា ស្ថិតនៅទីតាំងការិយាល័យរបស់ គួច ខៀម និងជាអ្នកទទួលស្គាល់សមាសភាពថ្មីៗ បន្ទាប់ពីចូលរួម គួច ខៀមបានប្រគល់ភារកិច្ចដូចជា៖ ១) ឃោសនាប្រឆាំងនឹងខ្មែរក្រហម។ ២) ស៊ើបការណ៍ និង តាមដានចលនាបដិវត្តន៍ និង ៣) ពង្រីកកម្លាំងសេ-អ៊ី-អា បន្ត។ ក្រោយពីចូលជា

កម្លាំង សេ-អ៊ី-អា នៅចុងឆ្នាំ១៩៧១ លឹម ហ៊ិត បានទៅទាក់ទងខ្សែរយៈរបស់ គួច ខៀម ដែលមានឈ្មោះដូចជា៖ កែប សុផុះ សិស្សថ្នាក់ទីបញ្ចប់បច្ចុប្បន្នចាប់ខ្លួន។ ដោក សុភ័ណ សិស្សឆ្នាំទី២ នៃមហាវិទ្យាល័យគ្រឿងយន្តបាត់ដំបង បច្ចុប្បន្នក្ដាប់មិនបាន។ ពេជ ឆៃយ៉ា ប្រធានសិស្សបាត់ដំបង បច្ចុប្បន្នក្ដាប់មិនបាន។ ឃួន ចំរើន សិស្សថ្នាក់ទីបញ្ចប់ បច្ចុប្បន្នយុទ្ធជនកងចល័តស្រុក៨៣តំបន់៤ និង ព្រុំ សល់ សិស្សថ្នាក់ទីបញ្ចប់ បច្ចុប្បន្នប្រជាជននៅភូមិក្ដាំងផា ឃុំខ្ពប ស្រុកសង្កែតំបន់៤។ ការដែលទាក់ទងកម្លាំងខាងលើគឺដើម្បីធ្វើសកម្មភាពឃោសនាក្នុងចំណោមសិស្សវិទ្យាល័យបាត់ដំបងឱ្យស្អប់របបខ្មែរក្រហម ថាជាចលនាកាប់សម្លាប់ប្រជាជន និងជាបក្សកុម្មុយនីស្ត។

នៅឆ្នាំ១៩៧២ កាន់ថា បានណែនាំខ្សែរយៈមួយចំនួនទៀតដល់ លឹម ហ៊ិត ដើម្បីឱ្យធ្វើការទាក់ទងមានដូចជា ចាន់ថា សិស្សថ្នាក់ទី១។ ងីដឹង សិស្សថ្នាក់ទីបញ្ចប់ បច្ចុប្បន្នប្រជាជននៅភូមិព្រៃទទឹង ស្រុកដូនទាវ តំបន់៤។ សូ ឈិញ សិស្សថ្នាក់ទីបញ្ចប់បច្ចុប្បន្នប្រជាជននៅស្រុកបវេល តំបន់៥។ ទន់សោ សិស្សថ្នាក់ទីបញ្ចប់ បច្ចុប្បន្នក្ដាប់មិនបាន។ សេង យុទ្ធិរិត សិស្សឆ្នាំទី២ បច្ចុប្បន្នក្ដាប់មិនបាន។ ទូច សីង្រាចាន់ សិស្សថ្នាក់ទី១ បច្ចុប្បន្នក្ដាប់មិនបាន។ មី ណារី សិស្សថ្នាក់ទីបញ្ចប់ បច្ចុប្បន្នក្ដាប់មិនបាន។ ងិន យឹន សិស្សថ្នាក់ទីបញ្ចប់ បច្ចុប្បន្ននៅកងចល័តស្រុក៨៣ តំបន់៤។ ខ្សែទាក់ទងទាំង៩ នាក់ខាងលើ គឺត្រូវដើរឃោសនាប្រជាជននៅភូមិស្លាកែត ស្រុក៨៣ អំពីនយោបាយរបស់បដិវត្តន៍ គឺមានភាពឃោរឃៅ កាប់សម្លាប់ប្រជាជនលក់ដីឱ្យយួន និង បំបាត់ពូជសាសន៍ខ្មែរ។

នៅឆ្នាំ១៩៧៣ និងឆ្នាំ១៩៧៤ លឹម ហ៊ិត កសាងកម្លាំងបានចំនួន៥នាក់ បន្ថែមទៀតគឺ ១) សុក នៅ សិស្សថ្នាក់ទីបញ្ចប់បច្ចុប្បន្នក្ដាប់មិនបាន។ ២) ស្រី ផន សិស្សថ្នាក់ទីបញ្ចប់ បច្ចុប្បន្នក្ដាប់មិនបាន។ ៣) យស់ ស្រស់ សិស្សថ្នាក់ទីបញ្ចប់ បច្ចុប្បន្នក្ដាប់មិនបាន។ ៤) ភូ កុសល់និមិត្រ សិស្សថ្នាក់ទីបញ្ចប់ បច្ចុប្បន្នក្ដាប់មិនបាន និង ៥) សេង សឹន សិស្សថ្នាក់ទី១ បច្ចុប្បន្នក្ដាប់មិនបាន។ កម្លាំងទាំង៥នាក់ ដែលកសាងបានមក គឺ លឹម ហ៊ិត ចាត់តាំងឱ្យធ្វើសកម្មភាពអប់រំសិស្សឱ្យស្រឡាញ់របបសេរី ផ្សព្វផ្សាយពីសៀវភៅលោកសេរី និងបញ្ចាំងកុនពីការសប្បាយ ភ្លឹតភ្លើនតាមរូបភាពរបស់ចក្រពត្តិ។ បន្ថែមពីនោះ គឺកម្លាំងទាំង៥នាក់ ត្រូវចាត់តាំងបន្តឱ្យទៅតាមដានសកម្មភាពរបស់ខ្មែរក្រហមនៅភូមិអន្លង់វិល ភូមិពាមឯក ភូមិអូរដំបង ក្នុងស្រុក៨១ (ស្រុកសង្កែ) ដោយប្រើរូបភាពជាអ្នកលក់នំប៉័ង លក់កៅស៊ូប៉េងប៉ោង សម្រាប់ក្មេងលេង និងធ្វើជាអ្នកលក់ការ៉េមកីជាដើម។

នៅខែមិថុនា ឆ្នាំ១៩៧៥ លឹម ហ៊ិត ត្រូវអង្គការជម្លៀសឱ្យទៅនៅភូមិជ្រៃកោង ឃុំបួន ស្រុកដូនទាវ តំបន់៤ ភូមិភាគពាយ័ព្យ។ លឹម ហ៊ិត ចូលទៅរស់នៅជាមួយក្រុមយុវជនដែលដឹកនាំដោយឈ្មោះ ស៊ុវ៉ាន់ អតីតសាស្ត្រាចារ្យ បច្ចុប្បន្នមាននាទីជាប្រធានកង។ ហេតុនេះ លឹម ហ៊ិត និង ស៊ុវ៉ាន់បានធ្វើការទាក់ទងគ្នាជាបន្តបន្ទាប់។ ស៊ុវ៉ាន់ បានបំភ្លៃថាអង្គការនឹងបោសសម្អាតកូនសិស្ស និងគ្រូនៅថ្ងៃខាងមុខសូមឱ្យ លឹម ហ៊ិត ចូលរួមប្រឆាំងជាមួយបដិវត្តន៍បន្តទៀត។ នៅខែកក្កដា ឆ្នាំ១៩៧៥ លឹម ហ៊ិត បានទៅទាក់ទងខ្សែរយៈ សេ-អ៊ី-អា ចំនួន១០នាក់ទៀត មានដូចជា៖ ផុន, វណ្ណធី, សុក លី, មាស រឿន, ប៉ែន រ៉ម, សេង គឹមអាន, សំអាត, ចាន់ សំណាង, សេង នី និង អ៊ុំ ភាក់សីលា ដើម្បីឱ្យចូលរួមធ្វើសកម្មភាពបំផ្លាញសំណាប និងស្រូវ ចាំចាប់ចំណុចខ្សោយរដ្ឋអំណាចភូមិឃុំ រួចឃោសនាប្រឆាំង និង បំផុសប្រជាជនឱ្យធ្វើពុតឈឺ ដោយយកលេសថាខ្វះរបស់។ នៅខែសីហា ឆ្នាំ១៩៧៥ លឹម ហ៊ិត និង បក្ខពួកទាំងអស់បានទទួលផែនការពី ស៊ុវ៉ាន់ឱ្យត្រៀមខ្លួនរត់ចូលព្រៃក្បាលចោរ ដែលមានទីតាំងជាប់ព្រំដែនសៀម។ គោលបំណងគឺដើម្បីចូលរួមកម្លាំងជាមួយឈ្មោះ វ៉ាន់ណាត មានតួនាទីជាស័ក្តិ១ និង ឈ្មោះ វ៉ាន់ ហ្វាន់មឿង មានតួនាទីជាស័ក្តិ៥ នៅស្រុកសៀម ដើម្បីចូលមកអុកឡុកនៅក្នុងស្រុក៨៣ តំបន់៤។

នៅឆ្នាំ១៩៧៦ ដោយសារទាក់ទង វ៉ាន់ណាត

មិនបាន ហេតុនេះផែនការរត់ចូលព្រៃក្បាលចោរ មិនបានសម្រេចទេ។ លឹម ហ៊ិត និងបក្ខពួកត្រូវ ស៊ុវ៉ាន់ចាត់តាំងឱ្យធ្វើសកម្មភាពប្រឆាំងជាមួយបដិវត្តន៍បន្តទៀត។ សកម្មភាពដែលទទួលបានពី ស៊ុវ៉ាន់គឺឱ្យបំផ្លាញសម្ភាររបស់បដិវត្តន៍មានដូចជា ៖ លួចដុតកណ្ដាប់ស្រូវ បំផ្លាញពូជស្រូវ លួចបោះចោលសំណាបដែលត្រូវយកទៅស្ទូង បញ្ចូលទឹកចូលក្នុងសំណាបដើម្បីឱ្យរលួយ លួចកាប់ទូក និងរទេះគោ។ បន្ទាប់មកទៀតគឺត្រូវលួចស្រូវដែលប្រមូលផលបានយកទៅឱ្យខាងចោរព្រៃដែលដឹកនាំដោយ វ៉ាន់ណាត។ ក្រោយមកទៀត ស៊ុវ៉ាន់បានចាត់តាំង លឹម ហ៊ិត ឱ្យយកគ្រាក់ចំនួន២០សន្ទឹកយកទៅបាចនៅភូមិដាំស្ពៃ និង ភូមិស្លាកែត ដែលបង្ហាញពីខ្ញឹមសារ ទាមទារឱ្យអង្គការបើកផ្សារ និងរៀបចំសាលារៀនឡើងវិញ។

នៅខែមេសា ឆ្នាំ១៩៧៧ លឹម ហ៊ិត ត្រូវដាច់ខ្សែទាក់ទងជាមួយ ស៊ុវ៉ាន់ ព្រោះអង្គការបានដកឱ្យទៅនៅអង្គភាពនេសាទចល័តរបស់ភូមិភាគ។ ស្ថិតនៅអង្គភាពនេសាទ លឹម ហ៊ិត បានចូលទៅទាក់ទងភ្ជាប់ខ្សែរយៈ សេ-អ៊ី-អា ឈ្មោះ ប៉ាន មានតួនាទីជាអនុគណៈកម្មាធិការ នេសាទរបស់ភូមិភាគ បច្ចុប្បន្នត្រូវអង្គការចាប់ខ្លួន។ លឹម ហ៊ិត ចូលទៅទាក់ទង ប៉ាន បានតាមរយៈឈ្មោះ សារី អតីតជានិស្សិតមហាវិទ្យាល័យច្បាប់ បច្ចុប្បន្នជាយុទ្ធជននេសាទ និងត្រូវជាក្មួយរបស់ ប៉ាន ផ្ទាល់។ ស្ថិតក្នុងកងនេសាទចល័ត លឹម ហ៊ិត នៅតែបន្តធ្វើសកម្មភាពប្រឆាំងជាមួយបដិវត្តន៍ និងកសាងកម្លាំង ទើបអង្គការចាប់ខ្លួនគាត់នៅថ្ងៃទី៨ ខែកក្កដា ឆ្នាំ១៩៧៧។

**កំណត់ចំណាំ៖** អត្ថបទនេះដកស្រង់ចេញពីឯកសារចម្លើយសារភាពលេខ J០០១១២។ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំ និងធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម ដូច្នេះយើងមិនអាចសន្និដ្ឋានបានថាចម្លើយសារភាពរបស់ ធុច លឹម ហ៊ិត ពិតប្រាកដយ៉ាងណានោះទេ។



កម្មករនៅរោងជាងកំពុងដំឡើងទូកនេសាទនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។ (ហ៊ុនណា ប៊ឺយស្ត្រម/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# ផែនការសម្លាប់ប្រពន្ធរបស់ខ្សែរក្បត់ ដើម្បីកុំឱ្យខ្លួនជាប់ពាក់ព័ន្ធ

សុភ័ក្ត្រ ភាណា



*យោធាខ្មែរក្រហមជិះរថភ្លើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

ខ្ញុំឈ្មោះ ឌិល សារឿន អាយុ៣១ឆ្នាំ (ក្នុងឆ្នាំ១៩៧៧) កើតនៅស្រុកបាកាន ខេត្តពោធិ៍សាត់។ ឪពុករបស់ខ្ញុំឈ្មោះ ម៉ង់ ឌិល ស្លាប់នៅក្នុងវ័យ៦៦ឆ្នាំ ដោយសារជំងឺ និងម្ដាយរបស់ខ្ញុំឈ្មោះ ទូច ឆេ ស្លាប់នៅក្នុងវ័យ៤៨ឆ្នាំ ដោយសារជំងឺ។ ឪពុកម្ដាយខ្ញុំប្រកបរបរធ្វើស្រែចិញ្ចឹមជីវិត ហើយបងប្អូនខ្ញុំភាគច្រើនប្រកបរបរធ្វើស្រែបន្តពីគាត់ទាំងពីរនាក់។ ខ្ញុំមានបងស្រីម្នាក់, ប្អូនប្រុសបួននាក់ និងប្អូនស្រីម្នាក់ ក្នុងនោះបងនិងប្អូនស្រី ព្រមទាំងប្អូនប្រុសម្នាក់របស់ខ្ញុំ ប្រកបរបរធ្វើស្រែនៅស្រុកកំណើត ចំណែកឯប្អូនប្រុសបីនាក់ផ្សេងទៀតរបស់ខ្ញុំ គឺជាកម្មកររថភ្លើងនៅមង្គលបូរីក្នុងតំបន់៣, ជាកម្មកររថភ្លើងនៅបាត់ដំបង និងជាយោធាប្រចាំការនៅព្រំដែនខ្មែរ-សៀម។ ខ្ញុំមានប្រពន្ធឈ្មោះ អ៊ុច សឿន អាយុ២៩ឆ្នាំ និងមានកូនតូចៗពីរនាក់។

នៅមុនពេលចូលបម្រើបដិវត្តន៍ ខ្ញុំនិងប្រពន្ធប្រកបរបរធ្វើស្រែចិញ្ចឹមជីវិត និងពុំចេះអក្សរឡើយ។ ក្រោយមកខ្ញុំ និងប្រពន្ធបានចូលធ្វើបដិវត្តន៍ ដោយប្រពន្ធរបស់ខ្ញុំធ្វើជាកម្មកររថភ្លើងនៅខេត្តបាត់ដំបង ហើយខ្ញុំទទួល

តួនាទីផ្នែកយោធា នៅឆ្នាំ១៩៧០។ ក្រោយពីខ្ញុំចូលធ្វើបដិវត្តន៍នៅភូមិបុស្សីក្រាំង ក្នុងតួនាទីជាយោធាតំបន់២ នៅឆ្នាំ១៩៧១ ខ្ញុំបានទៅធ្វើការនៅអង្គភាពយោធាស្រុកបាកាន បានចំនួន៣ខែ និងបានចូលជាយោធាភាគនៅគ-១៣។

នៅឆ្នាំ១៩៧៣ ខ្ញុំបានប្តូរទៅកាន់អង្គភាពគ-២០។ ខ្ញុំបានសម្រាកមួយរយៈក្នុងឆ្នាំ១៩៧៤ និងនៅក្នុងឆ្នាំដដែលនេះ ខ្ញុំបានចូលធ្វើការនៅអង្គភាពគ-១៣វិញ រហូតទាល់តែរបបកម្ពុជាប្រជាធិបតេយ្យទទួលជ័យជម្នះ ក្នុងឆ្នាំ១៩៧៥។

បន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យទទួលជ័យជម្នះ និងគ្រប់គ្រងប្រទេសបានទាំងស្រុងក្នុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ យុទ្ធជន-យុទ្ធនារី ដែលបម្រើការងារនៅយោធាគ-១៣ ត្រូវផ្លាស់ឱ្យមកធ្វើជាកម្មកររថភ្លើងនៅខេត្តបាត់ដំបង ដោយទទួលភារកិច្ចផ្នែកសំណង់។ នៅពេលនោះ ក្រុមគ្រួសាររបស់ខ្ញុំបានផ្លាស់មករស់នៅទីកន្លែងស្នាក់សម្រាប់កម្មកររថភ្លើងខេត្តបាត់ដំបង និងផ្នែកសំណង់។ បន្ទាប់មក ខ្ញុំបានស្គាល់និងទាក់ទងឈ្មោះ ឡឹង។

នៅក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៦ ឡឹង បានប្រាប់ខ្ញុំថា គាត់បានចាត់តាំងឈ្មោះ លន់ ឱ្យសម្លាប់ប្រពន្ធរបស់ឈ្មោះ រាជដាត់ ប៉ុន្តែ លន់ ធ្វើមិនបានសម្រេច។ នៅខាងមុខផ្ទះរបស់គាត់ ដោយមាននីសាររបស់គាត់ពីរនាក់ទៀតគឺឈ្មោះប៉ូ និងឈ្មោះ លី បានដឹងឮដែរ។ គាត់ប្រាប់ថាប្រសិនបើឱ្យខ្ញុំធ្វើកិច្ចការនេះ អាចនឹងមិនមានបញ្ហា ប៉ុន្តែ ឡឹង មិនបានចាត់តាំងការងារនេះមកខ្ញុំទេ។ ឡឹង គ្រាន់តែប្រាប់ខ្ញុំថា នារីដែលជាប្រពន្ធរបស់ រាជដាត់ បានលួចថ្នាំពេទ្យ និងស្ករ។ ខ្ញុំធ្លាប់បានឮ លន់ ប្រាប់ខ្ញុំអំពីការចាត់តាំងផែនការ កាលពីខែធ្នូ ឆ្នាំ១៩៧៦។ លន់ ប្រាប់ខ្ញុំថា ប្រពន្ធរបស់ រាជ ដាត់ មានឈ្មោះនារីបូដាន់ ហើយទីតាំងដែលចាត់តាំងឱ្យសម្លាប់គឺស្ថិតនៅចម្ការចេក។ មិនយូរប៉ុន្មាន ខ្ញុំបានទទួលការចាត់តាំងថ្មីពី ឡឹង ឱ្យសម្លាប់នារីជាប្រពន្ធរបស់ខ្សែបណ្តាញម្នាក់ទៀត។

នៅយប់ថ្ងៃទី១៣ ខែមករា ឆ្នាំ១៩៧៧ នារីយ៉ាដា (សមមិត្តនារីម្នាក់ទៀត) បានបាត់ខ្លួន។ មុនហេតុការណ៍នេះ១០ថ្ងៃ ខ្ញុំ, ប៉ូ, ឡឹង និងម្នាក់ទៀតឈ្មោះ សុង បានជួបគ្នាដោយសម្ងាត់នៅរោងជាងឡានស្ថិតក្នុងផ្នែករថភ្លើងខេត្តបាត់ដំបង។ នៅក្នុងជំនួប ឡឹង បានចាត់តាំងខ្ញុំ, ប៉ូ និង សុង ទៅសម្លាប់ នារីយ៉ាដា។ ឡឹង បានបញ្ជាក់ថា៖ «បើមិនសម្លាប់នារីយ៉ាដាចោលទេ ពេលបែកការត្រូវស្លាប់ទាំងអស់គ្នា»។ ឡឹង ថែមទាំងសង្កត់ធ្ងន់ប្រាប់យើងទាំងបីនាក់ថា ផែនការទាំងនេះ មិនត្រូវនិយាយប្រាប់នរណាទេ ចៀសវាងបែកការណ៍ ហើយត្រូវរង់ចាំឱកាសហុចឱ្យដើម្បីអនុវត្ត។ ឡឹងបានប្រាប់ទៀតថាមូលហេតុដែលត្រូវសម្លាប់នារីយ៉ាដាចោល ព្រោះអង្គការបានចាប់ និងសម្លាប់ប្តីរបស់នារីនេះហើយ។ ដូច្នេះ យើងត្រូវសម្លាប់នារីនេះ ដើម្បីកុំឱ្យជាប់ពាក់ព័ន្ធ។ ក្នុងថ្ងៃកើតហេតុ នាវេលាម៉ោង៨កន្លះយប់ យើងទាំង៤នាក់ដែលរួមទាំង ឡឹង បានជួបគ្នាម្តងទៀតនៅជ្រុងខាងលិចសាលារៀនរបស់កម្មកររថភ្លើងខេត្តបាត់ដំបង។ នៅពេលនោះ ឡឹង ចាត់តាំងខ្ញុំ, ប៉ូ និងសុង អនុវត្តផែនការសម្លាប់ នារីយ៉ាដា។ នៅម៉ោង៩យប់ បន្ទាប់ពីទទួលផែនការ យើងបានសំដៅទៅកាន់ផ្ទះ នារីយ៉ាដាទាំង៤នាក់។ ប៉ូ គឺជាអ្នកយាមផ្លូវមុខស្ថានីយរថភ្លើងដោយអង្គុយត្រង់ដងទង់។ ឡឹង និងខ្ញុំ ឈរចាំមុខផ្ទះ នារីយ៉ាដា។ សុង ចូលទៅជិតមាត់ទ្វារផ្ទះ នារីយ៉ាដា និងហៅឱ្យគាត់ចេញមកក្រៅ។ សុងថែមទាំងបានប្រាប់ឱ្យ នារីយ៉ាដា យកកន្ទេលមកជាមួយ រួចធ្វើដំណើរទៅចម្ការចេក។

នៅពេលធ្វើដំណើរទៅកាន់ចម្ការចេក យើងទាំង៤នាក់បានទៅជាមួយ នារីយ៉ាដា ទាំងអស់គ្នា។ យើងបានធ្វើដំណើរយ៉ាងឆ្ងាយកាត់តាមមុខរោងចក្រ និងបានទៅដល់ប្រឡាយមួយស្ថិតនៅខាងត្បូងរោងចក្រតម្បាញ។ មកដល់ត្រឹមនេះ ឡឹងបានចាកចេញទៅ និងទុកតួនាទីឱ្យខ្ញុំ, សុង និង ប៉ូ គឺជាអ្នកអនុវត្ត។ យើងបន្តដំណើរទៅមុខទៀតរហូតដល់ភូមិអង្គរួចហើយបត់ទៅ

ទិសខាងត្បូង សំដៅទៅកាន់ភ្លឺស្រែចាស់មួយ។ យើងបានមកដល់ជង្រុកស្រូវមួយកន្លែង ហើយទុកឱ្យ នារីយ៉ាដា នៅជាមួយប៉ូដើម្បីឱ្យប៉ូរំលោភមុនពេលសម្លាប់នាង។ ខ្ញុំនិង សុង បែកផ្លូវគ្នាដើររកដំបង ដោយខ្ញុំរកបានដំបងបួនជ្រុងមួយ ហើយ សុង រកបានដំបងមូលមួយ។ ក្រោយ ប៉ូរំលោភ នារីយ៉ាដារួចរាល់ ខ្ញុំបានវាយនាងពីរដំបងត្រូវក្បាល និងស្មា។ បន្ទាប់មក សុងបានបន្តវាយនាងរហូតដល់ស្លាប់។ បន្ទាប់ពីសម្លាប់ នារីយ៉ាដា រួចរាល់ យើងបានដាក់សពនាងផ្កាប់មុខលើកន្ទេល ហើយដាក់ដំបងខ្វែងចំពីលើកន្ទេលចំកណ្តាលក្បាលសព។ បន្ទាប់ពីរៀបចំសពរួចរាល់ សុង, ប៉ូ និងខ្ញុំបានបំបែកគ្នាទៅផ្ទះរៀងខ្លួន។ រំលងបានមួយថ្ងៃ ខ្ញុំបានទៅដេកនៅរោងគ្រាក់ទ័រ នៅភូមិអង្គមួយយប់ដើម្បីក្តាប់សភាពការណ៍។ នៅទីនោះ ខ្ញុំស្នាក់នៅជាមួយ ប៉ូ, កម្មាភិបាល តាន់, អឿន, ម៉ន និង សារុិន។ ដោយសារពុំមានសភាពការណ៍ខុសប្លែក ខ្ញុំបានត្រឡប់មកផ្ទះវិញ។ ក្រោយពីសម្លាប់នារីយ៉ាដា បានប្រមាណ ៥ថ្ងៃ ខ្ញុំត្រូវអង្គការចាប់ខ្លួននៅយប់ថ្ងៃទី១៩ ខែមករា ឆ្នាំ១៩៧៧។

**កំណត់ចំណាំ៖** អត្ថបទនេះដកស្រង់ចេញពីឯកសារចម្លើយសារភាពលេខ J00៤៥៨ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំ និងធ្វើទារុណកម្ម យ៉ាងធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម។ ដូច្នេះយើងមិនអាចសន្និដ្ឋានបានថា ចម្លើយសារភាពរបស់ ឌិល សារឿន ពិតប្រាកដប៉ុណ្ណោះយ៉ាងណានោះទេ។



រូបពាក់មួកនៅខាងស្តាំ និងដើរខាងមុខ៖ អៀង សារី ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដឹកនាំគណៈប្រតិភូចុះត្រួតពិនិត្យផ្លូវរថភ្លើង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ព្រះរាជបណ្ណាល័យហ្លួងម៉ែនៃមជ្ឈមណ្ឌលឯកសារកម្ពុជា បោះពុម្ពសៀវភៅថ្មីមានចំណងជើងថា «សាក្សីប្រវត្តិសាស្ត្រ ៖ ព្រះរាជជីវប្រវត្តិដ៏ឧត្តុងឧត្តម សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ»

**មីន សាណាស់**




ក្របសៀវភៅ សាក្សីប្រវត្តិសាស្ត្រ ៖ ព្រះរាជជីវប្រវត្តិដ៏ឧត្តុងឧត្តម សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ»។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី៨ ខែសីហា ឆ្នាំ២០២៦ ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា បានផ្ញើព្រះលិខិតថ្លែងអំណរគុណចំពោះ ឯកឧត្តម ឆាំង យុ ឯកអគ្គរាជទូតអមព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ និងជានាយក «ព្រះរាជបណ្ណាល័យ ហ្លួងម៉ែ» នៃមជ្ឈ-មណ្ឌលឯកសារកម្ពុជា ចំពោះការបញ្ចប់ដោយជោគជ័យបោះពុម្ពសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ៖ ព្រះរាជជីវប្រវត្តិដ៏ឧត្តុងឧត្តម សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ»។ នៅក្នុងលិខិត ព្រះករុណា បានថ្លែងអរគុណចំពោះ ការលះបង់ និងការខិតខំប្រឹងប្រែងរបស់ឯកឧត្តម ឆាំង យុ រួមជាមួយនឹងការប្តេជ្ញាចិត្តរបស់ក្រុមការងារ បានជួយថែរក្សាទុកនូវទំព័រប្រវត្តិសាស្ត្រដ៏សំខាន់មួយនៃជាតិ និងកេរដំណែលដ៏ស្ថិតស្ថេររបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ។

នៅថ្ងៃទី១១ ខែ សីហា ឆ្នាំ២០២៦ សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ បានផ្ញើលិខិតថ្លែងកោតសរសើរយ៉ាងកក់ក្តៅជូន ឆាំង យុ ចំពោះ ឯកឧត្តម ឆាំង យុ ឯកអគ្គរាជទូតអមព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ និងជានាយក «ព្រះរាជបណ្ណាល័យ ហ្លួងម៉ែ» នៃមជ្ឈមណ្ឌលឯកសារកម្ពុជា ចំពោះការខិតខំស្រាវជ្រាវ ចងក្រងសៀវភៅប្រវត្តិសាស្ត្រជាច្រើននូវភស្តុតាងស្តីអំពី ព្រះរាជក្រឹត្យ ព្រះបរមងារ និងព្រះរាជបុព្វសិទ្ធិថ្វាយអតីតព្រះមហាក្សត្រ ព្រះមហាក្សត្រី នៃព្រះរាជាណាចក្រកម្ពុជា និងជាឯកសារដ៏មានតម្លៃធំធេងជាមូលដ្ឋានសំខាន់សម្រាប់អ្នកជំនាន់ក្រោយ។ សៀវភៅឯកសារ **«សាក្សីប្រវត្តិសាស្ត្រ ៖ ព្រះរាជជីវប្រវត្តិដ៏ឧត្តុងឧត្តម សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវរ**

**រាជមាតាជាតិខ្មែរ**» បានបញ្ជាក់យ៉ាងច្បាស់លាស់ និងជាសាក្សីក្នុងដំណាក់កាលនីមួយៗ ដែលព្រះអង្គបានខិតខំដង្ហែបម្រើ ព្រះករុណាព្រះមហាវីរក្សត្រ ព្រះវររាជបីតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ ព្រះបរមរតនកោដ្ឋ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ដោយស្មោះស្ម័គ្រ ស្មាមីភក្តិ និងបម្រើប្រជាជាតិ ប្រជារាស្ត្រកម្ពុជាជាទីស្នេហា។

សៀវភៅ «**សាក្សីប្រវត្តិសាស្ត្រ៖ ព្រះរាជជីវប្រវត្តិដ៏ឧត្តុងឧត្តម សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ**» ត្រូវបានរៀបរៀងឡើងជាភាសាខ្មែរ និងអង់គ្លេស ក្នុងគោលបំណងក្រាបបង្គំទូលថ្វាយអំណរព្រះគុណ និងអបអរសាទរក្នុងឱកាសនៃព្រះរាជពិធីចម្រើនព្រះជន្មគម្រប់៩០ យ៉ាងចូល៩១ព្រះវស្សារបស់សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ នៅថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២៦ ចំពោះព្រះរាជកិច្ចឥតរួញរារបស់ព្រះអង្គជូនជាតិ និងពិភពលោក។ លើសពីនេះ ការបោះពុម្ពសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ៖ ព្រះរាជជីវប្រវត្តិដ៏ឧត្តុងឧត្តម សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ» ចង់បង្ហាញឱ្យឃើញពីការវិវត្តន៍ក្នុងនាមជាយុវតីដែលជារាស្ត្រសាមញ្ញ រហូតទទួលព្រះរាជក្រឹត្យតែងតាំង និងព្រះគោរមងាររជាបន្តបន្ទាប់ ជាសម្តេចព្រះមហាក្សត្រី នៃព្រះរាជាណាចក្រកម្ពុជា។

សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ គឺព្រះអង្គតែម្នាក់គត់ ដែលបានទតឃើញផ្ទាល់ព្រះនេត្រនូវដំណើរឆ្លងកាត់ដ៏លំបាករបស់កម្ពុជា ចាប់តាំងពីសម័យអាណានិគម សម័យឯករាជ្យ សង្គ្រាម សោកនាដកម្ម រហូតដល់សម័យកាលនៃការរស់រានមានជីវិតពីរបបខ្មែរក្រហម និងការអភិវឌ្ឍន៍ប្រទេសឱ្យទៅជាសង្គមសម័យទំនើប។ សម្តេចព្រះមហាក្សត្រីបានដង្ហែអមព្រះកាយ ព្រះករុណា ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋឆ្លងកាត់ការភៀសព្រះកាយ និងគ្រោះថ្នាក់ស្ទើរដល់ព្រះជន្ម ដោយបានបំពេញព្រះរាជកិច្ច និងធ្វើជាព្រះរាជគំរូដ៏ខ្ពង់ខ្ពស់។ សម្តេចព្រះមហាក្សត្រីគឺជាបុគ្គលគំរូសម្រាប់ស្ត្រី និងយុវនារី តាមរយៈជីវប្រវត្តិ


"Witness to History: The Storied Life of Cambodia's Queen Mother"

ព្រះរាជលិខិតសម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ថ្លែងកោតសរសើរយ៉ាងកក់ក្តៅ ជូនចំពោះ ឯកឧត្តម ឆាំង យុ ឯកអគ្គរាជទូតអមព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ និងជានាយក «ព្រះរាជបណ្ណាល័យ ហ្វូងម៉ែ» នៃមជ្ឈមណ្ឌលឯកសារកម្ពុជា។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

របស់ព្រះអង្គ ដែលជាមូលដ្ឋានគ្រឹះនៃការបំផុសគំនិតជាពិសេសកុមារី និងស្ត្រីវ័យក្មេងៗ សម្តេចព្រះមហាក្សត្រីគឺជាគំរូនៃថ្នាក់ដឹកនាំស្ត្រីដែលបំផុសគំនិតតាមរយៈការចូលរួមយ៉ាងស្ងៀមស្ងាត់ ទន់ភ្លន់ ប៉ុន្តែរឹងមាំ និងម៉ឺងម៉ាត់។ មិនត្រឹមតែប៉ុណ្ណោះ សម្តេចព្រះមហាក្សត្រីគឺជាគំរូក្នុងការប្រែក្លាយបទពិសោធន៍ជីវិតឱ្យទៅជាមេរៀន និងបែបផែននៃការអប់រំ និងការតម្រង់ទិសដល់យុវនារីជំនាន់ក្រោយ។

យោងតាមសៀវភៅ «**សាក្សីប្រវត្តិសាស្ត្រ៖ ព្រះរាជជីវប្រវត្តិដ៏ឧត្តុងឧត្តម សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ**» បានបង្ហាញលិខិតកាលប្បវត្តិនៃព្រះគោរមងាររជាប្រវត្តិសាស្ត្រ



សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ និងលោក ឆាំង យុ ឯកអគ្គរាជទូតអមព្រះរាជខុទ្ទកាល័យ ព្រះមហាក្សត្រ និងជានាយក «ព្រះរាជបណ្ណាល័យ ហ្វូងម៉ែ» នៃមជ្ឈមណ្ឌលឯកសារកម្ពុជា នៅព្រះបរមរាជវាំង។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

និងព្រះរាជគុណូបការៈ ជាផ្លូវការ មានដូចជា៖

នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ១៩៩២៖ សម្តេចព្រះ នរោត្តម សីហនុ បានឡាយព្រះហស្តលេខាលើ «ក្រឹត្យ» ដំឡើងព្រះឋានៈពី «អ្នកម្នាង នរោត្តម ម៉ូនីក សីហនុ» ទៅជា «**សម្តេចព្រះជាយា**»។

នៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣៖ ត្រាស់បង្គាប់តែងតាំង សម្តេចព្រះជាយា នរោត្តម ម៉ូនីក សីហនុ ជា «សម្តេចព្រះមហេសី នៃព្រះរាជាណាចក្រកម្ពុជា»។

នៅថ្ងៃទី៣ ខែតុលា ឆ្នាំ១៩៩៣៖ ត្រាស់បង្គាប់តែងតាំងជា «សម្តេចព្រះមហេសី នរោត្តម មុនិនាថ សីហនុ នៃព្រះរាជាណាចក្រកម្ពុជា» ដោយព្រះនាម «មុនិនាថ» មានន័យថា «អ្នកដែលជាទីពឹង ជាទីពំនាក់របស់អ្នកប្រាជ្ញ»។

នៅថ្ងៃទី២ ខែមករា ឆ្នាំ១៩៩៦៖ ប្រទានព្រះនាមជា «សម្តេចព្រះរាជអគ្គមហេសី នរោត្តម មុនិនាថ សីហនុ នៃព្រះរាជាណាចក្រកម្ពុជា»។

នៅថ្ងៃទី២៩ ខែតុលា ឆ្នាំ២០០៤៖ ច្បាប់ដែលត្រូវបានប្រកាសឱ្យប្រើប្រាស់ បានកំណត់ថ្វាយព្រះគោរមងារជា «**សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល**»។

ក្រៅពីព្រះគោរមងារដ៏ខ្ពង់ខ្ពស់ខ្ពង់ខ្ពស់ខាងលើ សម្តេចព្រះមហាក្សត្រីបានដឹកនាំ និងលះបង់ក្នុងកិច្ចការមនុស្សធម៌តាមរយៈកាកបាទក្រហមកម្ពុជា។ ការបំពេញព្រះរាជបេសកកម្មការទូតយ៉ាងលេចធ្លោក្នុងប្រទេស និងអន្តរជាតិ ក្នុងព្រះរាជឋានៈជាស្ត្រីទីមួយ។ ការចូលរួមក្នុងព្រះរាជបូជនីយកិច្ចដើម្បីឯករាជ្យជាតិ ឆ្នាំ១៩៥៣ និងចលនាតស៊ូរំដោះជាតិ។ ការមើលថែទាំព្រះស្វាមី ព្រះករុណា ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ ដោយភក្តីភាព និងធ្វើជាព្រះរាជគ្រូពេទ្យផ្ទាល់ ព្រមទាំងការបំពេញមុខងារជាអគ្គហេរញ្ញិក និងនាយកខុទ្ទកាល័យ។

នៅផ្នែកចុងក្រោយសៀវភៅ «**សាក្សីប្រវត្តិសាស្ត្រ៖ ព្រះរាជជីវប្រវត្តិដ៏ឧត្តុង្គឧត្តម សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ**» បានបង្ហាញពីការអភិរក្ស និងការកែលម្អព្រះរាជកេរដំណែលរបស់ព្រះករុណា សម្តេចព្រះ នរោត្តម សីហនុ

ព្រះបរមរតនកោដ្ឋ គឺ ទី១) អំពីពោធិ៍ចិនតុងកើតឡើងវិញ (ពីផ្ទៃសំណង់រឹងទៅជាទេសភាពធម្មជាតិ)៖ គម្រោងរៀបចំអតីតអាកាសយានដ្ឋានពោធិ៍ចិនតុងឱ្យទៅជាប្រព័ន្ធអេកូឡូស៊ីបៃតង មជ្ឈមណ្ឌលវប្បធម៌ និងទីក្រុងអេប៉ុង។ ក្នុងនោះ «ព្រះរាជបណ្ណាល័យហ្លួងម៉ែ» ត្រូវបានបង្កើតឡើងនៅចំស្នូលនៃបួងមេ ដើម្បីធ្វើជាវិទ្យាស្ថាន-សារមន្ទីរ រក្សាទុកប្រវត្តិសាស្ត្រ និងតភ្ជាប់ទំនាក់ទំនងរវាងមនុស្សជំនាន់មុននិងមនុស្សជំនាន់ក្រោយ។ ទី២) អគារមរតកសង្គមរាស្ត្រនិយម សម្តេចឪ-សម្តេចម៉ែ (បុរីអូរស្វាយ-សែនជ័យ)៖ ការស្តារ និងអភិរក្សទីតាំងប្រវត្តិសាស្ត្រក្នុងខេត្តស្ទឹងត្រែង ដែលបង្កើតឡើងតាំងពីឆ្នាំ១៩៦៤។ អគារនេះត្រូវបានសម្ពោធជាផ្លូវការក្នុងឆ្នាំ២០២៥ ដោយមានបង្កើតបណ្ណាល័យបណ្តែតទឹកចល័តសម្រាប់បម្រើដល់ប្រជាជន និងសិស្សានុសិស្សនៅតាមកោះជុំវិញ និងទី៣) ការកែប្រែទីតាំងអតីតព្រះរាជដំណាក់សម័យសង្គមរាស្ត្រនិយមក្នុងខេត្តស្ទឹងត្រែងទៅជា ព្រះសារមន្ទីរ ដែលសម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ សព្វព្រះរាជហឫទ័យយ៉ាងខ្លាំង។



លោក ទិត្យ សត្យាវង្ស ប្រធានក្រុមស្ថាបត្យកម្មព្រះរាជបណ្ណាល័យ ហ្លួងម៉ែ នៃមជ្ឈមណ្ឌលឯកសារកម្ពុជា ជូនសៀវភៅសាកវីប្រវត្តិសាស្ត្រ៖ ព្រះរាជជីវប្រវត្តិដ៏ឧត្តុង្គឧត្តម សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ» ដល់ឯកឧត្តម ហួត ហាក់ រដ្ឋមន្ត្រីក្រសួងទេសចរណ៍។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



លោក ទិត្យ សត្យាវង្ស ប្រធានក្រុមស្ថាបត្យកម្មព្រះរាជបណ្ណាល័យ ហ្លួងម៉ែ នៃមជ្ឈមណ្ឌលឯកសារកម្ពុជា ជូនសៀវភៅសាកវីប្រវត្តិសាស្ត្រ៖ ព្រះរាជជីវប្រវត្តិដ៏ឧត្តុង្គឧត្តម សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ» ដល់ឯកឧត្តម សរ សុពុត្រា គណៈអភិបាលខេត្តស្ទឹងត្រែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



លោក ទិត្យ សត្យាវង្ស ប្រធានក្រុមស្ថាបត្យកម្មព្រះរាជបណ្ណាល័យ ហ្លួងម៉ែ នៃមជ្ឈមណ្ឌលឯកសារកម្ពុជា ជូនសៀវភៅសាកវីប្រវត្តិសាស្ត្រ៖ ព្រះរាជជីវប្រវត្តិដ៏ឧត្តុង្គឧត្តម សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ» ដល់លោក លី មីនា អភិបាលក្រុងស្ទឹងត្រែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



លោក ទិត្យ សត្យាវង្ស ប្រធានក្រុមស្ថាបត្យកម្មព្រះរាជបណ្ណាល័យ ហ្លួងម៉ែ នៃមជ្ឈមណ្ឌលឯកសារកម្ពុជា ជូនសៀវភៅសាកវីប្រវត្តិសាស្ត្រ៖ ព្រះរាជជីវប្រវត្តិដ៏ឧត្តុង្គឧត្តម សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ» ដល់លោក ដាន់ យុត អភិបាលស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ខ្សែជីវិតរបស់វីរកងទ័ព ថន ពិទិ មុនពេលពលីនៅសមរភូមិតំបន់បឹងត្រកួន

ធី គឹមហុង

វីរកងទ័ព ថន ពិទិ អាយុ២៦ឆ្នាំ មានស្រុកកំណើតនៅភូមិក្បាលទឹកលើ ឃុំដាំសង្កែ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ។ ពិទិមានឪពុកឈ្មោះ ថនធី អាយុ៥៦ឆ្នាំ មានស្រុកកំណើតនៅឃុំអរិយក្សត្រ ស្រុកល្វាឯម ខេត្តកណ្ដាល ចំណែកម្ដាយឈ្មោះ ទី អិត អាយុ៥៥ឆ្នាំ មានស្រុកកំណើតនៅភូមិក្បាលទឹកលើ ឃុំដាំសង្កែ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ។ ពិទិ មានបងប្អូនចំនួន ៤នាក់ គឺស្រី២នាក់ និងប្រុស២នាក់។ ក្រោយមកក្រុមគ្រួសាររបស់ ពិទិបានផ្លាស់មករស់នៅភូមិសង្កែ ឃុំបឹងបេង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យតាំងពី ពិទិ នៅតូច។

កាលពីក្មេង ពិទិបានចូលរៀននៅសាលាបឋមសិក្សា និងអនុវិទ្យាល័យសង្កែ ក្នុងភូមិសង្កែ ឃុំបឹងបេង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ។ ពិទិបានឈប់រៀនត្រឹមថ្នាក់ទី៩ ដោយសារស្ថានភាពគ្រួសារមានការខ្វះខាតខ្លាំង។ នៅពេលត្រឡប់មកពីសាលារៀនវិញ ពិទិ តែងតែស៊ីឈ្នួលធ្វើការងារឱ្យអ្នកភូមិដើម្បីរកលុយជួយទ្រទ្រង់ជីវភាពគ្រួសារ។ ថ្ងៃមួយក្នុងឆ្នាំ ២០១៨ ពិទិ បានសម្រេចចិត្តសុំឪពុកម្ដាយទៅធ្វើការងារជាពលករចំណាកស្រុកនៅប្រទេសថៃតាមរយៈមិត្តភក្ដិ និងបងប្អូននៅក្នុងភូមិជាមួយគ្នា។ ដោយសារជីវភាពខ្វះខាតខ្លាំង ឪពុកម្ដាយបានអនុញ្ញាតឱ្យ ពិទិចេញទៅធ្វើការងារជាពលករចំណាកស្រុកទាំងនៅវ័យក្មេង។ ពេលធ្វើការងារជាពលករនៅប្រទេសថៃពិទិតែងតែផ្ញើប្រាក់មួយចំនួនមកជួយទំនុកបម្រុងឪពុកម្ដាយ និងទុកមួយចំនួនសម្រាប់ចាយវាយផ្ទាល់ខ្លួន។ ពិទិបានខិតខំធ្វើការងារនៅប្រទេសថៃរហូតដល់ឆ្នាំ២០២២ ទើបសម្រេចចិត្តត្រឡប់មករស់នៅស្រុកកំណើតវិញ រួចហើយបន្តធ្វើស្រែចម្ការជាមួយឪពុកម្ដាយ។



ថន ពិទិ អាយុ២៦ឆ្នាំ រស់នៅភូមិសង្កែ ឃុំបឹងបេង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ។ ពិទិ បានពលីជីវិតនៅសមរភូមិបឹងត្រកួន នៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២៥។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅក្នុងឆ្នាំ២០២២ ដដែលនោះ ពិទិបានសុំការអនុញ្ញាតពីឪពុកម្ដាយដើម្បីប្រឡងចូលបម្រើកងទ័ព។ ពេលនោះឪពុកម្ដាយបានអនុញ្ញាតឱ្យ ពិទិ ដាក់ពាក្យប្រឡង និងបានប្រឡងជាប់ចូលបម្រើកងទ័ពដូចបំណងប្រាថ្នានៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២២។ ក្រុមគ្រួសារ ពិទិ មានក្ដីរីករាយជាពន់ពេក ពីព្រោះបានឃើញកូនប្រុសចូលបម្រើជាតិមាតុភូមិ និងបានជួយសម្រាលបន្ទុកគ្រួសារមួយផ្នែកធំ។

ក្រោយពេលបានចូលបម្រើកងទ័ពពេញសិទ្ធិ ពិទិ ត្រូវបានថ្នាក់ដឹកនាំកងយោធពលខេមរភូមិន្ទបញ្ជូនទៅហ្វឹកហ្វឺននៅសាលាពលទាហានទី៥ ចំណុះយោធភូមិភាគទី៥ ក្នុងខេត្តបាត់ដំបងរយៈពេល៦ខែ។ បន្ទាប់ពីបញ្ចប់ការហ្វឹកហ្វឺន ពិទិ ត្រូវបានថ្នាក់ដឹកនាំកងយោធពលខេមរភូមិន្ទចាត់តាំងឱ្យមកបំពេញភារកិច្ចនៅទីបញ្ជាការតំបន់ប្រតិបត្តិការសឹករងខេត្តបន្ទាយមានជ័យ។ ភារកិច្ចចម្បងរបស់ ពិទិ ពេលនោះ គឺចុះល្បាតនៅតាមដងទន្លេសាប ដើម្បីជួយសង្គ្រោះប្រជាពលរដ្ឋ និងមើលការខុសត្រូវតាមតំបន់អភិរក្សផ្សេងៗ។ លោក ថន ធី ដែលត្រូវជាឪពុករបស់ ពិទិបានរៀបរាប់ថា កូនប្រុសរបស់ខ្ញុំគឺជាមនុស្សរឹងមាំ និងស្ងប់ស្ងាត់តាំងពីនៅក្មេង ហើយកូនខ្ញុំមិនដែលបង្ហាញភាពលំបាករបស់ខ្លួនឱ្យឪពុកម្តាយដឹងឡើយ។

នៅពេលផ្ទុះសង្គ្រាមកម្ពុជា-ថៃលើកទី១ នាថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២៥ ពិទិ មិនទាន់ត្រូវបានបញ្ជូនទៅសមរភូមិ ពីព្រោះមានរបួសលើស្មងជើង ដោយសារមុតពូថៅអំឡុងពេលចុះទៅល្បាតតាមដងទន្លេសាបកាលពីខែមិថុនាកន្លងទៅ។ ពេលនោះ ពិទិ មិនបានប្រាប់ក្រុមគ្រួសារឱ្យដឹងថាខ្លួនមានរបួសស្មងជើងទេពីព្រោះខ្លាចឪពុកម្តាយមានការព្រួយបារម្ភ។ មេបញ្ជាការបានមើលឃើញស្ថានភាពរបួសរបស់ ពិទិ ពិបាកក្នុងការធ្វើដំណើរទៅមក ទើបសម្រេចឱ្យ ពិទិ នៅប្រចាំការនៅក្នុងបន្ទាយរហូតដល់ជាសះស្បើយ។


ថន ពិទិ អាយុ២៦ឆ្នាំ រស់នៅភូមិសង្កែ ឃុំបឹងបេង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ។ ពិទិ បានពលីជីវិតនៅសមរភូមិបឹងត្រកួន នៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២៥។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅចុងខែសីហា ឆ្នាំ២០២៥ មេបញ្ជាការបម្រុងនឹងបញ្ជូនពិទិទៅសមរភូមិមុខទិសប្រាសាទព្រះវិហារ ប៉ុន្តែបងប្អូនធម៌របស់ ពិទិបានស្នើសុំមេបញ្ជាការឱ្យ ពិទិមកឈរជើងនៅសមរភូមិមុខតំបន់«បឹងត្រកួន»វិញ។ ពេលទៅដល់សមរភូមិមុខតំបន់បឹងត្រកួនភ្លាមៗ ពិទិមិនទាន់ប្រាប់ឪពុកម្តាយ ពីព្រោះមិនចង់ឱ្យពួកគាត់បារម្ភ។ លុះឈរជើងនៅសមរភូមិមុខតំបន់បឹងត្រកួនបានមួយរយៈ ទើបមិត្តភក្តិនៅក្នុងក្រុមជាមួយ ពិទិ បានប្រាប់ទៅឪពុកម្តាយរបស់ ពិទិ។ ចាប់តាំងពីបានដឹងថា ពិទិ ប្រចាំការនៅសមរភូមិជួរមុខ ក្រុមគ្រួសារបានទំនាក់ទំនងទៅ ពិទិ ជាប្រចាំរហូតដល់ថ្ងៃផ្ទុះសង្គ្រាមតាមព្រំដែនកម្ពុជាថៃជាលើកទី២នៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២៥។

បើតាមការបញ្ជាក់ពីលោក ថន ធី គឺនៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២៥ ពេលផ្ទុះអាវុធភ្លាមៗ លោកបានទំនាក់ទំនងជាមួយកូនប្រុសបានធម្មតា ប៉ុន្តែមួយថ្ងៃក្រោយមក លោក ថន ធី មិនអាចទាក់ទងកូនប្រុសបានឡើយ ពីព្រោះថ្នាក់ដឹកនាំបានតម្រូវឱ្យកងទ័ពជួរមុខបិទប្រព័ន្ធអេឡិចត្រូនិកដែលនៅជាប់ខ្លួនទាំងអស់។ ចាប់តាំងពីពេលនោះមកលោក ថន ធី និងប្រពន្ធបានត្រឹមតែទន្ទឹងរង់ចាំផ្លូវកូនប្រុស ទាក់ទងមកវិញ ប៉ុន្តែមិនឃើញទូរសព្ទមកសោះ។

នៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ ២០២៥ លោក ថន ធី និងប្រពន្ធបានទទួលដំណឹងថាកូនប្រុសបានពលីជីវិតក្នុងសមរភូមិហើយ។ មិត្តរួមអាវុធរបស់ ពិទិបានប្រាប់លោក ថន ធី និងភរិយាថា មុនពេល ពិទិ ពលី គឺមាន

ការបាញ់ប្រហារគ្នាយ៉ាងខ្លាំងក្លា នៅក្នុងគ្រានោះឈ្មោះ មករា ដែលជាមិត្តរួមអាវុធជាមួយ ពិទិ បានស្រែកឱ្យនាំគ្នាដកថយបន្តិច៖ «បងប្អូនយើង! ថយសិនរកកន្លែងមានសុវត្ថិភាព!» ប៉ុន្តែដោយសារសំឡេងគ្រាប់កាំភ្លើងលាន់រំពងខ្លាំងពេក ធ្វើឱ្យ ពិទិ និងវីរកងទ័ពកម្ពុជាដែលនៅក្នុងលេណដ្ឋានស្ទាប់មិនឮ និងមិនអាចដកថយបានភ្លាមៗឡើយ។ មួយរំពេចនោះ ដ្រូនរបស់ទាហានថៃមកទម្លាក់គ្រាប់បែកចំលេណដ្ឋានរបស់ ពិទិ ដែលមានសមាជិកប្រមាណ១០នាក់ និងបានពលីអស់ចំនួន៨នាក់។ នៅក្នុងចំណោមវីរកងទ័ពដែលបានពលី គឺមាន ពិទិ ម្នាក់ដែរ។ ចំណែក មករា និងកងទ័ពម្នាក់ទៀតបានដកថយមករកទីកន្លែងសុវត្ថិភាពទាន់ពេលវេលា និងមានរបួសស្រាល ហើយបានរួចផុតពីគ្រោះថ្នាក់ ។

វីរកងទ័ព ថន ពិទិ បានពលីនៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២៥ ប៉ុន្តែរហូតដល់ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ ២០២៥ ទើបក្រុមជួយសង្គ្រោះអាចយកសាកសពចេញពីសមរភូមិមកធ្វើបុណ្យតាមប្រពៃណីសាសនា។ លោក ថន ធី បានឱ្យដឹងថា ពេលទទួលដំណឹងថាកូនប្រុសបានពលីនៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២៥ភ្លាម ក្រុមគ្រួសារខ្ញុំ និងក្រុមគ្រួសារវីរកងទ័ព៧ នាក់ទៀតបានមកជួបជុំគ្នាដើម្បីចូលរួមជាមួយរដ្ឋបាលខេត្តបន្ទាយមានជ័យរៀបចំធ្វើបុណ្យសពតាមប្រពៃណីសាសនា ឧទ្ទិសកុសលផលបុណ្យរួមគ្នា នៅវត្តចម្ការខ្នុរ ក្រុងសេរីសោភ័ណ ខេត្តបន្ទាយមានជ័យ ដោយពុំទាន់មានសាកសពនៅឡើយ។ លុះដល់ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២៥ ទើបក្រុមការងារជួយសង្គ្រោះអាចយកសាកសពវីរកងទ័ពមកប្រគល់ឱ្យក្រុមគ្រួសារ ពេលនោះសាកសពមានសភាពហើមខ្លាំងពីព្រោះបានពលីរយៈពេល៧ថ្ងៃមកហើយ។ សាកសពរបស់វីរកងទ័ព ថន ពិទិ ត្រូវបានគ្រួសារយកទៅធ្វើបុណ្យសពតាមប្រពៃណីសាសនាម្តងទៀតនៅវត្តស្វាយចាស់ ក្នុងក្រុងសេរីសោភ័ណ ខេត្តបន្ទាយមានជ័យ។

ទោះបីជាការពលីជីវិតរបស់វីរកងទ័ព ថន ពិទិ បានបន្សល់ទុកនូវភាពសោកសៅ និងការឈឺចាប់យ៉ាងខ្លាំងក្រៃលែងសម្រាប់ឪពុកម្តាយ និងក្រុមគ្រួសារ ប៉ុន្តែស្នាដៃ គុណបំណាច់ និងការលះបង់ដ៏ធំធេងរបស់ ថន ពិទិ ក្នុងនាមជាវីរកងទ័ពដ៏ក្លាហានរបស់កម្ពុជា គឺស្ថិតនៅជាប់ក្នុងក្រឡបេះដូងរបស់ប្រជាជនកម្ពុជាគ្រប់រូបជាដរាប។ ការបូជាសាច់ស្រស់ឈាមស្រស់របស់ វីរកងទ័ព ថន ពិទិ សម្រាប់ការពារបូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជាយើង គឺជាការលះបង់មិនអាចកាត់ថ្លៃបាន។



ថន ពិទិ អាយុ២៦ឆ្នាំ រស់នៅភូមិសង្កែ ឃុំបឹងបេង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ។ ពិទិ បានពលីជីវិតនៅសមរភូមិបឹងត្រកួន នៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២៥។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# វីរកងទ័ព ខ្លាំ សុផល

## ពលីជីវិតដោយសារយន្តហោះចម្បាំង F-16 នៅសមរភូមិប្រាសាទតាមាន់

***រឹម ពេជ្រដារ៉ូ***

*នៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២៥ វីរកងទ័ព ខ្លាំ សុផល បានពលីជីវិតដោយសារយន្តហោះចម្បាំង F-16 របស់សត្រូវឈ្លានពានទឹកដីថៃទម្លាក់គ្រាប់បែកចំលេណដ្ឋានបណ្ដាលឱ្យបាក់សន្លត់នៅសមរភូមិតំបន់ប្រាសាទតាមាន់។ លោក ឃឿយ ខ្លាំ ត្រូវជាឪពុកបច្ចុប្បន្នរស់នៅភូមិត្រពាំងធំ ឃុំរើល ស្រុកពួក ខេត្តសៀមរាប បានរៀបរាប់រឿងរ៉ាវកូនប្រុសរបស់ខ្លួនអំឡុងពេលសង្គ្រាមរវាងកម្ពុជា-ថៃ ក្នុងឆ្នាំ២០២៥ ដូចខាងក្រោម ៖*

*ខ្ញុំឈ្មោះ ឃឿយ ខ្លាំ អាយុ៤៩ឆ្នាំ មានប្រពន្ធឈ្មោះ ប៉ូយ ត្រឹប អាយុ៤៩ឆ្នាំ។ ខ្ញុំ និងប្រពន្ធមានកូនចំនួន៧ នាក់ គឺប្រុស៤នាក់ និងស្រី៣នាក់ ហើយ ខ្លាំ សុផល អាយុ២៨ឆ្នាំ គឺជាកូនទី៣នៅក្នុងគ្រួសារ។*

*តាំងពីកុមារ សុផល គឺជាក្មេងស្លូតបូត និងចេះគោរពចាស់ទុំ។ សុផល បានចូលរៀននៅសាលាបឋមសិក្សាត្រពាំងធំ និងឈប់រៀនត្រឹមថ្នាក់ទី៧ នៅអនុវិទ្យាល័យរើលក្នុងខេត្តសៀមរាប។ សុផល បានសម្រេចចិត្តបោះបង់ការសិក្សាដោយសារជីវភាពគ្រួសារមានការខ្វះខាត។*

*នៅឆ្នាំ២០១៣ សុផល បានចូលបម្រើក្នុងជួរកងទ័ពនៅខេត្តសៀមរាប។ បន្ទាប់មកថ្នាក់ដឹកនាំកងខេមរភូមិន្ទបានបញ្ជូន សុផល ទៅហ្វឹកហាត់យុទ្ធសាស្ត្រកងទ័ពនៅសាលាពលទាហានទី៤ក្នុងស្រុកបន្ទាយស្រី ខេត្តសៀមរាប។ ក្រោយពីបញ្ចប់ការហ្វឹកហ្វឺន ថ្នាក់ដឹកកងទ័ពបានបញ្ជូល សុផល ទៅក្នុងអង្គភាពកងវរសេនាតូចអន្តរាគមន៍លេខ២៨១នៃ*



*វីរកងទ័ព ខ្លាំ សុផល ពលីជីវិតដោយសារយន្តហោះចម្បាំង F-16 របស់ទាហានថៃទម្លាក់គ្រាប់បែកចំលេណដ្ឋានបណ្ដាលឱ្យបាក់សន្លត់នៅសមរភូមិតំបន់ប្រាសាទតាមាន់ ក្នុងថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២៥។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

*កងពលតូចអន្តរាគមន៍លេខ១៤ ចំណុះកងពលធំអន្តរាគមន៍លេខ១២ ប្រចាំការនៅស្រុកបន្ទាយអំពិល ខេត្តឧត្ដរមានជ័យ។ អង្គភាពរបស់ សុផល បានឈរជើងនៅតំបន់ប្រាសាទតាមាន់ ក្នុងស្រុកបន្ទាយអំពិល។*

*នៅព្រឹកថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២៥ ទាហានថៃបានបាញ់សម្លាប់កងទ័ពកម្ពុជាម្នាក់ដែលគ្មានអាវុធស្លាប់នៅក្បែរលេណដ្ឋាននៅក្នុងភូមិសាស្ត្រមុំបី ខេត្តព្រះវិហារ ធ្វើឱ្យស្ថានការណ៍នៅតាមបណ្ដោយព្រំដែនកម្ពុជា-ថៃមានភាពតានតឹងកាន់តែខ្លាំង។ ខ្ញុំ និងក្រុមគ្រួសារចាប់ផ្ដើមព្រួយបារម្ភពីសុវត្ថិភាព*

សុផល និងបានធ្វើដំណើរចេញពីខេត្តសៀមរាបឆ្ពោះទៅកាន់ស្រុកបន្ទាយអំពិលខេត្តឧត្តរមានជ័យ ដើម្បីទៅសួរសុខទុក្ខកូនប្រុសដែលកំពុងប្រចាំការនៅខ្សែត្រៀមជួរមុខតំបន់ប្រាសាទតាមាន់ជាញឹកញាប់។ ខ្ញុំបានណែនាំកូនអំពីកន្លែងដែលមានសុវត្ថិភាព និងកន្លែងដែលគ្មានសុវត្ថិភាព ព្រោះខ្លាចកូនមានគ្រោះថ្នាក់ដល់ជីវិត។ ខ្ញុំធ្លាប់ជាអតីតកងទ័ពប្រយុទ្ធលើសមរភូមិ ខ្ញុំបានដឹងពីគោលដៅរបស់សត្រូវខ្លះៗ គឺជារឿយៗផ្តោងដាក់យើងចំពីមុខ និងពីចំហៀង។ មុនពេលផ្ទុះអាវុធ ខ្ញុំបានទំនាក់ទំនងទៅ សុផល ជាញឹកញាប់ និងបានសួរនាំអំពីទីតាំងដែល សុផល កំពុងឈរជើង តើមានសុវត្ថិភាពដែរឬទេ ការហូបចុកគ្រប់គ្រាន់ទេ ហើយស្ថានការណ៍នៅទីនោះយ៉ាងដូចម្តេច។

នៅពេលផ្ទុះអាវុធរវាងកម្ពុជា-ថៃលើកទី១ នៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២៥ ខ្ញុំកាន់តែមានការព្រួយបារម្ភពី សុផល ថែមទៀត។ ពេលផ្ទុះសង្គ្រាមភ្លាមៗខ្ញុំនិង សុផល បានដាច់ការទំនាក់ទំនង ធ្វើឱ្យខ្ញុំមិនស្រណុកក្នុងចិត្ត ព្រោះព្រួយបារម្ភអំពីសុខសុវត្ថិភាពរបស់កូនជាប់ជានិច្ច។ ពេលនោះ សុផល មិនហ៊ានបើកទូរសព្ទទេតាំងពីចាប់ផ្តើមផ្ទុះអាវុធ ព្រោះមេបញ្ជាការរបស់ សុផល ហាមមិនឱ្យបើកទូរសព្ទខ្លាចមានគ្រោះថ្នាក់។

នៅពេលមានបទឈប់បាញ់វេលាម៉ោង១២:០០ រំលងអាធ្រាតនៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៥ ទើប សុផល ទាក់ទងមកខ្ញុំ។ រយៈពេល៤ទៅ៥ថ្ងៃក្រោយមក សុផល បានសុំច្បាប់មេបញ្ជាការមកលេងគ្រួសារនៅឯខេត្តសៀមរាបរយៈពេល៣ថ្ងៃ ដើម្បីមកជួបមុខឪពុកម្តាយ បងប្អូន និងយាយដែលចាស់ជរាទន្ទឹងរង់ចាំមើលផ្លូវចៅ។ ពេលនោះ សុផល បានរៀបរាប់ទុក្ខលំបាករបស់ខ្លួនអំឡុងពេលសង្គ្រាម គឺមិនបានហូបបាយទឹកអស់រយៈ៤ទៅ៥ថ្ងៃ ទម្រាំបទឈប់បាញ់ចូលជាធរមាន។ ពេលខ្ញុំ និងក្រុមគ្រួសារស្តាប់ពូ សុផល រៀបរាប់ពីទុក្ខលំបាកធ្វើឱ្យខ្ញុំដែលជាឪពុកមានអារម្មណ៍ក្តុកក្តួល និងអាណិតស្រណោះកូនដែលហ៊ានលះបង់គ្រប់សព្វបែបយ៉ាងដើម្បីជាតិមាតុភូមិ។

មុនផ្ទុះសង្គ្រាមលើកទី២ចំនួនមួយថ្ងៃ គឺនៅថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២៥ សុផល បានទំនាក់ទំនងមកខ្ញុំ ព្រមទាំងប្រាប់ពីស្ថានភាពនៅកន្លែងដែលគាត់ឈរជើងថា ពុកអើយ! សភាពការណ៍នៅកន្លែងខ្ញុំឈរជើងអត់ស្រួលទៀតហើយពុក ខ្ញុំមិនអាចទូរសព្ទទៅពុកបានទៀតទេ ខ្ញុំបិទទូរសព្ទហើយ។ លុះដល់ស្អែកឡើងនៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២៥ សង្គ្រាមចាប់ផ្តើមផ្ទុះឡើងជាលើកទី២ សុផល មិនហ៊ានហៅទូរសព្ទមកគ្រួសារទេ ព្រោះកងទ័ពទាំងអស់ត្រូវបិទទូរសព្ទ គឺមានតែតេអូរតែប៉ុណ្ណោះសម្រាប់ទំនាក់ទំនងនៅក្នុងអង្គភាពកងទ័ព។ ចាប់តាំងពីពេលនោះមក ខ្ញុំមិនហ៊ានហៅទូរសព្ទទៅ សុផល ទៀតទេ ព្រោះគិតពីសុខសុវត្ថិភាពរបស់កូនដែលកំពុងប្រយុទ្ធតទល់ជាមួយ




វីរកងទ័ព ខ្នាំ សុផល ពលីជីវិតដោយសារយន្តហោះចម្បាំង F-16 របស់ទាហានថៃទម្លាក់គ្រាប់បែកចំលេណដ្ឋានបណ្តាលឱ្យបាក់សត្តត់នៅសមរភូមិតំបន់ប្រាសាទតាមាន់ ក្នុងថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២៥។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

សត្រូវឈ្លានពានថៃ។

នៅវេលាប្រហែលម៉ោង១១យប់ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២៥ មិត្តរួមអាវុធរបស់ សុផល ដែលទើបនឹងដកមកខាងក្រោយបានទំនាក់ទំនងមកខ្ញុំ និងក្រុមគ្រួសារថា សុផល បានពលីជីវិតនៅក្នុងលេណដ្ឋានដោយសារយន្តហោះចម្បាំង F-16 របស់សត្រូវទម្លាក់គ្រាប់បែកត្រូវចំលេណដ្ឋានបណ្តាលឱ្យបាក់សន្លុតពីលើ។ នៅពេលទទួលដំណឹងថាកូនប្រុសបានពលីនៅសមរភូមិ ខ្ញុំនិងប្រពន្ធពិបាកទទួលយកខ្លាំងណាស់។ ខ្ញុំ និងប្រពន្ធនឹកស្រណោះ និងសោកស្តាយកូនជាពន់ពេក។ ពេលនោះសាកសព សុផល មិនអាចយកចេញពីក្នុងលេណដ្ឋានបានទេ។ ក្រុមគ្រួសារខ្ញុំបានរៀបចំពិធីបុណ្យឧទ្ទិសកុសលដល់ សុផល តាមប្រពៃណីសាសនាដោយគ្មានសាកសពកូន។

នៅក្នុងពិធីបុណ្យសព សុផល មានមន្ត្រីជាន់ខ្ពស់រាជរដ្ឋាភិបាលកម្ពុជា ញាតិមិត្ត និងប្រជាជនមកចូលរួមរំលែកទុក្ខជាមួយក្រុមគ្រួសារខ្ញុំយ៉ាងច្រើនកុះករ។ បន្ទាប់មកលោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី ហ៊ុន ម៉ាណែត បានឧបត្ថម្ភផ្ទះមួយខ្នងដល់ក្រុមគ្រួសារខ្ញុំស្នាក់នៅឱ្យបានសមរម្យ។

នៅថ្ងៃទី៥ ខែមេសា ឆ្នាំ២០២៦ កន្លងទៅ អង្គភាពកងពលធំអន្តរាគមន៍លេខ២បានទំនាក់ទំនងមកខ្ញុំ និងគ្រួសារ ថាសាកសពកូនប្រុសខ្ញុំឈ្មោះ ខ្វាំ សុផល ត្រូវបានយកចេញពីលេណដ្ឋាន និងបញ្ជូនទៅតម្កល់ទុកនៅវត្តពងទឹក ក្នុងស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ។ ពេលទទួលបានដំណឹងនេះភ្លាម ខ្ញុំនិងក្រុមគ្រួសារបានធ្វើដំណើរចេញពីខេត្តសៀមរាបឆ្ពោះទៅវត្តពងទឹក ខេត្តឧត្តរមានជ័យ ដើម្បីរៀបចំធ្វើបុណ្យសពកូនប្រុសខ្ញុំតាមប្រពៃណីសាសនាម្តងទៀត។ ពេលចប់កម្មវិធីបុណ្យសព ខ្ញុំនិងគ្រួសារបាននាំយកអដ្ឋិធាតុកូនប្រុសមកទុកនៅផ្ទះក្នុងភូមិត្រពាំងធំ ឃុំរើល ស្រុកពួក ខេត្តសៀមរាប ជាទីដែលកូនប្រុសខ្ញុំធ្លាប់រស់នៅ និងធំធាត់ឡើង។



វីរកងទ័ព ខ្វាំ សុផល ពលីជីវិតដោយសារយន្តហោះចម្បាំង F-16 របស់ទាហានថៃទម្លាក់គ្រាប់បែកចំលេណដ្ឋានបណ្តាលឱ្យបាក់សន្លុតនៅសមរភូមិតំបន់ប្រាសាទតាមាន់ ក្នុងថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២៥។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# យិន សុធារី ៖ ប្រជាជនភៀសសឹកនៅវត្តប្រម៉ោយ

**មឿន ស្រីណុច**



យិន សុធារី ស្នាក់នៅមណ្ឌលជនភៀសសឹក ស្ថិតនៅក្នុងឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ក្រោយកិច្ចព្រមព្រៀងស្ដីពីបទឈប់បាញ់ក្នុងថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៥ ប្រជាជនដែលមានលំនៅតាមបណ្ដោយព្រំដែនថ្មដាជាច្រើនគ្រួសារ នៅមិនទាន់អាចវិលត្រឡប់ទៅផ្ទះសម្បែងរបស់ខ្លួនវិញទេ។ ប្រជាជនទាំងអស់បានស្នាក់នៅបណ្ដោះអាសន្ននៅក្នុងមណ្ឌលជនភៀសសឹក ស្ថិតនៅក្នុងឃុំប្រម៉ោយ អស់រយៈពេលជាច្រើនខែដោយសារផ្ទះនៅជាប់ព្រំដែនថ្មដា ត្រូវទាហានថៃរំលោភបំពានរាយលួសបន្លា និងដាក់ទូកុងតឺន័រ។ អ្នកស្រី យិន សុធារី មានផ្ទះនៅជាប់ព្រំដែនថ្មដា និងជាប្រជាជនភៀសសឹកបានរៀបរាប់ដូចខាងក្រោម៖

ខ្ញុំឈ្មោះ យិន សុធារី ភេទស្រី អាយុ៥៨ឆ្នាំ កើតនៅក្នុងភូមិត្នោតពង សង្កាត់ចោមចៅ ខណ្ឌដង្កោ ខេត្តកណ្ដាល (បច្ចុប្បន្នរាជធានីភ្នំពេញ)។ សព្វថ្ងៃខ្ញុំរស់នៅក្នុងភូមិសង្កមថ្មី ឃុំថ្មដា ស្រុកវាលវែង ខេត្តពោធិ៍សាត់។ ខ្ញុំមានឪពុកឈ្មោះយិនពៅ (ស្លាប់) និងម្ដាយឈ្មោះ ប្រាក់ សាវឿន អាយុ៨០ឆ្នាំ សព្វថ្ងៃរស់នៅខេត្តកំពង់ចាម។ ខ្ញុំមានបងប្អូនបង្កើតចំនួន ៦នាក់ គឺស្រី២នាក់ និងប្រុស៤នាក់ ហើយខ្ញុំគឺជាកូនច្បងនៅក្នុងគ្រួសារ។ បងប្អូនរបស់ខ្ញុំនៅរស់រានមានជីវិតចំនួន៤នាក់ និងបានស្លាប់ចំនួន២នាក់។

ខ្ញុំមានប្ដីឈ្មោះ សយ ស៊ីណា អាយុ៦៦ឆ្នាំ និងជាអតីតកងទ័ពក្នុងអង្គភាពការពារព្រំដែនគោកលេខ៥០១នៅថ្មដា។ ប្ដីរបស់ខ្ញុំមានស្រុកកំណើតនៅស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម។ ខ្ញុំមានកូនចំនួន៦នាក់គឺស្រីម្នាក់ និងប្រុស៥នាក់ ហើយកូនប្រុសទីពីររបស់ខ្ញុំឈ្មោះ សយ មិនា គឺជាកងទ័ពក្នុងកងកាំភ្លើងធំ។ សព្វថ្ងៃកូនប្រុសរបស់ខ្ញុំកំពុងជាប់ហាត់ហ្វឹកហាត់នៅខេត្តកំពង់ឆ្នាំង។

នៅឆ្នាំ១៩៩៩ ប្ដីរបស់ខ្ញុំត្រូវបានរាជរដ្ឋាភិបាលបញ្ជូនមកនៅកងការពារព្រំដែនគោកលេខ៥០១ ឃុំថ្មដា ស្រុកវាលវែង ខេត្តពោធិ៍សាត់។ បន្ទាប់មក ខ្ញុំបាននាំកូនៗចាកចេញពីទីក្រុងភ្នំពេញមករស់នៅជាមួយប្ដីនៅឃុំថ្មដា ខេត្តពោធិ៍សាត់។ ខ្ញុំ និងប្ដីបានសាងសង់ផ្ទះនៅក្នុងភូមិសង្គមថ្មី ឃុំថ្មដា ស្ថិតក្បែរបន្ទាយកងទ័ពកម្ពុជានៅព្រំដែនថ្មដា។ ដំបូងខ្ញុំមិនមានមុខរបរទេ។ ខ្ញុំនិងកូនៗរស់នៅ ហូបរបបអង្កររបស់កងទ័ព។ បន្ទាប់មក ខ្ញុំបានប្រកបមុខរលក់ដូរអីវ៉ាន់ចាប់ហួយ នៅខាងមុខផ្ទះ ស្ថិតនៅខាងមុខប៉ុស្ដិ៍នគរបាលការពារព្រំដែនគោក ចំណែកបន្ទាយកងទ័ពកម្ពុជានៅខាងក្រោយផ្ទះ។ មុនពេលមានការផ្ទុះអាវុធរវាងកងទ័ពកម្ពុជា និងទាហានថៃ ខ្ញុំប្រកបមុខរបររកស៊ីធម្មតា។ នៅព្រំដែនថ្មដាសម្បូរភ្ញៀវទេសចរមកកម្សាន្តជាហូរហែស្ទើររាល់ថ្ងៃ។

នៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២៥ ទាហានថៃបានចាប់ផ្ដើមបាញ់ផ្សែងពុល និងប្រើយន្តហោះគ្មានមនុស្សបើក (ដ្រូន) ហោះមកក្រវែលពាសពេញក្នុងឃុំថ្មដា ទាំងយប់ទាំងថ្ងៃ។ ខ្ញុំ និងកូនៗមានការភិតភ័យ និងព្រួយបារម្ភយ៉ាងខ្លាំង។ បន្ទាប់មក ខ្ញុំ និងក្រុមគ្រួសារត្រូវបានអាជ្ញាធរឃុំជម្លៀសចេញពីភូមិសង្គមថ្មី ឃុំថ្មដា មកកាន់វត្តប្រម៉ោយ ស្ថិតក្នុងភូមិប្រម៉ោយ ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់ ដើម្បីរក្សាសុវត្ថិភាព។ នៅពេលខ្ញុំមកដល់វត្ត ខ្ញុំឃើញប្រជាជនដែលរស់នៅក្នុងឃុំថ្មដាបានជម្លៀសមកកាន់ឃុំប្រម៉ោយជាបន្តបន្ទាប់ដែរ។

នៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២៥ ខ្ញុំទទួលដំណឹងថា ទាហានថៃបានផ្លោងកាំភ្លើងធំចូលតំបន់អូរក្រុកដំរី ស្ថិតក្នុងភូមិឯកភាព ឃុំថ្មដា ស្រុកវាលវែង ខេត្តពោធិ៍សាត់។ បន្ទាប់ពីឮដំណឹងនេះ ខ្ញុំមានការព្រួយបារម្ភពីផ្ទះ និងរបស់របរនៅក្នុងផ្ទះខ្ញុំ ព្រោះខ្លាចមានការផ្ទុះអាវុធកាន់តែខ្លាំង។ ខ្ញុំបានស្នាក់នៅក្នុងវត្តប្រម៉ោយអស់រយៈពេល១សប្ដាហ៍ ទើបត្រឡប់ទៅរស់នៅក្នុងផ្ទះនៅភូមិសង្គមថ្មីវិញ។

នៅខែសីហា ឆ្នាំ២០២៥ ក្រុមគ្រួសាររបស់ខ្ញុំ និងប្រជាជនមួយចំនួនក្នុងភូមិសង្គមថ្មី បានភៀសខ្លួនមកកាន់វត្តប្រម៉ោយជាលើកទី២ ព្រោះឮថាសភាពការណ៍នៅតាមព្រំដែនថ្មដាមានការតានតឹង និងមិនសូវមានសុវត្ថិភាពទេ។ ខ្ញុំបានស្នាក់នៅក្នុងវត្តប្រម៉ោយអស់រយៈពេលប្រហែល៣ថ្ងៃ រហូតស្ថានការណ៍នៅព្រំដែនស្ងប់ស្ងាត់ ទើបខ្ញុំ និងក្រុមគ្រួសារបានវិលទៅកាន់ភូមិសង្គមថ្មីវិញ។

នៅថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២៥ ទាហានថៃចាប់ផ្ដើមបាញ់មកលើទីតាំងឈរជើងរបស់កងទ័ពកម្ពុជានៅខេត្តឧត្ដរមានជ័យ ខេត្តព្រះវិហារ និងខេត្តបន្ទាយមានជ័យ។ នៅព្រំដែនថ្មដា ទាហានថៃមិនទាន់ផ្លោងគ្រាប់ចូល និងមានការផ្ទុះអាវុធទេ ប៉ុន្តែទាហានថៃចាប់ផ្ដើមបាញ់ផ្សែងពុល និងប្រើយន្តហោះគ្មានមនុស្សបើក (ដ្រូន) ហោះចូលក្នុងភូមិសាស្ត្រឃុំថ្មដាធ្វើឱ្យខ្ញុំមានការព្រួយបារម្ភ និងភ័យខ្លាចទាហានថៃទម្លាក់គ្រាប់បែក។ ក្នុងពេលជាមួយគ្នា ខ្ញុំចាប់ផ្ដើមគិតភ្លាមថា អាចនឹងផ្ទុះសង្គ្រាមនៅព្រំដែនថ្មដាម្ដងទៀតជាមិនខាន។ មិនយូរប៉ុន្មាន ប្រជាជននៅក្នុងឃុំថ្មដាបានចាប់ផ្ដើមភៀសខ្លួនចេញពីផ្ទះសម្បែងទៅកាន់ទីកន្លែងមានសុវត្ថិភាពជាបន្តបន្ទាប់។ ដោយឡែក ខ្ញុំ និងប្ដីនៅតែព្រួយបារម្ភពីផ្ទះសម្បែង ទើបខ្ញុំ និងប្ដីមិនទាន់ភៀសខ្លួនចេញពីថ្មដា។ នៅពេលនោះ ខ្ញុំ និងប្ដីត្រូវផ្សែងពុលរបស់ទាហានថៃស្ទើរតែបាត់បង់ជីវិតនៅព្រំដែនថ្មដា។ បន្ទាប់ពីត្រូវផ្សែងពុល ខ្ញុំ និងប្ដី មានអាការពិបាកដកដង្ហើមខ្លាំងណាស់ ពីព្រោះខ្ញុំមិនបានដឹងថាខ្លួនឯងត្រូវផ្សែងពុលរបស់ទាហានថៃទេ។ កូនៗរបស់ខ្ញុំបានទូរសព្ទប្រាប់ខ្ញុំ និងប្ដីត្រូវតែភៀសខ្លួនចេញពីថ្មដាជាបន្ទាន់ ដោយសារកូនខ្ញុំឃើញតាមរយៈសារព័ត៌មានផ្សាយថា ទាហានថៃបន្តបាញ់ផ្សែងពុលជាបន្តបន្ទាប់

ក្នុងភូមិសាស្ត្រឃុំថ្មដា។ ក្រោយមក ខ្ញុំ និងប្ដីបានភៀសខ្លួនទៅកាន់ជំរំភៀសសឹកនៅភូមិប្រម៉ោយ ឃុំប្រម៉ោយដោយសុវត្ថិភាព។ អំឡុងពេលស្នាក់នៅជំរំជនភៀសសឹក ខ្ញុំបានទទួលដំណឹងថា ទាហានថៃបានផ្លោងគ្រាប់កាំភ្លើងធំចូលបន្ទាយកងទ័ពកម្ពុជានៅភូមិសង្គមថ្មី។ ពុដូច្នេះ ខ្ញុំពុំមានអារម្មណ៍សប្បាយចិត្តទេ។ ខ្ញុំមានការព្រួយបារម្ភពីទ្រព្យសម្បត្តិក្នុងផ្ទះរបស់ខ្ញុំនៅភូមិសង្គមថ្មី និងខ្លាចទាហានថៃនៅតែបន្តសង្គ្រាមកាន់តែធំឡើងបន្តទៀត។

អំឡុងពេលសង្គ្រាមផ្ទុះឡើងពីថ្ងៃទី៧ ដល់ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៥ ខ្ញុំបានដឹងតាមរយៈប្រជាជនប្រាប់ថា ផ្ទះចម្ការរបស់ខ្ញុំនៅបាតស្ទឹងក្នុងភូមិសង្គមថ្មីត្រូវបានភ្លើងឆាបឆេះអស់ ហើយភ្លើងបានរីករាលដាលឆាបឆេះដល់ដំណាំនៅក្នុងចម្ការរបស់ខ្ញុំស្ទើរតែទាំងស្រុង។ ខ្ញុំមិនបានដឹងពីមូលហេតុដែលបណ្ដាលឱ្យមានភ្លើងឆេះនោះទេ។ ផ្ទះរបស់ខ្ញុំនៅខាងលើមាត់ស្ទឹងដែលមានលក់ដូរអីវ៉ាន់ចាប់ហួយ និងទ្រព្យសម្បត្តិផ្សេងៗត្រូវបានចោរចូលគាស់ រួចចូល លួចរបស់របរទាំងអស់មិនមានអ្វីនៅសេសសល់ទៀតទេ។ បន្ទាប់ពីស្ងាត់សង្គ្រាមរវាងកងទ័ពកម្ពុជា និងទាហានថៃខ្ញុំបានធ្វើដំណើរឡើងទៅមើលផ្ទះក្នុងភូមិសង្គមថ្មី។ នៅពេលខ្ញុំទៅដល់ផ្ទះភ្លាម ខ្ញុំសោកស្ដាយយ៉ាងខ្លាំងព្រោះឃើញផ្ទះត្រូវគេគាស់បំផ្លាញ។ ខ្ញុំមានអារម្មណ៍សោកសៅ និងនិយាយមិនចេញឡើយ។ នៅក្នុងផ្ទះរបស់ខ្ញុំត្រូវបានគេគាស់បំផ្លាញខ្ទេចខ្ទីមិនមានរបស់របរ អីវ៉ាន់ និងទ្រព្យសម្បត្តិនៅសេសសល់ឡើយ។ ខ្ញុំបានត្រឡប់មកជំរំភៀសសឹកវិញ ទាំងអារម្មណ៍ក្ដុកក្ដួល មិនដឹងថាត្រូវរស់នៅបែបណាតទៅទៀត។ ប៉ុន្តែខ្ញុំនៅមានកូន និងប្ដីចាំលើកទឹកចិត្ត ហើយព្យាយាមគិតថា ខ្ញុំត្រូវតែបន្តដើរទៅមុខ រួចចាប់ផ្ដើមកសាងជីវិតសាឡើងវិញម្ដងទៀត។ រាល់ថ្ងៃខ្ញុំ និងប្ដី ខិតខំធ្វើការងារខ្លាំងណាស់ ដើម្បីឱ្យកូនៗជាទីស្រឡាញ់បានសិក្សារៀនសូត្រ និងគ្រួសាររស់នៅមានសុភមង្គល។ ខ្ញុំ និងប្ដីបានព្យាយាមស្វែករកការងារគ្រប់ទិសទី។

ខ្ញុំបានស្នាក់នៅជំរំភៀសសឹកអស់រយៈពេលជាច្រើនខែក្នុងឃុំប្រម៉ោយ។ ខ្ញុំបានត្រឡប់ទៅមើលផ្ទះ៣ទៅ៤ដង ប៉ុន្តែខ្ញុំមិនហ៊ានស្នាក់នៅផ្ទះ និងមិនហ៊ាននៅផ្ទះយូរទេ។ ប្ដីរបស់ខ្ញុំបានទៅមើលផ្ទះសម្បែងញឹកញាប់ជាងខ្ញុំ។ រៀងរាល់ពេលខ្ញុំទៅអើតមើលផ្ទះ ខ្ញុំតែងតែត្រឡប់មកជំរំភៀសសឹកវិញភ្លាមៗ ព្រោះខ្ញុំនៅតែខ្លាចទាហានថៃបាញ់ផ្សែងពុលចូលមកទៀត។ រហូតមកដល់ពេលនេះ ប្រជាជនរស់នៅក្នុងភូមិកណ្ដាល ឃុំអន្លង់រាប ស្រុកវាលវែង ខេត្តពោធិ៍សាត់ មានការអាណិតស្រឡាញ់ខ្ញុំ និងប្ដី ហេតុនេះទើបអ្នកភូមិឱ្យប្ដីរបស់ខ្ញុំឡើងដើមត្នោត និងគាបយកទឹកត្នោតផ្អែម ទឹកត្នោតជូ និងធ្វើជាស្ករត្នោតយកទៅលក់បានប្រាក់ចំណូលសម្រាប់ផ្គត់ផ្គង់ថ្លៃសិក្សារៀនសូត្ររបស់កូនៗ និងជីវភាពរស់នៅប្រចាំថ្ងៃ។ កូនៗរបស់ខ្ញុំ២នាក់ ម្នាក់រៀនថ្នាក់ទី៨ និងម្នាក់ទៀតរៀនថ្នាក់ទី១២ នៃវិទ្យាល័យ ហ៊ុន សែន ប្រម៉ោយ។ កូនប្រុសទី៣ឈ្មោះ សយ មិនា កំពុងហ្វឹកហាត់ក្នុងកងកាំភ្លើងធំនៅខេត្តកំពង់ឆ្នាំង ហើយកូនត្រូវមានឈ្មោះបញ្ជូនទៅការពារនៅប្រកបឹងត្រកួន ស្ថិតក្នុងឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ក្នុងខែមីនា ឆ្នាំ២០២៦។

ខ្ញុំមានការព្រួយបារម្ភពីកូនប្រុសខ្លាំងណាស់ ប៉ុន្តែខ្ញុំនឹកគិតថា កូនមានឪពុកជាអតីតកងទ័ពដែលមានភាពអង់អាចក្លាហាន ប្រាកដណាស់កូនប្រុសនឹងមានសមត្ថភាព និងមានភាពក្លាហានដូចឪពុក ទើបខ្ញុំបានធូរស្បើយចិត្តវិញ។ ប្ដីរបស់ខ្ញុំតែងតែនិយាយថា ប្រសិនបើកូនប្រុសត្រូវបានបញ្ជូនមកការពារនៅព្រំដែនថ្មដា ប្ដីរបស់ខ្ញុំនឹងចូលរួមការពារទឹកដីជាមួយកងទ័ពកម្ពុជាវិញ ទោះបីជារូបគាត់បានចូលនិវត្តន៍ពីកងទ័ពហើយក្ដី ព្រោះប្ដីរបស់ខ្ញុំស្គាល់ទីតាំងភូមិសាស្ត្រថ្មដាយ៉ាងច្បាស់លាស់ និងអាចបង្ហាត់បង្ហាញប្រាប់គោលដៅដល់កងទ័ពក្មេងៗស្រករក្រោយអំពីទីតាំងទាំងអស់នោះបាន។

សព្វថ្ងៃខ្ញុំចង់ត្រឡប់ទៅរស់នៅផ្ទះវិញខ្លាំងណាស់ ប៉ុន្តែខ្ញុំនៅតែខ្លាចទាហានថៃ។ ខ្ញុំចង់ឱ្យរាជរដ្ឋាភិបាលដោះស្រាយបញ្ហាជម្លោះព្រំដែនជាមួយថៃឱ្យបានឆាប់រហ័ស និងមិនចង់ឱ្យកើតមានសង្គ្រាមឡើយ។

# ស្ត្រីមេម៉ាយ និងជាប្រជាជនភៀសសឹកនៃជម្លោះព្រំដែនកម្ពុជា-ថៃ ឆ្នាំ២០២៥

**មឿន ស្រីណុច**

ខ្ញុំឈ្មោះ ខែម សារី ភេទស្រី អាយុ៤៦ឆ្នាំ មានមុខរបរលក់ចាយ និងលក់ម្ហូបអាហារ។ ខ្ញុំមានស្រុកកំណើតនៅក្នុងភូមិស្ពានថ្ម ឃុំព្រៃញី ស្រុកសំពៅមាស ខេត្តពោធិ៍សាត់។ បច្ចុប្បន្នខ្ញុំរស់នៅក្នុងភូមិសង្គមថ្មី ឃុំថ្មដា ស្រុកវាលវែង ខេត្តពោធិ៍សាត់។ ខ្ញុំមានឪពុកឈ្មោះ ឃឹម ខែម (ស្លាប់) និងម្ដាយឈ្មោះ ស្វែង ភ័គ សព្វថ្ងៃរស់នៅខេត្តពោធិ៍សាត់។ ខ្ញុំមានបងប្អូនបង្កើតចំនួន៥នាក់ ហើយខ្ញុំគឺជាកូនទី២ក្នុងគ្រួសារ។ ខ្ញុំគឺជាស្ត្រីមេម៉ាយមានកូនចំនួន៤នាក់ គឺស្រី២នាក់ និងប្រុស២នាក់។

កាលនៅវ័យកុមារ ខ្ញុំបានចូលរៀននៅសាលាបឋមសិក្សាព្រែកស្ដី ខេត្តពោធិ៍សាត់ បានត្រឹមថ្នាក់ទី៣។ បន្ទាប់មក ខ្ញុំត្រូវបានឪពុកម្ដាយឱ្យឈប់រៀន ព្រោះគ្រួសារមានជីវភាពខ្វះខាត។ ខ្ញុំបានដើរបេះផ្លែឈើព្រៃយកទៅលក់នៅផ្សារពោធិ៍សាត់ដើម្បីជួយជីវភាពគ្រួសារប្រចាំថ្ងៃ ចំណែកឪពុកម្ដាយរបស់ខ្ញុំប្រកបរបរធ្វើស្រែចម្ការ។

នៅឆ្នាំ១៩៩៧ ប្ដីរបស់ខ្ញុំឈ្មោះ អ៊ីម ប៉ាន គឺជាមន្ត្រីនគរបាល ត្រូវបានមេបញ្ជូនឱ្យមកការពារនៅព្រំដែនថ្មដា ស្ថិតក្នុងស្រុកវាលវែង ខេត្តពោធិ៍សាត់។ នៅពេលនោះខ្ញុំកំពុងពពោះកូនទី១ ហេតុនេះប្ដីរបស់ខ្ញុំមិនទាន់ឱ្យខ្ញុំមករស់នៅព្រំដែនថ្មដាជាមួយគាត់ទេ ព្រោះនៅតាមព្រំដែនសម្បូរជំងឺគ្រុនចាញ់ និងមិនទាន់មានមន្ទីរពេទ្យសម្រាប់ព្យាបាលជំងឺនៅឡើយ។

នៅឆ្នាំ១៩៩៨ ខ្ញុំសម្រាលបានកូនប្រុសម្នាក់។ បន្ទាប់មក ខ្ញុំបានប្ដូរមករស់នៅជាមួយប្ដីនៅព្រំដែនថ្មដា ហើយខ្ញុំបានចាប់ផ្ដើមប្រកបមុខរបរលក់ដូរបន្តិច



ខែម សារី នៅជំរំភៀសសឹក ស្ថិតនៅក្នុងឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

បន្តួច ដើម្បីសន្សំលុយសង់ផ្ទះនៅថ្មដា។ កាលខ្ញុំមករស់នៅថ្មដាដំបូងមិនទាន់មានផ្លូវធ្វើដំណើរស្រួលនោះទេ គឺនៅពេលធ្វើដំណើរមានការលំបាក ព្រោះផ្លូវរអិល និងចំណាយពេលយូរ។ នៅឆ្នាំ២០០៨ ប្ដីរបស់ខ្ញុំបានទទួលមរណភាពដោយសារជំងឺ។

នៅមុនពេលមានការផ្ទុះអាវុធរវាងកងទ័ពកម្ពុជា និងទាហានថៃ ខ្ញុំ និងកូនៗបានប្រកបមុខរបរលក់បាយ លក់ម្ហូបអាហារ កាហ្វេ និងគ្រឿងភេសជ្ជៈផ្សេងៗទៀតនៅរង្វង់មូលប្រមុះជ្រូក ស្ថិតនៅក្នុងឃុំថ្មដា ស្រុកវាលវែង ខេត្តពោធិ៍សាត់។ កាលនោះខ្ញុំងាយស្រួលប្រកបមុខរបរចិញ្ចឹមជីវិត ព្រោះនៅ

ថ្មដាមានភាពអ៊ូអរ សុវត្ថិភាព សម្បូរមនុស្ស ភ្ញៀវទេសចរជនជាតិចិន និងកម្មករដែលបានមកធ្វើការងារសាងសង់អាគារ និងសង់ផ្លូវជាតិលេខ៥៥នៅព្រំដែនថ្មដា។ តំបន់ថ្មដា កំពុងស្ថិតនៅក្នុងការអភិវឌ្ឍន៍ដែលអាចឱ្យខ្ញុំលក់ដូរដាច់ និងស្វែងរកប្រាក់ចំណូលសម្រាប់ផ្គត់ផ្គង់ជីវភាពគ្រួសារប្រចាំថ្ងៃ។ ក្នុងមួយសប្តាហ៍ព្រំដែនខ្មែរ-ថៃ នៅច្រកអន្តរជាតិថ្មដា បើកឱ្យភ្ញៀវនិងប្រជាជនចេញចូលម្តង ហើយខ្ញុំឧស្សាហ៍ធ្វើដំណើរចូលទៅលេង និងទិញរបស់របរបន្តិចបន្តួចនៅផ្សាររណាត់ប្រទេសថៃ។ ប៉ុន្តែសម្រាប់បន្លែត្រី សាច់ និងសម្ភារលក់ដូរ ខ្ញុំបានទិញមកពីទីរួមខេត្តពោធិ៍សាត់។ ការរស់នៅប្រចាំថ្ងៃរបស់គ្រួសារខ្ញុំគឺមានភាពរីករាយ ហើយខ្ញុំសប្បាយចិត្តណាស់ដែលបានឃើញប្រជាជនខ្មែរមកពីគ្រប់ខេត្ត ក្រុងមានការងារធ្វើសម្រាប់ចិញ្ចឹមជីវិតខ្លួនឯង និងក្រុមគ្រួសារ។

នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៥ ស្ថានភាពនៅតាមខេត្តជាប់ព្រំដែននានាមិនល្អ ទើបខ្ញុំចាប់ផ្តើមរៀបចំសម្ភារចាំបាច់ និងរៀបចំអីវ៉ាន់រួចជាស្រេច ប៉ុន្តែខ្ញុំមិនទាន់ភៀសខ្លួនចេញពីថ្មដាភ្លាមទេ។ លុះដល់យប់ថ្ងៃដដែល ស្ថានភាពនៅព្រំដែនថ្មដាលែងមានសុវត្ថិភាព ទើបខ្ញុំនិងកូនចៅបានជួលរថយន្តមួយគ្រឿងធ្វើដំណើរចេញពីថ្មដាទៅស្នាក់នៅផ្ទះជន្ទួងស្ថិតនៅទីរួមខេត្តពោធិ៍សាត់។ ខ្ញុំស្នាក់នៅផ្ទះជន្ទួងអស់រយៈពេល១សប្តាហ៍ ទើបត្រឡប់មកផ្ទះនៅភូមិសង្គមថ្មីវិញ។ បន្ទាប់មក ខ្ញុំបានបើកតូបលក់បាយ ម្ហូបអាហារ កាហ្វេ និងភេសជ្ជៈជាធម្មតានៅរង្វង់មូលច្រមុះជ្រូកថ្មដា។ នៅពេលខ្ញុំមកដល់ដំបូង នៅថ្មដាមានសភាពស្ងប់ស្ងាត់ ព្រោះមិនទាន់មានប្រជាជន និងកម្មករហ៊ានត្រឡប់មកធ្វើការងារ និងរស់នៅតាមផ្ទះវិញនៅឡើយ។ មួយរយៈក្រោយមក ទើបប្រជាជនក្នុងឃុំថ្មដា និងកម្មករបាននាំគ្នាត្រឡប់មកធ្វើការងារដូចរាល់ដងវិញ។ ជនជាតិចិនបានចាប់ផ្តើមសាងសង់អគារបន្ត និងសម្បូរមនុស្សមករស់នៅដោយមិនមានការភ័យខ្លាចទេ។

នៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២៥ ទាហានថៃបានចាប់ផ្តើមផ្ទុះអាវុធមុននៅតាមព្រំដែនខេត្តឧត្តរមានជ័យ ខេត្តបន្ទាយមានជ័យ និងខេត្តព្រះវិហារ។ ចំណែកនៅព្រំដែនថ្មដាមានសភាពការណ៍តានតឹងដូចគ្នា ហើយអាជ្ញាធរភូមិឃុំបានប្រកាសប្រាប់ប្រជាជនឱ្យត្រៀមភៀសខ្លួនចេញពីឃុំថ្មដាម្តងទៀត។ បន្ទាប់មក ប្រជាជនមួយចំនួនធំបានភៀសខ្លួនចេញពីឃុំថ្មដា ទៅកាន់កន្លែងមានសុវត្ថិភាពនៅឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់។ ចំណែកខ្ញុំ និងកូនៗមិនទាន់បានភៀសខ្លួនទេ ព្រោះខ្ញុំនៅរង់ចាំកូនចំនួន២នាក់ ដែលកំពុងធ្វើការងារក្នុងសណ្ឋាគារនៅថ្មដា។

នៅវេលាម៉ោងប្រហែល៤ ទៀបភ្លឺថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២៥ ខ្ញុំនិងកូនៗបានដើរទៅជួលឡានចំនួនមួយគ្រឿងធ្វើដំណើរចេញពីថ្មដាមកកាន់ឃុំប្រម៉ោយភ្លាមៗ។ ក្នុងពេលធ្វើដំណើរចេញពីថ្មដា ទាហានថៃបានផ្លោងគ្រាប់ចូលតំបន់អូរភ្លុកដំរី និងបាញ់ចូលតំបន់ថ្មដា ដែលធ្វើឱ្យខ្ញុំ និងកូនចៅមានការភ័យខ្លាចខ្លាំងណាស់ ព្រោះគ្រាប់ផ្លោងរបស់ថៃបានហោះពីលើក្បាលរបស់ខ្ញុំ។ ខ្ញុំបានឃើញកម្មករសាងសង់អគារចិន និងប្រជាជនដែលធ្វើការងារក្នុងសណ្ឋាគារភៀសខ្លួនចេញទាំងភ័យស្លន់ស្លោ។ កម្មករខ្លះបានជិះម៉ូតូមួយគ្រឿងមានគ្នា៤ទៅ៥នាក់ ដើម្បីគេចខ្លួនឱ្យបានឆាប់រហ័សចេញពីឃុំថ្មដា ដែលមើលទៅពិតជាលំបាក និងគួរឱ្យអាណិតខ្លាំងណាស់។ ក្នុងពេលជាមួយគ្នានោះ ខ្ញុំនិងកូនៗយកតែសម្ភារចាំបាច់មួយចំនួនតែប៉ុណ្ណោះមកតាមខ្លួន។ ចំណែករបស់របរមានតម្លៃ ទ្រព្យសម្បត្តិ និងអីវ៉ាន់លក់ដូរទាំងអស់ត្រូវបានចាក់សោទុកនៅក្នុងតូប។

នៅអំឡុងខែមករា និងខែកុម្ភៈ ឆ្នាំ២០២៦ ខ្ញុំបានត្រឡប់ទៅមើលផ្ទះ និងតូបលក់ដូរនៅតំបន់ច្រមុះជ្រូកថ្មដា ប៉ុន្តែតូបរបស់ខ្ញុំ និងតូបរបស់កូនៗត្រូវបានទាហានថៃហ៊ុមព័ទ្ធបន្លាលួស ហើយទាហានថៃបានជញ្ជូនរបស់របរចេញពីតូបខ្ញុំ និងកូនៗស្ទើរតែទាំងអស់។ ខ្ញុំបានចូលទៅមើលផ្ទះនៅភូមិសង្គមថ្មីក្រែងលោមានផលប៉ះពាល់ពីសង្គ្រាម និងអាចឱ្យខ្ញុំចូលមកស្នាក់នៅក្នុងផ្ទះវិញបាន ប៉ុន្តែនៅពេលខ្ញុំបើកទ្វារ និងបង្អួចស្រាប់តែប្រទះឃើញទាហានថៃឈរត្រៀបត្រាដែលមានចម្ងាយប្រមាណ២០ម៉ែត្រពីផ្ទះរបស់ខ្ញុំ និងបាន

បែរកាំភ្លើងមកចំផ្ទះរបស់ខ្ញុំ រួមទាំងផ្ទះអ្នកភូមិផ្សេងទៀតរួចជាស្រេច។ ខ្ញុំមានអារម្មណ៍ភិតភ័យណាស់ និងព្រួយបារម្ភពីសុវត្ថិភាពខ្លួនឯង ព្រមទាំងកូនៗព្រោះខ្លាចមានការផ្ទុះអាវុធទៀត ដូច្នេះខ្ញុំមិនហ៊ានស្នាក់នៅផ្ទះទេ គឺបានត្រឹមតែទៅមើល រួចឆាប់ត្រឡប់មកមណ្ឌលភៀសសឹកវិញ។ បន្ទាប់មក កូនប្រុសច្បងរបស់ខ្ញុំបានត្រឡប់ទៅមើលរបស់របរនៅក្នុងតូបក្រែងលោមាននៅសេសសល់ ប៉ុន្តែកូនរបស់ខ្ញុំបានទូរសព្ទមកប្រាប់ខ្ញុំថា របស់របរបានបាត់អស់ហើយ។ ដំបូងឡើយ ខ្ញុំមានការបាក់ទឹកចិត្ត និងពិបាកចិត្តខ្លាំងណាស់ ព្រោះត្រូវបាត់បង់ទ្រព្យសម្បត្តិដែលខ្ញុំខិតខំសន្សំស្ទើរតែមួយជីវិត ដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារឱ្យមានភាពរីកចម្រើន និងដើម្បីចិញ្ចឹមបីបាច់កូនៗឱ្យបានរៀនសូត្រ។ ខ្ញុំបានបាត់បង់របស់របរជាច្រើនរួមមាន ម៉ាស៊ីនឆុងកាហ្វេ ធុងបាសចំនួន២ ម៉ាស៊ីនគាបសាំងវិច និងសម្ភារផ្សេងទៀត។

បច្ចុប្បន្នគ្រួសារខ្ញុំបន្តរស់នៅក្នុងជំរំភៀសសឹក ពីព្រោះមានសុវត្ថិភាពជាងស្នាក់នៅផ្ទះ។ ខ្ញុំមិនទាន់ហ៊ានទៅរស់នៅផ្ទះទេ ព្រោះខ្ញុំនៅតែមានការភ័យខ្លាច និងមិនទុកចិត្តទាហានថៃ។ អាជ្ញាធរឃុំ ស្រុក ខេត្ត និងសប្បុរសជននានានៅតែបន្តយកចិត្តទុកដាក់ជួយឧបត្ថម្ភ ផ្គត់ផ្គង់សម្ភារ ម្ហូបអាហារ ហូបចុកដល់ខ្ញុំ និងជួយសម្រួលដល់ជីវភាពរបស់គ្រួសារខ្ញុំ។ ខ្ញុំមានអារម្មណ៍ធូរស្បើយក្នុងចិត្តបន្តិច ព្រោះកូនខ្ញុំអាចបន្តរៀនសូត្រ និងមានគ្រូពេទ្យចាំជួយផ្តល់ថ្នាំ រួមទាំងមើលថែជាប្រចាំ។ ទោះបីខ្ញុំរស់នៅក្នុងមណ្ឌលជនភៀសសឹកមិនជួបការលំបាកខ្លាំង ប៉ុន្តែខ្ញុំចង់វិលត្រឡប់ទៅផ្ទះខ្លួនឯងវិញ។ ទីតាំងផ្ទះរបស់ខ្ញុំកំពុងស្ថិតនៅតំបន់ក្តៅ ហើយខ្ញុំមានការព្រួយបារម្ភខ្លាចត្រូវរត់ភៀសខ្លួនម្តងហើយម្តងទៀត។ ខ្ញុំតែងតែដេកគិតរាល់ថ្ងៃថា ថ្ងៃណាខ្ញុំវិលត្រឡប់ទៅផ្ទះ ខ្ញុំនឹងចាប់ផ្តើមបើកលក់ដូរវិញ។ ពេលនេះខ្ញុំមានតែបាតដៃទទេ ខ្ញុំបាត់បង់ទ្រព្យសម្បត្តិទាំងអស់ ប៉ុន្តែខ្ញុំនៅតែគិតថា ខ្ញុំនឹងអាចចាប់ផ្តើមជីវិតសាជាថ្មីម្តងទៀតនៅពេលស្រុកទេសបានសុខសាន្តត្រាណ។



*ជំរំប្រជាជនភៀសសឹកនៅក្នុងឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

# ខ្មែរក្រហមឈប់ឱ្យខ្ញុំបង្រៀនសិស្ស
## ដោយសារខ្ញុំយកបទចម្រៀងកាលពីសង្គមចាស់ មកច្រៀងលេង

ថុន ស្រីពៅ

ខ្ញុំឈ្មោះ សំ ទឹម អាយុ៧៥ឆ្នាំ រស់នៅភូមិតាកោ សង្កាត់តាកោ ក្រុងព្រៃវែង ខេត្តព្រៃវែង។ ខ្ញុំមានឪពុកឈ្មោះ សំ សឹម និងម្តាយឈ្មោះ ហ៊ិន មួន។ ខ្ញុំមានបងប្អូនចំនួន៩នាក់ គឺស្រី៧នាក់ និងប្រុស២នាក់ ប៉ុន្តែស្លាប់អស់ម្នាក់ដោយសារជំងឺសើស្បែក។

នៅឆ្នាំ១៩៦០ ខ្ញុំមានអាយុ៨ឆ្នាំ បានចូលរៀនដំបូងនៅសាលាវត្តតាកោ សង្កាត់តាកោ ក្រុងព្រៃវែង ខេត្តព្រៃវែង។ ក្រោយមក ដោយសារតែជីវភាពក្រីក្រលំបាក និងពុំមានអ្នកជួយធ្វើស្រែប្រាំងឪពុកម្តាយ ទើបខ្ញុំឈប់រៀននៅត្រឹមថ្នាក់ឧត្តមបឋម គឺថ្នាក់ទី៩ពីសង្គមចាស់។

នៅឆ្នាំ១៩៦៦ ខ្ញុំបានបួសជាព្រះសង្ឃនៅវត្តតាកោ។ ខ្ញុំបួសបានរយៈពេល៣ព្រះវស្សា ម្តាយខ្ញុំបានមកប្រាប់ខ្ញុំឱ្យសឹកដើម្បីទៅជួយធ្វើស្រែគាត់វិញ។ ប៉ុន្តែខ្ញុំមិនទាន់ទាំងបានជួយការងារគាត់ផង ស្រាប់តែធ្លាក់ខ្លួនឈឺមួយរយៈ។

នៅឆ្នាំ១៩៧០ ក្រោយមានរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ ខ្ញុំឃើញប្រជាជននៅខេត្តកំពង់ចាមធ្វើបាតុកម្មប្រឆាំងនឹងរដ្ឋប្រហារ។ បាតុករបាននាំគ្នាស្រែកថា ជយោ សម្តេចឪ នរណាមិនទៅកាប់ចោល។ ក្រោយមកទៀត ខ្ញុំឃើញមានការបំផុសបំផុលឱ្យប្រជាជននៅក្នុងភូមិចូលរួមបម្រើក្នុងជួរកងទ័ពជាមួយកងទ័ពវៀតកុង។ ដោយសារខ្ញុំចង់ឱ្យសម្តេចព្រះ នរោត្តម សីហនុវិលត្រឡប់មកសោយរាជ្យវិញ ទើបខ្ញុំរួមជាមួយមិត្តភក្តិចំនួន២នាក់ទៀតបានស្នើកងទ័ពរំដោះ ចូលធ្វើជាកងទ័ព ប៉ុន្តែកងទ័ពរំដោះបានប្រាប់ខ្ញុំឱ្យទៅសុំអង្គការថ្នាក់លើ ព្រោះថ្នាក់ស្រុក



សំ ទឹម អាយុ៧៥ឆ្នាំ រស់នៅភូមិតាកោ សង្កាត់តាកោ ក្រុងព្រៃវែង ខេត្តព្រៃវែង។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

មានកងទ័ពគ្រប់ចំនួនហើយ។ ដូច្នេះ ខ្ញុំបានវិលត្រឡប់មកផ្ទះវិញ។ ពេលនោះ ឪពុករបស់ខ្ញុំបានប្រាប់ខ្ញុំថា ប្រសិនជាខ្ញុំចង់ទៅធ្វើជាកងទ័ព គឺខ្ញុំបានធ្វើត្រឹមតែជាអ្នកយាមតែប៉ុណ្ណោះ។ នៅពេលខ្ញុំឮសម្តីឪពុករបស់ខ្ញុំនិយាយដូច្នេះ ខ្ញុំសម្រេចចិត្តឈប់ស្នើសុំជាកងទ័ព។ នៅឆ្នាំ១៩៧២ ខ្មែរក្រហមបានចាត់តាំងខ្ញុំឱ្យធ្វើជាគ្រូបង្រៀនកុមារនៅក្នុងភូមិ។

បន្ទាប់ពីខ្មែរក្រហមទទួលជ័យជម្នះ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមលែងឱ្យខ្ញុំធ្វើជាគ្រូបង្រៀនតទៅទៀត ដោយសារតែខ្ញុំយកបទចម្រៀងកាលពីសង្គមចាស់មកច្រៀង។ នៅអំឡុងពេលនោះ

ប្រធានឃុំបានហៅគ្រូៗទាំងអស់ទៅបង្ហឹកឱ្យចេះច្រៀងបទបដិវត្តន៍ជាច្រើនបទក្នុងគោលបំណងបំភ្លេចចោលនូវចម្រៀងកាលពីសង្គមចាស់ ហើយងាកមកច្រៀង និងបង្រៀនសិស្សឱ្យច្រៀងចម្រៀងបដិវត្តន៍ជំនួសវិញ។ ចំណែកខ្ញុំពេលសម្រាកពីម៉ោងបង្រៀន ហើយចេញទៅរែកដី ខ្ញុំចេះតែរអិលមាត់ច្រៀងចម្រៀងកាលពីសង្គមចាស់ ដែលជាហេតុធ្វើឱ្យអង្គការបញ្ឈប់ខ្ញុំ និងលែងឱ្យខ្ញុំធ្វើជាគ្រូបង្រៀនតទៅទៀត ព្រោះខ្លាចប៉ះពាល់ដល់ក្មេងជំនាន់ក្រោយ ខ្លាចក្មេងជំនាន់ក្រោយស្គាល់សង្គមចាស់ និងស្គាល់ការសប្បាយរីករាយ ភ្លេចអំពីការតស៊ូវាយរបប លន់ នល់។ លើសពីនេះ ខ្មែរក្រហមបានទិតៀនខ្ញុំថា នៅជាប់កម្ទេលចាស់មិនទាន់ដាច់ស្រឡះ។ ប៉ុន្តែទោះបីជាយ៉ាងនេះក្តី ខ្មែរក្រហមបានចាត់តាំងខ្ញុំឱ្យធ្វើជាប្រធាន- ខ។ តួនាទីជាប្រធាន- ខគឺខ្ញុំត្រូវដឹកនាំក្រុមម៉ែៗ ក្រុមបងស្រី និងក្រុមប្រុសៗ សរុបចំនួន២០នាក់ឱ្យធ្វើស្រែក្នុងភូមិ។ កាលនោះ ខ្ញុំមិនមានអាហារហូបឆ្អែតទេ ប៉ុន្តែខ្ញុំតស៊ូរស់រហូតមកដល់សព្វថ្ងៃ។ ជួនកាលក្នុងមួយថ្ងៃ ខ្ញុំហូបផ្លែចេកតែមួយផ្លែតែប៉ុណ្ណោះ។ ចំណែកឯការងារវិញ ខ្ញុំពុំដែលធ្វើឱ្យទាស់ចិត្តប្រធានកងឡើយ។ លើសពីនេះ នៅពេលកូនក្រុមភ្លូររាស់ដកស្ទូងឬប្រូតកាត់ គឺខ្ញុំត្រូវចុះធ្វើជាមួយកូនក្រុមជាប់ជានិច្ច បើខ្ញុំមិនធ្វើទេ ប្រាកដជាត្រូវកូនក្រុមធ្វើការទិតៀននៅក្នុងអង្គប្រជុំជាក់ជាពុំខានឡើយ។

នៅឆ្នាំ១៩៧៧ ខ្មែរក្រហមបានចាត់តាំងខ្ញុំឱ្យធ្វើការនៅក្នុងកងចល័ត និងត្រូវទៅដឹកព្រែក នៅភូមិអូរកណ្តាល ឃុំដរិពូន ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង។ ថ្ងៃមួយពេលដែលខ្ញុំកំពុងដឹកប្រឡាយ ខ្ញុំឃើញនារីម្នាក់កើតជំងឺស្រឹត ប្រកាច់ធ្លាក់ពីមាត់ប្រឡាយចុះទៅក្រោមជម្រៅ៧ម៉ែត្រ។ ខ្ញុំភ្ញាក់ផ្អើលជាខ្លាំងនៅពេលឃើញគាត់ធ្លាក់ទៅដល់ក្រោម ហើយងើបឡើងធ្វើការវិញហាក់ដូចជាពុំឈឺចាប់ឡើយ។ ចំណែកខ្ញុំខំប្រឹងធ្វើការបន្តទៀត។ មិនយូរប៉ុន្មាន ខ្ញុំបានធ្លាក់ខ្លួនឈឺគ្រុនសន្ធប់ ដូច្នេះខ្មែរក្រហមបានបញ្ជូនខ្ញុំទៅព្យាបាលនៅមន្ទីរពេទ្យរយៈពេលកន្លះខែ ទើបបញ្ជូនខ្ញុំត្រឡប់មកផ្ទះវិញ។ នៅពេលដែលខ្ញុំមកដល់ផ្ទះ ខ្មែរក្រហមបានចាត់តាំងខ្ញុំឱ្យទៅកាប់ខស នៅភូមិពាមស្តី ឃុំព្រែកជ្រៃ ស្រុកពោធិ៍រៀង ខេត្តព្រៃវែង និងតំបន់ផ្សេងៗទៀតដែលមានព្រៃដុះច្រើន។

បន្ទាប់ពីកើតមានព្រឹត្តិការណ៍ចោទប្រកាន់ថា សោ ភឹម ក្បត់ ខ្ញុំឃើញកងទ័ពមកពីភូមិភាគនិរតីបានចូលមកចាប់កងឈ្លប ប្រធានកង និង ប្រធានឃុំ នៅតំបន់របស់ខ្ញុំយកទៅសម្លាប់ចោល។ ចំណែកប្អូនស្រីរបស់ខ្ញុំត្រូវកងទ័ពមកពីភូមិភាគនិរតីបញ្ជូនទៅខេត្តពោធិ៍សាត់ ព្រោះគាត់មានប្តីធ្វើជាកងឈ្លបក្រោមការដឹកនាំរបស់ សោ ភឹម។ នៅពេលនោះ ឪពុកម្តាយរបស់ខ្ញុំអាណិតកូនជាខ្លាំង ព្រោះខ្លាចកូនមានគ្រោះថ្នាក់ ទើបសម្រេចចិត្តស្នើសុំខ្មែរក្រហមទៅរស់នៅខេត្តពោធិ៍សាត់ជាមួយកូនដែរ។ ឪពុករបស់ខ្ញុំបានស្លាប់នៅទីនោះ គឺសល់តែម្តាយ និងប្អូនស្រីរបស់ខ្ញុំតែប៉ុណ្ណោះដែលមានជីវិតបានវិលត្រឡប់ស្រុកកំណើតវិញ។

ចំណែកខ្ញុំនៅធ្វើស្រែក្នុងភូមិ និងកាប់ខសឱ្យអង្គការរហូតដល់របបខ្មែរក្រហមដួលរលំ នៅដើមខែមករា ឆ្នាំ១៩៧៩។



សំ ទឹម កំពុងអានទស្សនាវដ្តីស្វែងរកការពិតនៃមជ្ឈមណ្ឌលឯកសារកម្ពុជា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# លួចបេះផ្លែឈើនោងមកស្ងោរហូបដើម្បីរស់

**ជីម សុខគា**

ខ្ញុំឈ្មោះ ឌុល ភី ឈ្មោះហៅក្រៅ គ្រាត់ អាយុ ៨១ឆ្នាំ កើតនៅភូមិព្រៃមេលងខាងត្បូង ឃុំព្រៃខ្លា ស្រុកកោះអណ្ដែត ខេត្តតាកែវ។ សព្វថ្ងៃ ខ្ញុំគឺជាដូនជីកាន់សីល១០ រស់នៅភូមិក្រាំងគរ ឃុំត្រាំកក់ ស្រុកត្រាំកក់ ខេត្តតាកែវ។ ខ្ញុំមានឪពុកឈ្មោះ ឌុល ជិន និងម្ដាយឈ្មោះ ហ៊ុល ញ៉ាក ប៉ុន្តែគាត់ទាំងពីរនាក់បានស្លាប់អស់ហើយ។ ខ្ញុំមានបងប្អូនបង្កើតចំនួនបីនាក់ ក្នុងនោះមានប្រុសម្នាក់ និងស្រីពីរនាក់។ បច្ចុប្បន្នបងប្អូនរបស់ខ្ញុំនៅរស់រានមានជីវិតតែ២នាក់តែប៉ុណ្ណោះ។ ខ្ញុំមានប្ដីឈ្មោះ រស់ ទុយ ស្លាប់យូរឆ្នាំហើយ និងមានកូនចំនួន៤នាក់ ក្នុងនោះមានកូនស្រីចំនួនបីនាក់ និងប្រុសម្នាក់។



ឌុល ភី អាយុ៨១ឆ្នាំ រស់នៅភូមិព្រៃមេលងខាងត្បូង ឃុំព្រៃខ្លា ស្រុកកោះអណ្ដែត ខេត្តតាកែវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

កាលពីក្មេង ខ្ញុំបានចូលរៀនអក្ខរកម្មជាមួយគ្រូឈ្មោះ ដូ។ ខ្ញុំរៀនរហូតចេះអានអក្សរ និងសរសេរបានបន្តិចបន្តួច ទើបឈប់រៀន។ ក្រោយ លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្ដេចព្រះ នរោត្តម សីហនុ ចេញពីតំណែងនៅឆ្នាំ១៩៧០ ខ្ញុំផ្លាស់មករស់នៅភូមិក្រាំងគរ ហើយពេលនោះមានយន្តហោះមកទម្លាក់គ្រាប់បែកជាញឹកញាប់។ ខ្ញុំនិងក្រុមគ្រួសារមានការភ័យខ្លាចយ៉ាងខ្លាំង ហើយបាននាំគ្នាជីកលេណដ្ឋាន ដើម្បីការពារខ្លួនពីការទម្លាក់គ្រាប់បែក។ ទោះបីយ៉ាងណា យន្តហោះបានមកទម្លាក់គ្រាប់បែកនៅម្ដុំព្រៃក្ដី ក្នុងភូមិក្រាំងគរ ឃុំត្រាំកក់ ស្រុកត្រាំកក់ ខេត្តតាកែវបន្តទៀត។ ដោយសារភ័យខ្លាចពីការទម្លាក់គ្រាប់បែក ក្រុមគ្រួសារខ្ញុំបានទៅរស់នៅក្បែរស្រះទឹកចាស់ នៅទំនប់អូររំដួល ស្ថិតនៅក្នុងភូមិត្រពាំងចក ឃុំត្រាំកក់ ស្រុកត្រាំកក់ ខេត្តតាកែវ។ គ្រួសារខ្ញុំទៅរស់នៅទីនោះមិនបានប៉ុន្មានខែផង ខ្ញុំសម្រាលបានកូនស្រីច្បងម្នាក់។ ជាសំណាងល្អរបស់ខ្ញុំ ដែលមានឆ្មបបុរាណជួយសម្រាលកូនឱ្យខ្ញុំដោយសុវត្ថិភាព។ ខ្ញុំនៅចងចាំឆ្មបបុរាណនោះមានឈ្មោះ អ៊ឹម។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមទទួលបានជ័យជម្នះទាំងស្រុងលើរបប លន់ នល់ ពេលនោះក្រុមគ្រួសារខ្ញុំរួមទាំងប្រជាជនដែលរស់នៅក្នុងភូមិក្រាំងគរ ត្រូវបានអង្គការជម្លៀសចេញពីភូមិ។ ក្រុមគ្រួសាររបស់ខ្ញុំ និងប្រជាជនជាច្រើនគ្រួសារបានទៅរស់នៅ ខាងកើតវត្តក្រពុំឈូក ក្នុងស្រុកកោះអណ្ដែត ខេត្តតាកែវ។ បន្ទាប់មក អង្គការចាត់តាំងខ្ញុំឱ្យចូលធ្វើការងារក្នុងកងស្រួច។ ប្រធានកងរបស់ខ្ញុំគឺជាបុរស មានមាឌតូច សម្បុរស្រអែម និងមានការ

យោគយល់ចំពោះប្រជាជននៅក្រោមបង្គាប់ៗ ក្នុងរបបខ្មែរក្រហម ខ្ញុំត្រូវខិតខំធ្វើការឱ្យបានល្អ និងធ្វើឱ្យទាន់តាមការកំណត់របស់អង្គការ។ ការងារប្រចាំថ្ងៃរបស់ខ្ញុំគឺត្រូវទៅជីកប្រឡាយ និងលើកទំនប់ៗ ក្នុងមួយកងស្រួចមានសមាជិក១០នាក់ បូករួមទាំងបុរស និងស្ត្រី។ ក្រៅពីរែកដីចាក់ធ្វើទំនប់ អង្គការប្រើខ្ញុំឱ្យបំបែកគុម្ពស្រូវឱ្យដុះបានច្រើន និងដកស្មៅដែលដុះនៅក្នុងស្រែ។ អង្គការប្រើខ្ញុំដូចសត្វគោ សត្វក្របី គ្មានពេលឈប់សម្រាកឡើយ។ អង្គការបានរឹតបន្តឹង គាបសង្កត់បំបិទសិទ្ធិសេរីភាពលើការនិយាយស្តីរបស់ខ្ញុំរួមទាំងប្រជាជននៅតាមកង។ អង្គការបានបង្ខំប្រជាជនឱ្យកាត់ផ្តាច់មនោសញ្ចេតនារវាងបងប្អូនឪពុកម្តាយ និងសាច់ញាតិ។ ចំណែកកងឈ្លបបានតាមដានប្រជាជនទាំងយប់ទាំងថ្ងៃ។ ប្រជាជនទាំងអស់មិនមានសិទ្ធិតវ៉ាឡើយ គឺម្នាក់ៗត្រូវខិតខំធ្វើការងារឱ្យបានល្អដើម្បីអាចរស់រានមានជីវិតបន្តទៀត។ ដោយសារការនឿយហត់ និងអស់កម្លាំងខ្លាំង ខ្ញុំតែងតែលួចបេះផ្លែននោងមកស្ងោរក្នុងកំសៀវ ដែលមើលទៅហាក់ដូចជាខ្ញុំដាំទឹកតែផឹកៗ នៅពេលខ្ញុំហូបននោងស្ងោរ គឺខ្ញុំត្រូវលួចហូបមិនឱ្យខ្មែរក្រហមឃើញឡើយ។ របបខ្មែរក្រហមបានបង្អត់អាហារ ប្រព្រឹត្តអំពើព្រៃផ្សៃ និងកាប់សម្លាប់ប្រជាជនគ្មានមេត្តាឡើយ។ ជាក់ស្តែង ខ្ញុំបានស្គាល់មនុស្សពីរនាក់គឺ រិត និង ប៉ែត គឺជាប្រជាជនជម្លៀសដូចខ្ញុំដែរ ដែលស្លាប់ដោយសារអត់អាហារ។ ក្រោយរបបខ្មែរក្រហមដួលរលំ នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ទើបខ្ញុំវិលត្រឡប់មកស្រុកកំណើត និងរស់នៅជួបជុំក្រុមគ្រួសារវិញ។



ទេសភាពវាលស្រែ នៅខេត្តតាកែវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# រៀបការក្នុងរបបខ្មែរក្រហម

## លី សុខឃាង



សុន សុខា អាយុ៦៣ឆ្នាំ រស់នៅក្នុងភូមិថ្នល់កែង ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

សុន សុខា ភេទស្រី អាយុ៦៣ឆ្នាំ កើតនៅភូមិទួលតាហោ ស្រុកអូរាំងឪ ខេត្តត្បូងឃ្មុំ។ បច្ចុប្បន្ន សុខា រស់នៅក្នុងភូមិថ្នល់កែង ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។

សុខា បានចែករំលែករឿងរ៉ាវប្រវត្តិតស៊ូរបស់ខ្លួនថា៖ ខ្ញុំរស់នៅជាមួយឪពុក ចំណែកម្ដាយខ្ញុំបានស្លាប់ជាយូរមកហើយ ព្រោះតាំងពីខ្ញុំធំឡើង ខ្ញុំមិនដែលបានជួបមុខម្ដាយសូម្បីតែម្ដង។ ការរស់នៅជាមួយឪពុក ដោយគ្មានម្ដាយមើលថែទាំ គឺខ្ញុំខ្វះភាពកក់ក្ដៅ។ គ្រួសារខ្ញុំមានជីវភាពក្រីក្រ ដោយសារឪពុកខ្ញុំប្រកបរបរធ្វើស្រែចិញ្ចឹមកូនៗ។ ខ្ញុំមិនបានរៀនសូត្រទេ។ មិនយូរប៉ុន្មាន ឪពុកខ្ញុំបានរៀបការប្រពន្ធម្នាក់ទៀត។ ក្រោយពីឪពុកខ្ញុំរៀបការរួច ខ្ញុំត្រូវរស់នៅជាមួយម្ដាយចុងនៅស្រុកកំណើត។

លុះដល់ឆ្នាំ១៩៧០ ខ្ញុំចងចាំថាមានការទម្លាក់គ្រាប់បែកនៅក្នុងភូមិ។ ខណៈពេលនោះប្រជាជនមិនហ៊ានចេញទៅធ្វើការឆ្ងាយៗពីផ្ទះទេ។ ខ្ញុំត្រូវប្រយ័ត្នចំពោះយន្តហោះទម្លាក់គ្រាប់បែកគ្រប់ពេលវេលា។ ប្រជាជននៅក្នុងភូមិបាននាំគ្នាជីកលេណដ្ឋាននៅតាមផ្ទះរៀងៗខ្លួន ទុកសម្រាប់ការពារខ្លួនពីការទម្លាក់គ្រាប់បែក។ កាលនោះ សូម្បីតែការធ្វើស្រែមានការលំបាកខ្លាំងណាស់ដែរ។ ដល់រដូវធ្វើស្រែ ស្ទូងដក ច្រូតកាត់ម្ដងៗ ប្រជាជនមានភាពភ័យខ្លាចយ៉ាងខ្លាំងមិនហ៊ានចេញទៅវាលស្រែទេ ព្រោះពេលខ្លះប្រជាជនកំពុងតែធ្វើការ យន្តហោះ ហោះមកទម្លាក់គ្រាប់បែកជាច្រើនសន្ទឹកសន្ទាប់មកលើប្រជាជន ធ្វើឱ្យមានអ្នកខ្លះរងរបួស ហើយអ្នកខ្លះទៀតរត់ទៅលាក់ខ្លួននៅក្បែរដំបូកប្រឡាយ ទាំងសេចក្ដីភ័យខ្លាច។ គ្រួសារខ្ញុំបន្តរស់នៅក្នុងស្រុកកំណើតរហូតដល់ខ្មែរក្រហមទទួលបានជ័យជម្នះ។

នៅក្នុងឆ្នាំ១៩៧៥ បន្ទាប់ពីខ្មែរក្រហមឡើងកាន់អំណាច គ្រួសារខ្ញុំត្រូវបានអង្គការជម្លៀសទៅរស់នៅស្រុកកោះញែក ខេត្តមណ្ឌលគិរី។ កាលនោះដោយសារតែមានបញ្ជាពីថ្នាក់លើទើបគ្រួសារខ្ញុំត្រូវចាកចេញពីភូមិកំណើតទៅរស់នៅស្រុកឆ្ងាយ។ គ្រួសារខ្ញុំមិនអាចដឹងបានទេថា អង្គការជម្លៀសទៅឱ្យរស់នៅកន្លែងថ្មីដោយសារតែហេតុផលអ្វី ព្រោះយើងគ្មានសិទ្ធិសួរនាំទេ គឺមានសិទ្ធិត្រឹមធ្វើតាមបទបញ្ជាតែប៉ុណ្ណោះ។ បន្ទាប់ពីគ្រួសារខ្ញុំធ្វើដំណើរទៅដល់ស្រុកកោះញែក យើងត្រូវរស់នៅជាសហករណ៍ហូបរួម ធ្វើការងាររួមនិងគ្មានរបស់របរប្រើប្រាស់ឯកជនទៀតទេ។ ប៉ុន្តែ

ចំពោះកន្លែងស្នាក់នៅ គឺយើងមានផ្ទះ និងរស់នៅតាមក្រុមសាររៀងៗខ្លួន។ ឪពុកនិងម្តាយចុងរបស់ខ្ញុំត្រូវបានអង្គការបញ្ជូនទៅធ្វើការនៅក្នុងសហករណ៍។ រីឯខ្ញុំក្នុងដំណាក់កាលដំបូង ខ្មែរក្រហមចាត់តាំងឱ្យទៅធ្វើជាជំនួយការចុងភៅនៅរោងបាយសហករណ៍។ ការងារដែលខ្ញុំធ្វើជាប្រចាំ គឺជួយចិតបន្លែចុងភៅ និងដាំបាយសម្រាប់ចែកឱ្យអ្នកធ្វើការនៅក្នុងសហករណ៍ទាំងអស់។ ខ្ញុំនៅធ្វើជាអ្នកចិតបន្លែបានមួយរយៈ អង្គការផ្លាស់ប្តូរខ្ញុំឱ្យទៅខាងផ្នែកមើលថែទាំងក្មេងៗវិញ។ កុមារទាំងអស់នោះ គឺសុទ្ធតែជាកូនរបស់ប្រជាជនដែលរស់នៅក្នុងសហករណ៍ជាមួយគ្នា ប៉ុន្តែឪពុកម្តាយរបស់ក្មេងៗមិនអាចនៅមើលថែក្មេងទាំងអស់នេះបានដូចមុនទេ ដោយសារខ្លួនជាប់ភារកិច្ចរៀងៗខ្លួនដែលអង្គការបានផ្តល់ឱ្យ។ ជារៀងរាល់ព្រឹក មីងៗតែងតែយកកូនតូចៗមកផ្ញើជាមួយខ្ញុំមុនពេលចេញទៅបំពេញការងារ។ ក្មេងៗទាំងនោះ ត្រូវខ្ញុំបញ្ចុកបាយ ទឹក និងដាក់ឱ្យដេកគ្រប់ៗគ្នា។ ខ្ញុំមើលក្មេងរហូតដល់ល្ងាចម៉ោង៥ ទើបម្តាយក្មេងៗទាំងនោះមកយកត្រឡប់ទៅផ្ទះវិញ។ នៅក្នុងសហករណ៍ខ្ញុំការហូបចុកមិនសូវខ្វះខាតទេ យូរៗម្តងប្រធានចុងភៅបានធ្វើបង្អែមឱ្យប្រជាជនហូបថែមទៀត។

នៅដើមឆ្នាំ១៩៧៦ អង្គការបានរៀបចំខ្ញុំឱ្យមានគូស្រករ។ កាលខ្ញុំរៀបការ មានគ្នាទាំងអស់ចំនួន៦គូ។ ការរៀបការរបស់ខ្ញុំមិនមានកម្មវិធីធំដុំអ្វីឡើយ ដោយអង្គការបានឱ្យកូនកម្លោះ និងកូនក្រមុំទាំងអស់អង្គុយទល់មុខគ្នា ហើយឡើងប្តេជ្ញាស្រឡាញ់គ្នា មើលថែគ្នា និងគោរពតាមអង្គការចាត់តាំង។ ក្រោយពីរៀបការរួច ខ្ញុំនិងប្តីបានមករស់នៅជាមួយគ្នាក្នុងសហករណ៍ និងបន្តធ្វើការតាមតួនាទីរៀងៗខ្លួន។

រហូតដល់ឆ្នាំ១៩៧៩ កងទ័ពស្ម័គ្រចិត្តវៀតណាមបានចូលមកពាសពេញប្រទេសកម្ពុជា។ ការចូលមកដល់របស់កងទ័ពវៀតណាម បានធ្វើឱ្យខ្ញុំបែកចេញពីឪពុក និងម្តាយចុងរហូតមកដល់បច្ចុប្បន្ន។ ចំណែកខ្ញុំនិងប្តីបានរត់ភៀសខ្លួនចូលក្នុងព្រៃ ដែលអំឡុងពេលនោះខ្ញុំមានផ្ទៃពោះជិតសម្រាល។ មិនយូរប៉ុន្មាន ខ្ញុំសម្រាលបានកូនស្រីម្នាក់។ ប៉ុន្តែជាអកុសលរយៈពេល៣ថ្ងៃក្រោយមក កូនស្រីរបស់ខ្ញុំបានស្លាប់ក្នុងព្រៃ។ បន្ទាប់ពីកូនស្លាប់ ខ្ញុំបានបន្តដំណើរទៅមុខទៀត ព្រោះខ្លាចកងទ័ពវៀតណាមតាមទាន់។ ពេលនោះ ខ្ញុំសរសៃខ្ចី ទើបធ្វើឱ្យខ្ញុំពិបាកក្នុងការធ្វើដំណើរដូចមនុស្សទូទៅ។ ក្នុងពេលធ្វើដំណើរ យើងត្រូវឆ្លងកាត់ទន្លេ ដើរកាត់ព្រៃក្រាស់ ហើយពេលខ្លះជួបកងទ័ពវៀតណាម និងវាយប្រយុទ្ធគ្នាពេញព្រៃ។

រហូតដល់ឆ្នាំ១៩៨៦ ខ្ញុំនិងប្តីបានទៅរស់នៅស៊ឹងចាន់។ នៅទីនោះ យើងសង់ផ្ទះតូចៗរស់នៅដោយឡែកពីគ្នា។ ខ្ញុំរស់នៅស៊ឹងចាន់បានត្រឹមរយៈពេល២ឆ្នាំ ទើបផ្លាស់ទៅរស់នៅក្នុងជំរំកូណយវិញ។ ពេលទៅរស់នៅទីនោះ ជីវភាពរបស់ខ្ញុំនិងប្រជាជនហាក់មានភាពធូរស្បើយជាងមុន។ ប្រជាជនអាចទៅរកស៊ីបោចវល្លិ៍ផ្តៅយកមកធ្វើជាកន្ទេល ល្អី ជាល លក់ទៅឱ្យប្រជាជនថៃដើម្បីរកប្រាក់ចំណូល។ ក្រៅពីនេះ តាមគ្រួសារនីមួយៗអាចដាំចេក ត្រកួន ត្រប់ ត្រសក់ សម្រាប់ហូបខ្លួនឯង។ ចំពោះរបបអាហារប្រចាំថ្ងៃយើងទទួលជំនួយពីអង្គការកាកបាទក្រហម។

មកដល់បច្ចុប្បន្ននេះ ខ្ញុំមានការភ្លេចភ្លាំងច្រើន ដោយសារខ្ញុំជួបរឿងច្រើនពេលរស់នៅក្នុងព្រៃ ដូចជាបាត់បង់កូនជាទីស្រឡាញ់។ បន្ថែមពីនេះ ខ្ញុំមានជំងឺស្ពឹកដៃស្ពឹកជើង និងជំងឺប្រចាំកាយជាច្រើនដែលបន្សល់ពីរបបខ្មែរក្រហម ព្រោះខ្ញុំបានធ្វើដំណើរដោយថ្មើរជើងរាប់ពាន់គីឡូម៉ែត្រពីតំបន់មួយទៅតំបន់មួយ ធ្វើឱ្យសុខភាពចុះខ្សោយរហូតមកដល់សព្វថ្ងៃ។



សុន សុខា អាយុ៦៣ឆ្នាំ រស់នៅក្នុងភូមិថ្នល់កែង ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ខ្មែរក្រហមសម្លាប់ប្ដីខ្ញុំ ព្រោះធ្លាប់ធ្វើជាគ្រូពេទ្យជំនាន់ លន់ នល់

**សិលា បញ្ញាវុធ**

ខ្ញុំឈ្មោះ ជីង ស៊ីម អាយុ៨០ឆ្នាំ សព្វថ្ងៃរស់នៅភូមិសុវណ្ណគមន៍ ឃុំកណ្ដោលជ្រុំ ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ។ ខ្ញុំគឺជាស្ត្រីមេម៉ាយ និងមានមុខរបរជាកសិករ។ ប្ដីរបស់ខ្ញុំឈ្មោះ សុខ សាធ គឺជាគ្រូពេទ្យក្នុងរបប លន់ នល់ ត្រូវខ្មែរក្រហមយកទៅសម្លាប់ក្នុងអាយុ៤៨ឆ្នាំ។ ខ្ញុំមានកូនចំនួន៨នាក់ គឺប្រុសម្នាក់ និងស្រី៧នាក់។ កូនរបស់ខ្ញុំចំនួន៤នាក់ បានស្លាប់ដោយសារជំងឺមុនរបបខ្មែរក្រហម និងអំឡុងពេលខ្មែរក្រហមចូលមកគ្រប់គ្រងប្រទេស។ បច្ចុប្បន្ន ខ្ញុំនៅសល់កូនស្រីចំនួន៤នាក់តែប៉ុណ្ណោះ។ កូនៗរបស់ខ្ញុំបច្ចុប្បន្នប្រកបមុខរបរលក់ដូរ។

នៅអំឡុងពេលមានការទម្លាក់គ្រាប់បែកគ្រួសារខ្ញុំបានភៀសខ្លួនទៅរស់នៅទីក្រុងភ្នំពេញ។ កាលនៅស្រុកកំណើត ប្ដីរបស់ខ្ញុំធ្វើជាគ្រូពេទ្យក្នុងភូមិ ប៉ុន្តែពេលទៅដល់ភ្នំពេញ គាត់បានប្ដូរទៅជាអ្នករត់ម៉ឺក ។ ប្រាំឆ្នាំក្រោយមក នៅពេលខ្មែរក្រហមទទួលជ័យជម្នះលើរបប លន់ នល់ ខ្មែរក្រហមបានបង្ខំក្រុមគ្រួសារខ្ញុំឱ្យចាកចេញពីទីក្រុងភ្នំពេញត្រឡប់ទៅស្រុកកំណើតវិញ។ ទោះជាយ៉ាងណា យើងមិនបានធ្វើដំណើរទៅដល់ផ្ទះយើងឡើយ ព្រោះខ្មែរក្រហមបានបង្ខំគ្រួសាររបស់ខ្ញុំឱ្យទៅរស់នៅភូមិដំណាក់ចារ ឃុំអញ្ចើម ស្រុកមេមត់ ខេត្តត្បូងឃ្មុំ ជំនួសវិញ។ នៅក្នុងអំឡុងពេលជម្លៀសនោះ កូនរបស់ខ្ញុំម្នាក់បានស្លាប់តាមផ្លូវដោយសារជំងឺរាក។

ពេលទៅដល់ភូមិដំណាក់ចារ ខ្មែរក្រហមបានហៅប្ដីខ្ញុំ និងប្អូនថ្លៃខ្ញុំ ដែលជាអតីតទាហាន លន់ នល់ ទៅរៀនសូត្រ។ ពេលខ្ញុំសួរកម្មាភិបាលខ្មែរក្រហមថា



ជីង ស៊ីម អាយុ៨០ឆ្នាំ រស់នៅភូមិសុវណ្ណគមន៍ ឃុំកណ្ដោលជ្រុំ ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ត្រូវរៀនប៉ុន្មានខែ កម្មាភិបាលនោះប្រាប់ថា ត្រឹម៣ខែប៉ុណ្ណោះ។ ប៉ុន្តែរហូតដល់៤ខែកន្លងផុតទៅ ប្ដី និងប្អូនថ្លៃរបស់ខ្ញុំនៅតែមិនឃើញត្រឡប់មកវិញ។ ខ្ញុំបានទៅសួរនាំម្ដងទៀត ស្រាប់តែកម្មាភិបាលនោះឆ្លើយថា មកពីប្ដីខ្ញុំរៀនមិនទាន់ចេះ។ ខ្ញុំនិយាយតបវិញថា៖ «ល្ងង់អីក៏ល្ងង់ម្ល៉េះ! ធ្លាប់ធ្វើជាគ្រូពេទ្យដែរនៅតែរៀនមិនចេះទៀត»។ កម្មាភិបាលនោះបានឆ្លើយតបមកវិញថា៖ «នេះជាច្បាប់បដិវត្តន៍ បើចេះថ្ងៃណា នឹងបានមកវិញថ្ងៃនោះ»។

រយៈពេល៧ខែកន្លងផុតទៅ នៅក្នុងហេតុការណ៍ដែលអ្នកភូមិផ្អើលទៅមើលសាកសពបុរសម្នាក់ដែលសង្ស័យថា ស្លាប់ដោយសារជំងឺឃ្លង់ ខ្ញុំបានជួបកម្មាភិបាលខ្មែរក្រហមរូបនោះម្ដងទៀត ហើយសួរពីដំណឹងប្ដីរបស់ខ្ញុំសាជាថ្មីប៉ុន្តែខ្ញុំនៅតែទទួលបានចម្លើយដដែលៗថា ប្ដីរបស់ខ្ញុំរៀនមិនទាន់ចប់។ ថ្ងៃមួយបន្ទាប់ពីខ្ញុំធ្វើការងាររួច ខ្ញុំបានទៅអង្គុយនៅក្រោមដើមជ្រៃមួយដើម ហើយជេរប្រទេចខ្មែរក្រហមដោយសំឡេងឮៗថា៖ «បដិវត្តន៍ម៉ែវាអី! បើភូតរហូតអ៊ីចឹង!»។ ពេលនោះក្រុមស្ត្រីដែលនៅក្បែរនោះបានប្រញាប់មកឃាត់ខ្ញុំមិនឱ្យមាត់កបន្តទៀតឡើយ ព្រោះខ្លាចមានគ្រោះថ្នាក់។

យប់មួយ នៅពេលខ្ញុំកំពុងអុំអង្ករ ស្រាប់តែពោះរបស់ខ្ញុំចាប់ផ្ដើមរឹងខ្លាំង និងពិបាកធ្វើការ ដោយសារជិតដល់ថ្ងៃសម្រាលកូន។ ស្ថានភាពរបស់ខ្ញុំកាន់តែលំបាកទៅៗ ខណៈប្ដីមិននៅក្បែរ។ ឃើញដូច្នេះ បងស្រីម្នាក់ដែលធ្វើការជាមួយគ្នា បានមកជួយអុំអង្ករជំនួសខ្ញុំ ដើម្បីឱ្យខ្ញុំទៅធ្វើការស្រាលៗវិញ គឺរើសគ្រាប់ស្រូវចេញពីអង្ករ។ លុះធ្វើការរួចរាល់នៅវេលាម៉ោង១០យប់ ខ្ញុំខំប្រឹងដើរទាំងលំបាកត្រឡប់មកផ្ទះវិញ។ ពេលឃើញខ្ញុំមកដល់ផ្ទះយឺតខុសធម្មតា ម្ដាយរបស់ខ្ញុំបានស្ទុះមកសួរនាំទាំងក្ដីបារម្ភ។ ខ្ញុំបានប្រាប់គាត់ពីការងារ និងអាការមិនស្រួលខ្លួន។ ម្ដាយខ្ញុំដឹងភ្លាមថា ខ្ញុំជិតសម្រាលកូន ទើបប្រញាប់ទៅអង្វរអ្នកជិតខាងឱ្យជួយទៅរកឆ្មបមកជួយបង្កើតកូន។ ពេលឆ្មបមកដល់ ឆ្មបបាននិយាយប៉ាន់ស្មានថា ពោះរបស់ខ្ញុំនៅតូច ដូច្នេះប្រហែលជាមួយខែទៀតទើបដល់ថ្ងៃឆ្លងទន្លេ ប៉ុន្តែដោយសារខ្ញុំឈឺពោះខ្លាំង ទីបំផុតខ្ញុំសម្រាលកូននាពេលនោះតែម្ដង។ ក្រោយសម្រាលរួច ឆ្មបនោះបានប្រញាប់ចាកចេញទៅវិញភ្លាមៗ ព្រោះខ្លាចថ្នាក់លើដឹង។

ត្រឹមតែរយៈពេល១៩ថ្ងៃក្រោយសម្រាលកូន ប្រពន្ធប្រធានសហករណ៍បានមកដល់ផ្ទះខ្ញុំ រួចនិយាយថា នឹងនាំខ្ញុំទៅជួបប្ដីដែលកំពុងអារឈើនៅស្រែថ្មី។ ខ្ញុំយល់ភ្លាមថា ខ្មែរក្រហមបម្រុងនាំខ្ញុំទៅសម្លាប់ចោល ព្រោះខ្ញុំដឹងថាប្ដីរបស់ខ្ញុំបានស្លាប់យូរហើយ។ ម្ដាយខ្ញុំបានជួយនិយាយបដិសេធ ដោយប្រាប់ថា ខ្ញុំទើបតែសម្រាលកូនបានរយៈពេល១៩ថ្ងៃតែប៉ុណ្ណោះ ដូច្នេះមិនអាចធ្វើដំណើរបានទេ។ ទោះបីជាប្រពន្ធប្រធានសហករណ៍នោះព្យាយាមអូសទាញយ៉ាងណា ប៉ុន្តែដោយសារភាពជម្នះមិនព្រមទៅ ទើបខ្មែរក្រហមលែងបង្ខំខ្ញុំទៀត។

រឿងរ៉ាវដ៏ខ្លោចផ្សាមួយទៀតគឺ ប្អូនស្រីរបស់ខ្ញុំឈ្មោះ លី អាយុ២៣ឆ្នាំ បានស្លាប់ដោយសារទាស់សរសៃ។ ប្អូនស្រីរបស់ខ្ញុំបានសម្រាលកូនដំណាលគ្នានឹងខ្ញុំ។ មូលហេតុគឺនាងបានហូបសម្ការីសាច់ក្របីដែលចុងភៅខ្មែរក្រហមស្ងោឱ្យប្រជាជនហូបក្នុងកម្មវិធីជប់លៀងឱ្យប្រជាជនបោកស្រូវ។ ពេលត្រឡប់មកដល់ផ្ទះ នាងចាប់ផ្ដើមក្ដៅខ្លួនខ្លាំង ហើយទាស់ស្លាប់ភ្លាមៗ ទាំងដែលកូនទើបតែអាយុមួយខែកន្លះ។ បន្ទាប់ពីម្ដាយស្លាប់ទៅ កូនតូចបានស្លាប់តាមក្រោយ ដោយសារគ្មានទឹកដោះបៅ។

នៅចុងឆ្នាំ១៩៧៨ គ្រួសារខ្ញុំ និងប្រជាជនជាច្រើនទៀត ត្រូវខ្មែរក្រហមកៀរឱ្យទៅរស់នៅភូមិត្រពាំងទា ឃុំចក ស្រុកអូរាំងឪ ខេត្តត្បូងឃ្មុំ។ នៅពេលកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងកងទ័ពស្ម័គ្រចិត្តវៀតណាម ជិតចូលមកដល់ យោធាខ្មែរក្រហមបានកៀរប្រជាជនទាំងយប់ទៅកាន់ភូមិជប់ ឃុំជប់ ស្រុកត្បូងឃ្មុំ ដែលជាទីតាំងសម្លាប់ប្រជាជន។ នៅក្នុងស្ថានភាពច្របូកច្របល់ ខ្ញុំ និងគ្រួសាររួមទាំងប្រជាជនជាច្រើននាក់ទៀត បានសម្រេចចិត្តលួចរត់ត្រឡប់ថយក្រោយវិញ។ ដៃម្ខាងខ្ញុំបីកូនតូច ឯដៃម្ខាងទៀតបណ្ដើរកូន២នាក់ធំៗ ដើរកាត់វាលស្រែត្រឡប់មកស្រុកកំណើត។ ចំណែកម្ដាយខ្ញុំដែលដើរមិនរួច ខ្ញុំបានទៅសុំរទេះគោអ្នកធ្វើដំណើរស្របផ្លូវគ្នា ដើម្បីឱ្យគាត់ជិះ។ ខ្ញុំ និងកូនៗបានដើរតាមពីក្រោយរទេះគោរហូតមកដល់ស្រុកកំណើតដោយសុវត្ថិភាព។

# នួន មិន ៖ ត្រូវគ្រាប់កាំភ្លើងតែមិនស្លាប់ ពេលពរកូនរត់គេចខ្លួន

**ថុន ស្រីពេជ្រ**

ខ្ញុំឈ្មោះ នួន មិន អាយុ៧៥ឆ្នាំ សព្វថ្ងៃរស់នៅភូមិតាកោ សង្កាត់តាកោ ក្រុងព្រៃវែង ខេត្តព្រៃវែង។ ខ្ញុំមានបងប្អូនបង្កើតចំនួន៦នាក់ ក្នុងនោះមានស្រី៤នាក់ និងប្រុស២នាក់។ ខ្ញុំមានប្តីឈ្មោះ ចាប និងមានកូនស្រីម្នាក់។ ប្តីរបស់ខ្ញុំគឺជាអតីតទាហាន លន់ នល់។

នៅឆ្នាំ១៩៧៥ បន្ទាប់ពីកងទ័ពខ្មែរក្រហមបានវាយលុក និងគ្រប់គ្រងទីក្រុងភ្នំពេញរួចមក ស្រាប់តែប្តីរបស់ខ្ញុំបានបាត់ខ្លួនដោយមិនដឹងមូលហេតុតាំងពីពេលនោះមក។ ខ្ញុំបានធ្លាក់ខ្លួនជាស្ត្រីមេម៉ាយ រស់នៅជាមួយកូនស្រីដោយគ្មានទីពឹង និងត្រូវសម្របខ្លួនជាមួយរបបសង្គមថ្មីរបស់ខ្មែរក្រហម។ ខ្មែរក្រហមបង្ខំខ្ញុំឱ្យធ្វើការងារធ្ងន់ធ្ងរ ដូចជា លើកប្រព័ន្ធភ្លឺស្រែ ជីកប្រឡាយ ជីកព្រែក គាស់គល់ឈើ ហើយជួនកាលត្រូវចាត់តាំងឱ្យធ្វើកន្ទេល។ ជារៀងរាល់ល្ងាច ប្រធានកងតែងតែហៅប្រជាជនទាំងអស់ទៅប្រជុំជីវភាពដើម្បីធ្វើការទិតៀន និងស្វ័យទិតៀនគ្នាទៅវិញទៅមកអំពីលទ្ធផលការងារ និងការជិះជាន់កម្លាំងពលកម្មអ្នកដទៃ។ នៅក្នុងអង្គប្រជុំ ខ្ញុំធ្លាប់ត្រូវប្រធានកងទិតៀនថា ក្នុងមួយថ្ងៃខ្ញុំធ្វើកន្ទេលមិនបានមួយ។ ទោះបីជាពេលនោះ ខ្មែរក្រហមមិនយកខ្ញុំទៅកសាង ប៉ុន្តែការទិតៀនធ្វើឱ្យខ្ញុំភ័យខ្លាចយ៉ាងខ្លាំង ហើយខិតខំប្រឹងប្រែងធ្វើការងារថែមទៀត ព្រោះបើធ្វើការមិនទាន់តាមផែនការ ប្រធានកងនឹងទិតៀនបន្តទៀតមិនខាន។

ក្រោយមក ខ្មែរក្រហមបានចាត់តាំងខ្ញុំឱ្យធ្វើជាប្រធានក្រុមដឹកនាំកុមារ និងមនុស្សចាស់ចំនួន១០ នាក់


នួន មិន អាយុ៧៥ឆ្នាំ រស់នៅភូមិតាកោ សង្កាត់តាកោ ក្រុងព្រៃវែង ខេត្តព្រៃវែង។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ទៅជីកព្រែក២ខែ នៅឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង។ នៅទីនោះ ខ្ញុំសង្កេតឃើញមានកងចល័ត និងកងកុមារជាច្រើនត្រូវបានបញ្ជូនមកជីកព្រែកដែរ។ ខ្ញុំពិតជាអាណិតក្មេងៗ ព្រោះការងារជីកព្រែក កាប់ដី និងរែកដី គឺនឿយហត់ខ្លាំងណាស់។ ខ្ញុំត្រូវកាប់ដី និងរែកដីរហូតក្រិនស្មា។ ចំណែកការហូបមានការខ្វះខាត និងរស់នៅគ្មានអនាម័យ ព្រោះរយៈពេល៦ថ្ងៃទើបខ្មែរក្រហមអនុញ្ញាតឱ្យខ្ញុំទៅងូតទឹកម្តង។ បន្ទាប់ពី

ជីកព្រែកទាំង២ខ្សែរួចរាល់ ខ្មែរក្រហមបានឱ្យប្រធានក្រុមនីមួយៗដឹកនាំសមាជិកក្រុមវិលត្រឡប់មកកន្លែងស្នាក់នៅវិញ ហើយខ្ញុំលែងធ្វើជាប្រធានក្រុមទៀតហើយ។ ពេលនោះ ប្រធានកងបានចាត់តាំងខ្ញុំឱ្យទៅធ្វើការក្នុងកងចល័តលើកភ្លឺស្រែដូចកាលពីមុនៗ ខ្ញុំយល់ថាការចាត់តាំងឱ្យធ្វើប្រធានក្រុម ឬកូនក្រុមគឺមិនខុសគ្នាឡើយ ព្រោះក្នុងកាលៈទេសៈនោះ ឱ្យតែនរណាធ្វើអ្វីខុសបន្តិច ដឹងតែខ្មែរក្រហមយកទៅកសាង រៀនសូត្រ ឬ សម្លាប់ចោលភ្លាមដោយមិនរើសមុខឡើយ ហើយជួនកាលប្រធានក្រុមអាចនឹងត្រូវឈ្លបខ្មែរក្រហមយកទៅសម្លាប់មុនសមាជិកក្រុម។

សោកនាដកម្មថ្មីបានចូលមកដល់នៅក្នុងខែធ្នូ ឆ្នាំ១៩៧៧ ដោយសារតែគ្រួសាររបស់ខ្ញុំត្រូវខ្មែរក្រហមចាត់ទុកថាជាប្រជាជនថ្មី។ ពេលនោះប្រធានភូមិបានមកចុះបញ្ជីឈ្មោះសមាជិកគ្រួសារខ្ញុំទាំង ៨ នាក់ ដើម្បីបញ្ជូនទៅខេត្តពោធិ៍សាត់ជាមួយប្រជាជនថ្មីជាច្រើនគ្រួសារទៀត។ ខ្មែរក្រហមបានយកឡានជាច្រើនគ្រឿងមកដឹកខ្ញុំ និងប្រជាជនឆ្ពោះទៅកាន់ឃុំអ្នកលឿង ស្រុកពាមរក៏ ខេត្តព្រៃវែង ដើម្បីជិះស្រឡាង ទៅភ្នំពេញ រួចបន្តធ្វើដំណើរតាមរថភ្លើងឆ្ពោះទៅកាន់ខេត្តពោធិ៍សាត់។ ពេលទៅដល់ខេត្តពោធិ៍សាត់ គណៈកងដែលរង់ចាំនៅទីនោះបានបែងចែកប្រជាជនទៅតាមតំបន់ផ្សេងៗគ្នា ដោយប្រជាជនខ្លះត្រូវអង្គការបញ្ជូនបន្តតាមរថភ្លើងទៅ



នួន មិន (រូបខាងស្តាំ) កំពុងអានទស្សនាវដ្តីស្វែងរកការពិតនៃមជ្ឈមណ្ឌលឯកសារកម្ពុជា។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខេត្តបាត់ដំបង។ រីឯគ្រួសាររបស់ខ្ញុំ និងប្រជាជនមកពីភូមិតាកោ ត្រូវបានគណៈកងនាំមកកាន់ភូមិស្វាយដូនកែវ ឃុំស្វាយដូនកែវ ស្រុកបាកាន ខេត្តពោធិ៍សាត់ ដើម្បីធ្វើរោងស្នាក់នៅ និងធ្វើការងារ។ នៅទីនោះ ឪពុកម្ដាយ និងបងប្អូនរបស់ខ្ញុំទាំងអស់ត្រូវខ្មែរក្រហមបំបែកឱ្យទៅធ្វើការនៅកន្លែងផ្សេងៗគ្នា។ ប្អូនប្រុសរបស់ខ្ញុំទាំង២នាក់ ម្នាក់ជាអតីតទាហាន លន់ នល់ និងម្នាក់ទៀតជាប្រជាជន ត្រូវអង្គការបញ្ជូនឱ្យទៅធ្វើការនៅក្នុងកងចល័តនៅឆ្ងាយពីភូមិ ហើយបាត់ដំណឹងរហូតមកដល់សព្វថ្ងៃ។ ខ្ញុំគិតថា ខ្មែរក្រហមបានយកប្អូនប្រុសខ្ញុំទាំងពីរទៅសម្លាប់ចោល ព្រោះបើសិនជាប្អូនរបស់ខ្ញុំនៅរស់ច្បាស់ជាត្រឡប់មករកគ្រួសារវិញមិនខាន។ ចំណែកខ្ញុំ ត្រូវប្រធានភូមិចាត់តាំងចូលក្នុងកងចល័តដឹកប្រឡាយ លើកភ្លឺស្រែ រែកដី ស្ទូង ដក និងច្រូតកាត់ ទាំងយប់ទាំងថ្ងៃ។

ក្រោយពេលខ្ញុំរស់នៅក្នុងខេត្តពោធិ៍សាត់បានរយៈពេលមួយឆ្នាំ កងទ័ពស្ម័គ្រចិត្តវៀតណាមចូលមករំដោះធ្វើឱ្យប្រជាជនជ្រួលច្របល់ជាខ្លាំង។ ពេលនោះមានប្រជាជនមកពីខេត្តស្វាយរៀងម្នាក់ដែលមានស្មារតីរឹងមាំ បានស្រែកប្រាប់ប្រជាជនទាំងអស់ឱ្យនាំគ្នាតស៊ូរត់គេចខ្លួន ដោយគាត់និយាយថា «បើនៅគឺស្លាប់ បើទៅអាចរស់»។ ពុដូច្នេះ ក្រុមខ្ញុំប្រញាប់ប្រញាល់រៀបចំខោអាវ និងដើររកបងប្អូនដើម្បីចាកចេញភ្លាមៗ។ ប៉ុន្តែពេលរត់ទៅដល់ទីតាំងមួយ ស្រាប់តែឃើញប្រជាជនកកកុញ ឈរបន្តកន្ទុយគ្នា ព្រោះកងទ័ពខ្មែរក្រហមបានស្នាក់នៅផ្នែកខាងមុខ។ គ្រួសាររបស់ខ្ញុំស្ថិតនៅជួរក្រោយគេបង្អស់។ រំពេចនោះ ស្រាប់តែមានសំឡេងគ្រាប់បែក ដែលខ្មែរក្រហមបោក និងបាញ់តម្រង់មកលើហ្វូងប្រជាជន បណ្ដាលឱ្យមានមនុស្សស្លាប់ និងរបួសជាច្រើននាក់។ នៅក្នុងស្ថានភាពចលាចល ខ្ញុំប្រញាប់រត់ចេញពីកន្លែងកើតហេតុ ដោយដៃម្ខាងបីកូន និងដៃម្ខាងទៀតកាន់សម្ភារប្រើប្រាស់។ ស្របពេលដែលខ្ញុំកំពុងគេចខ្លួន ស្រាប់តែមានគ្រាប់កាំភ្លើងមួយគ្រាប់ហោះមកចំបញ្ចិតកញ្ចឹងកខ្ញុំ ចំពេលខ្ញុំឱនដាក់កូនចុះឱ្យដើរលើដី បណ្ដាលឱ្យហូរឈាមយ៉ាងច្រើន និងបន្សល់ទុកស្លាកស្នាមរហូតមកដល់សព្វថ្ងៃ។

ក្រុមគ្រួសារខ្ញុំមិនអាចរត់គេចខ្លួនបានឡើយ គឺខ្មែរក្រហមបានកៀងគរគ្រួសារខ្ញុំ និងប្រជាជនដែលនៅសេសសល់ទាំងអស់យកទៅដុំគ្នានៅកន្លែងមួយ។ ខ្ញុំភិតភ័យយ៉ាងខ្លាំងព្រោះឃើញសាកសពមនុស្សស្លាប់គរគ្នាពាសពេញវាលស្រែ។ ខ្មែរក្រហមបម្រុងនឹងសម្លាប់ក្រុមខ្ញុំចោលទាំងអស់ ប៉ុន្តែសំណាងល្អមានកម្មាភិបាលខ្មែរក្រហមចិត្តធម៌ម្នាក់ទៀតបានចេញមុខមកជួយការពារ មិនឱ្យយោធាខ្មែរក្រហមប៉ះពាល់ប្រជាជនសូម្បីតែម្នាក់ ថែមទាំងបង្គាប់ឱ្យកូនចៅទៅរកបាយរកទឹកមកឱ្យប្រជាជនហូប និងឱ្យសម្រាកនៅទីនោះចំនួនមួយយប់។

លុះព្រឹកឡើង យោធាខ្មែរក្រហមទាំងនោះបានរត់កៀសខ្លួនបាត់អស់។ ដោយឃើញឱកាសល្អ ក្រុមគ្រួសារខ្ញុំ និងប្រជាជនដទៃទៀតបាននាំគ្នាចាកចេញពីទីនោះ ដើម្បីធ្វើដំណើរវិលត្រឡប់មកកាន់ស្រុកកំណើតវិញ។ ក្រុមគ្រួសារខ្ញុំជួបការលំបាកវេទនាយ៉ាងខ្លាំងព្រោះគ្មានស្បៀងអាហារគ្រប់គ្រាន់ ដូច្នេះយើងត្រូវដើរសុំបាយប្រជាជនហូបតាមផ្លូវ។ លើសពីនេះ ខ្ញុំ និងបងប្អូនត្រូវផ្លាស់វេនគ្នាអៀវឪពុកម្ដាយដែលមានជំងឺ និងគ្មានកម្លាំងកំហែងក្នុងការធ្វើដំណើរទៅមុខ។ ក្រុមគ្រួសារខ្ញុំ ត្រូវចំណាយពេលធ្វើដំណើរដោយថ្មើរជើងអស់រយៈពេលមួយខែទើបមកដល់ស្រុកកំណើតវិញ។ ក្រោយពីរបបខ្មែរក្រហមត្រូវដួលរលំ ខ្ញុំបានចាប់ផ្ដើមជីវិតថ្មីដោយប្រកបរបរធ្វើស្រែចម្ការ។ សព្វថ្ងៃ ខ្ញុំមានសេចក្ដីសប្បាយរីករាយ និងជ្រះថ្លាក្នុងចិត្តជាខ្លាំង ព្រោះបានរស់នៅជុំគ្នាជាមួយបងប្អូនស្រីទាំង៤នាក់ និងមានសំណាងបានរស់រានមានជីវិតពីរបបខ្មែរក្រហម។ ប៉ុន្តែខ្ញុំនៅតែនឹកស្រណោះការស្លាប់បាត់បង់ជីវិតប្អូនប្រុសរបស់ខ្ញុំពីរនាក់ក្នុងរបបខ្មែរក្រហម។

# ភៀសខ្លួនពីកម្ពុជាក្រោម មករស់នៅបុរីអូរស្វាយ

ស្រេង លីដា



ង៉ែត សូនី អាយុ៦០ឆ្នាំ រស់នៅភូមិអូរស្វាយ ឃុំអូរស្វាយ ស្រុកបុរីអូរស្វាយ សែនជ័យ ខេត្តស្ទឹងត្រែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

## ប្រវត្តិផ្ទាល់ខ្លួន និងគ្រួសារ

ខ្ញុំឈ្មោះ ង៉ែត សូនី បច្ចុប្បន្នអាយុ៦០ឆ្នាំ មានស្រុកកំណើតនៅភូមិអូរស្វាយ ឃុំអូរស្វាយ ស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង។ ខ្ញុំគឺជាកូនទី៦ ក្នុងចំណោមបងប្អូន៧ នាក់ ក្នុងនោះស្រីចំនួន៣នាក់ និងប្រុសចំនួន ៤នាក់។ ម្ដាយរបស់ខ្ញុំឈ្មោះ ថាច់ យូង ស្លាប់នៅឆ្នាំ២០២៥ ក្នុងអាយុ១០៣ឆ្នាំ ចំណែកឯឪពុករបស់ខ្ញុំឈ្មោះ ថាច់ ង៉ែត (ស្លាប់)។ ខ្ញុំមានប្ដីឈ្មោះ សី សុវត្ថិ (ស្លាប់) និងមានកូនចំនួន១០នាក់ ក្នុងនោះមានកូនប្រុសចំនួន៧ នាក់។ ដោយសារតែខ្ញុំធំដឹងក្ដីឡើងក្នុងសម័យសង្គ្រាម និងរបបខ្មែរក្រហមហេតុនេះ ខ្ញុំមិនមានឱកាសបានចូលរៀនសូត្រឡើយ។

## ភៀសខ្លួនពីកម្ពុជាក្រោម មកកសាងជីវិតថ្មីនៅបុរីអូរស្វាយ

មូលហេតុដែលគ្រួសាររបស់ខ្ញុំត្រូវឃ្លាតឆ្ងាយពីទឹកដីកំណើតកម្ពុជាក្រោម រហូតមកដល់ស្រុកបុរីអូរស្វាយ គឺមានដំណើររឿងវែងឆ្ងាយ និងឆ្លងកាត់ការលំបាកជាច្រើន។ នៅពេលសង្គ្រាមប្រឆាំងនឹងអាណានិគមបារាំងកើតឡើងនៅក្នុងប្រទេសវៀតណាម និងក្រោយមកសង្គ្រាមជាមួយកងទ័ពអាមេរិក ឪពុករបស់ខ្ញុំបានសម្រេចចិត្តភៀសខ្លួនពីកម្ពុជាក្រោមមករស់នៅ ទីក្រុងភ្នំពេញ ប្រទេសកម្ពុជាតែម្នាក់ឯង។ ក្រោយមក ម្ដាយរបស់ខ្ញុំបានធ្វើដំណើរមកតាមក្រោយ។ ដំណើរភៀសខ្លួនរបស់ឪពុកម្ដាយខ្ញុំនាសម័យនោះគឺពោរពេញទៅដោយគ្រោះថ្នាក់ និងលំបាកខ្លាំងណាស់ ព្រោះគាត់ត្រូវឆ្លងទឹក ដើរកាត់ព្រៃក្រាស់ ទើបអាចមកដល់ទីក្រុងភ្នំពេញ។ បន្ទាប់ពីគ្រួសារខ្ញុំមករស់នៅទីក្រុងភ្នំពេញបានមួយរយៈ ព្រះករុណា ព្រះបរមរតនកោដ្ឋ សម្ដេចព្រះ នរោត្តម សីហនុ ព្រះអង្គទ្រង់បានសព្វព្រះរាជហឫទ័យជ្រើសរើសគ្រួសាររបស់ខ្ញុំ និងប្រជាជនមួយចំនួនទៀតឱ្យមករស់នៅតំបន់ព្រៃដែន «បុរីអូរស្វាយ» ក្នុងអំឡុងឆ្នាំ១៩៦៣។ ពេលមកដល់បុរីអូរស្វាយ គ្រួសារខ្ញុំទទួលបានដីចំនួន៥ហិកតា និងផ្ទះមួយខ្នង។ ខ្ញុំនៅចាំបានថា ក្នុងសម័យសង្គមរាស្ត្រនិយម បុរីអូរស្វាយមានការអភិវឌ្ឍន៍ខ្លាំងណាស់ ព្រោះមានផ្សារ មានសួនច្បារ មានអគាររសង់ពីថ្មព្រមទាំងមានព្រលានយន្តហោះទៀតផង។

## ដើមពោធិ៍ព្រះរាជទាន

នៅបុរីអូរស្វាយ ម្តាយរបស់ខ្ញុំមានការងារជាអ្នកមើលថែសួនច្បារ និងមើលថែផ្កា ដោយទទួលបានប្រាក់បៀវត្សរ៍ ៨០០ រៀលក្នុងមួយខែ។ នៅពេលទំនេរ ម្តាយរបស់ខ្ញុំតែងតែឆ្លៀតជួយដឹកទឹកឱ្យឪពុករបស់ខ្ញុំដើម្បីសាងសង់ផ្ទះ។ អំឡុងពេលនោះ លោក ម៉ៅ សង្វៀម (គឺជាមន្ត្រីជាន់ខ្ពស់ និងជាឧត្តមសេនីយ៍នៅក្នុងសម័យសង្គមរាស្ត្រនិយម) បាននាំយកដើមពោធិ៍មួយដើម ដែលជាព្រះរាជទានពីសម្តេចព្រះនរោត្តម សីហនុមកកាន់បុរីអូរស្វាយ។ ពេលគាត់ឃើញម្តាយខ្ញុំកំពុងបោសសម្អាតសំរាមក្នុងបរិវេណស្តូប គាត់បានប្រគល់ដើមពោធិ៍នោះឱ្យម្តាយខ្ញុំជាអ្នកដាំ។ ម្តាយរបស់ខ្ញុំបានយកចិត្តទុកដាក់មើលថែដើមពោធិ៍ជាប្រចាំដែលដាំនៅជាប់នឹងស្តូបអនុស្សាវរីយ៍។

នៅក្នុងអំឡុងពេលដែលសម្តេចព្រះ នរោត្តម សីហនុ ទ្រង់យាងមកសម្ពោធបុរីអូរស្វាយ ព្រះអង្គបានចែកក្រណាត់សង្គមរាស្ត្រនិយមដល់ប្រជារាស្ត្រគ្រប់ៗគ្នា គឺទាំងក្មេងចាស់ប្រុសស្រី។ កាលនោះ ទោះបីខ្ញុំនៅក្មេង ក៏ខ្ញុំទទួលបានក្រណាត់ដូចមនុស្សធំដែរ ថែមទាំងបាននំ និងស្ករគ្រាប់ច្រើនជាងអ្នកឯទៀត។ ការទទួលបានអំណោយធ្វើឱ្យខ្ញុំនៅចងចាំ និងសប្បាយចិត្តយ៉ាងខ្លាំង ព្រោះបានយកមកចែកបងប្អូនហូបជុំគ្នានៅផ្ទះ។

## ការទម្លាក់គ្រាប់បែក

ភាពសប្បាយរីករាយ និងភាពសម្បូរសប្បាយនៅបុរីអូរស្វាយ មិនបានស្ថិតស្ថេរយូរទេ បន្ទាប់ពី លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះនរោត្តម សីហនុ ពីព្រះប្រមុខរដ្ឋ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០។ ភូមិអូរស្វាយទាំងមូលប្រែជាស្ងាត់ជ្រងំ និងគ្មានអ្នកណាហ៊ានរស់នៅឡើយ ព្រោះជាតំបន់ដែលរងការទម្លាក់គ្រាប់បែកយ៉ាងខ្លាំង។ គ្រួសាររបស់ខ្ញុំត្រូវភៀសខ្លួនទៅកាន់តំបន់អូររុន និងជីកលេណដ្ឋានដើម្បីការពារខ្លួនពីការទម្លាក់គ្រាប់បែក។ យើងស្នាក់នៅទីនោះប្រហែលមួយសប្តាហ៍ ទើបត្រឡប់មកភូមិអូរស្វាយវិញ ប៉ុន្តែហេដ្ឋារចនាសម្ព័ន្ធជាច្រើន ដូចជា ផ្សារ និងមន្ទីរពេទ្យ ត្រូវបានបំផ្លិចបំផ្លាញខ្ទេចខ្ទីអស់។

## ជីវិតខ្វះចត់ក្នុងរបបខ្មែរក្រហម

នៅក្នុងឆ្នាំ១៩៧១ កងទ័ពរំដោះខ្មែរក្រហមបានចូលមកគ្រប់គ្រងតំបន់បុរីអូរស្វាយ និងតំបន់ជាច្រើនទៀតនៃខេត្តស្ទឹងត្រែងទាំងមូល។ នៅឆ្នាំ១៩៧៥ ខ្មែរក្រហមទទួលបានជ័យជម្នះទាំងស្រុងលើរបប លន់ នល់។ បន្ទាប់មក ខ្មែរក្រហមបានជម្លៀសក្រុមគ្រួសារខ្ញុំឱ្យទៅនៅសាមខួយ និងប្រជាជននៅបុរីអូរស្វាយខ្លះទៀតទៅនៅញ៉ើន។ នៅទីនោះ ខ្មែរក្រហមបំបែកខ្ញុំចេញពីគ្រួសារឱ្យទៅរស់នៅក្នុងកងចល័ត។ ខ្ញុំត្រូវដកស្ទូង លើកភ្លឺស្រែ លើកទំនប់ ទាំងយប់ទាំងថ្ងៃ ដោយគ្មានពេលសម្រាកឡើយ។ ពេលលើកទំនប់ ខ្មែរក្រហមតែងតែនិយាយកុហកដើម្បីលើកទឹកចិត្តថា «បងប្អូនជិតដល់ថ្ងៃចូលឆ្នាំហើយ ត្រូវខិតខំធ្វើការឱ្យទាន់ផែនការ ដើម្បីបានសម្រាកទៅលេងឪពុកម្តាយ»។ ខ្ញុំនិងអ្នកឯទៀតខំប្រឹងធ្វើការខ្លាំងណាស់ ប៉ុន្តែការងាររបស់ខ្មែរក្រហមមិនចេះចប់មិនចេះហើយឡើយ ធ្វើរួច១០ម៉ែត្រ ប្រធានកងបន្ថែមឱ្យ១០ម៉ែត្រទៀត ធ្វើការប្រដេញជើងគ្នា ទាល់តែទំនប់នោះរួចរាល់។ ចំណែកម្តាយរបស់ខ្ញុំត្រូវអង្គការចាត់តាំងឱ្យធ្វើជាចុងភៅ និងត្រូវមើលថែយាយខ្ញុំដែលចាស់ជរា ប៉ុន្តែពេលខ្លះខ្មែរក្រហមចោទប្រកាន់ម្តាយខ្ញុំថា លួចលាក់យកបាយម្ហូបទៅចិញ្ចឹមយាយខ្ញុំទៅវិញ។

ក្នុងមួយឆ្នាំ ខ្មែរក្រហមអនុញ្ញាតឱ្យគ្រួសារខ្ញុំជួបគ្នាបានតែម្តងនៅរដូវចូលឆ្នាំខ្មែរ ប៉ុន្តែយើងជួបជុំគ្នាបានតែមួយភ្លែត គឺបែកទៅកងរៀងៗខ្លួនវិញ។ ពេលនោះឪពុកខ្ញុំមានវ័យចាស់ជរាខ្លាំង ខ្មែរក្រហមចាត់តាំងគាត់ឱ្យទៅចាំស្រែ។ ប្រធានកងតែងតែហៅខ្ញុំទៅប្រជុំអប់រំណែនាំពីមាគ៌ាអង្គការបដិវត្តន៍ និងហាមឃាត់មិនឱ្យប្រព្រឹត្តខុសសីលធម៌។ នៅអំឡុងពេលនោះ ប្អូនថ្លៃរបស់ខ្ញុំម្នាក់ឈ្មោះ ថាច់ សឿង ត្រូវឈ្លបខ្មែរក្រហមយកទៅសម្លាប់ដោយកុហកថា យកទៅ «រៀនសូត្រ»។ ក្រោយពីនោះ ខ្ញុំធ្លាប់បានឃើញខ្មែរក្រហម

រៀបការឱ្យយុវជន និងយុវនារី ក្នុងមួយលើកៗគឺមានចំនួន១០គូ ដោយខាងប្រុស ឈរមុខទល់មុខនឹងខាងស្រី រួចហើយលើកក្រមាបង់កឱ្យគ្នាទៅវិញទៅមកៗ បន្ទាប់មក កូនកម្លោះ និងកូនក្រមុំនាំគ្នា ហូបបាយដំណើបម្នាក់មួយចាន ដើម្បីបញ្ចប់កម្មវិធី។

## វិលត្រឡប់មកភូមិកំណើត

នៅដើមឆ្នាំ១៩៧៩ កងទ័ពស្ម័គ្រចិត្តវៀតណាម និងកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាបានវាយចូលមកដល់ខេត្តស្ទឹងត្រែង។ ចំណែក ខ្មែរក្រហមបានកៀរប្រជាជន និងគ្រួសារខ្ញុំទៅស្រុកជ័យសែន ខេត្តព្រះវិហារ។ ប៉ុន្តែគ្រួសារខ្ញុំមិនទៅតាមខ្មែរក្រហមឡើយ គឺសម្រេចចិត្តនាំគ្នាត្រឡប់មកនៅតំបន់ស្រែបុស្ស ទើបបានជួបនឹងកងទ័ពវៀតណាម។ ពេលនោះ ខ្ញុំភិតភ័យខ្លាំងណាស់ព្រោះធ្លាប់ឮខ្មែរក្រហមឃោសនាបំភ័យថា «ប្រសិនបើកងទ័ពវៀតណាមចាប់បាននឹងវះពោះប្រកស្នោ»។ ឪពុកម្តាយខ្ញុំបាននិយាយលួងលោមខ្ញុំថា «សូមកូនកុំភ័យអី ពុកម៉ែចេះនិយាយភាសាវៀតណាម»។ ឪពុកម្តាយខ្ញុំបានជួយបកប្រែឱ្យកងទ័ពវៀតណាមនៅទីនោះ ហើយកងទ័ពវៀតណាមបានចែកអង្ករ និងនំប៉័ងឱ្យគ្រួសារខ្ញុំហូប។

បន្ទាប់ពីស្នាក់នៅស្រែបុស្សមួយយប់ កងទ័ពវៀតណាមបានប្រាប់គ្រួសារខ្ញុំប្រញាប់ចាកចេញ ព្រោះខ្លាចមានការផ្ទុះអាវុធតតាំងគ្នាជាថ្មី។ គ្រួសារខ្ញុំបានធ្វើដំណើរដោយថ្មើរជើងរយៈពេលមួយយប់មួយថ្ងៃទើបមកដល់បុរីអូរស្វាយ។ នៅតាមផ្លូវចូលភូមិអូរស្វាយ ខ្ញុំឃើញសាកសពយោធាខ្មែរក្រហមចំនួន១០នាក់ និងឃើញកងទ័ពវៀតណាមជាច្រើននាក់នៅយាមការពារក្នុងភូមិ។ ក្រុមគ្រួសារខ្ញុំបានរស់នៅផ្ទះចាស់ដែលសេសសល់ពីរបបខ្មែរក្រហមបណ្តោះអាសន្ន និងនាំគ្នាធ្វើស្រែចម្ការដោយយកពូជស្រូវពីភូមិសាមខ្លួយ។

សព្វថ្ងៃ ខ្ញុំមានជំងឺលើសឈាម ជំងឺលើសជាតិស្ករ ជំងឺឈឺសន្លាក់ដៃជើង ព្រមទាំងមានបញ្ហាភ្នែកដោយមើលពុំសូវច្បាស់ឡើយ។ ទោះជាយ៉ាងណា រឿងរ៉ាវអតីតកាលទាំងអស់ ដែលខ្ញុំ និងគ្រួសារធ្លាប់ឆ្លងកាត់កន្លងមកនៅតែដក់ជាប់ក្នុងចិត្តរបស់ខ្ញុំ និងក្រុមគ្រួសារជានិច្ច។





រដូវទឹកទន្លេឡើង នៅឃុំអូរស្វាយ ស្រុកបុរីអូរស្វាយ សែនជ័យ ខេត្តស្ទឹងត្រែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ព្រះរាជបណ្ណាល័យហ្លួងម៉ែនៃមជ្ឈមណ្ឌលឯកសារកម្ពុជាបន្តផ្តល់រទេះរុញ

## ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម នៅស្រុកបុរីអូរស្វាយ សែនជ័យ

**សាន ចិន្តា**



*ទាវ នុន អាយុ៨០ឆ្នាំ រស់នៅភូមិអូរស្វាយ ឃុំអូរស្វាយ ស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង និងជានិគមជនសង្គមរាស្ត្រនិយម ទទួលបានរទេះរុញពីក្រុមការងារអគារមរតកសង្គមរាស្ត្រនិយម សម្តេចឪ-សម្តេចម៉ែ (បុរីអូរស្វាយ-សែនជ័យ)។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

ចន្លោះពីថ្ងៃទី៦ ដល់ទី៩ ខែសីហា ឆ្នាំ២០២៦ ក្រុមការងារអគារមរតកសង្គមរាស្ត្រនិយម សម្តេចឪ-សម្តេចម៉ែ (បុរីអូរស្វាយ-សែនជ័យ) នៃព្រះរាជបណ្ណាល័យហ្លួងម៉ែ បានផ្តល់រទេះរុញចំនួន៣គ្រឿង ដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលមានពិការភាព ដោយសារគ្រោះថ្នាក់ចរាចរណ៍ និងជំងឺប្រចាំកាយ រស់នៅក្នុងភូមិអូរស្វាយ ឃុំអូរស្វាយ ស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង។ ការផ្តល់ជូនរទេះរុញនាពេលនេះ មិនត្រឹមតែជួយសម្រួលដល់ការធ្វើដំណើរ និងការផ្លាស់ទីរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងស្តែងឱ្យឃើញពីការយកចិត្តទុកដាក់ខ្ពស់ចំពោះសង្គម ដោយមិនទុកនរណាម្នាក់ចោលឡើយ។ សកម្មភាពទាំងនេះ គឺជាការស្វែងរកដំណោះស្រាយចំពោះបញ្ហាប្រឈមនានាដែលអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមកំពុងជួបប្រទះក្នុងជីវភាពប្រចាំថ្ងៃ។

បន្ទាប់ពីទទួលបានរទេះរុញ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ទាំង៣រូប បានបង្ហាញនូវស្នាមញញឹម

ទឹកមុខរីករាយ និងក្តីសង្ឃឹមក្នុងការស្តារនូវសុខភាព និងការរស់នៅប្រចាំថ្ងៃរបស់ខ្លួនកាន់តែប្រសើរឡើងៗ ជំនួយស្មារតី និងសម្ភារទាំងនេះ មិនត្រឹមតែជួយសម្រួលបន្ទុកដល់គ្រួសារក្នុងការថែទាំប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបើកឱកាសឱ្យអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលមានពិការភាព ឬមិនអាចដើររួច អាចធ្វើដំណើរទៅពិនិត្យសុខភាពជាប្រចាំនៅមណ្ឌលសុខភាព «ព្រះនរោត្តម សីហនុរាជា និងសម្តេចព្រះវររាជមាតា នរោត្តម មុនិនាថ សីហនុ» អូរស្វាយ, ចូលរួមក្នុងសកម្មភាពសហគមន៍ និងវេទិកាចែករំលែកបទពិសោធន៍ក្នុងរបបខ្មែរក្រហម។ ជាមួយគ្នានេះ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ទាំង៣រូប បានសម្តែងនូវការអរគុណយ៉ាងជ្រាលជ្រៅចំពោះក្រុមការងារ នៃព្រះរាជបណ្ណាល័យ ហ្វូងម៉ែ ដែលតែងតែជួយគាំទ្រ និងមិនបោះបង់ចោលអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលកំពុងជួបប្រទះការលំបាក។

សកម្មភាពប្រគល់រទេះរុញ និងការចុះសួរសុខទុក្ខផ្ទាល់ដល់លំនៅឋាន មិនត្រឹមតែជាជំនួយសម្ភារសម្រាប់សម្រួលដល់ការរស់នៅប្រចាំថ្ងៃ និងការផ្លាស់ទីរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាការផ្តល់នូវការគាំទ្រផ្នែកស្មារតីដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ ស្របពេលដែលពេលវេលាកំពុងតែដើរទៅមុខ, សុខភាព និងការចងចាំរបស់អ្នករស់រានមានជីវិតដូចជា ទាវ ឆុន មានការឱនថយ ឬស្ទើរតែបាត់ការចងចាំទៅតាមវ័យ និងជំងឺប្រចាំកាយ ដែលទាមទារឱ្យមានការយកចិត្តទុកដាក់កាន់តែខ្លាំងបន្ថែមទៀត។

**ទាវ ឆុន** រស់នៅភូមិអូរស្វាយ ឃុំអូរស្វាយ ស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង និងជានិគមជនសង្គមរាស្ត្រនិយមមកពីខេត្តស្វាយរៀង ដែលត្រូវបានសម្តេចព្រះ នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋបញ្ជូនមករស់នៅបុរីអូរស្វាយ ក្នុងឆ្នាំ១៩៦៧។ បច្ចុប្បន្ន ទាវ ឆុន ធ្លាក់ខ្លួនពិការ ដោយសារតែជំងឺលើសឈាម អាចត្រឹមតែងើបអង្គុយ និងធ្វើចលនាបានខ្លះតែប៉ុណ្ណោះ។ ក្រោយពីធ្លាក់ខ្លួនឈឺ និងពិការ, ការចងចាំរបស់គាត់គឺមិនល្អដូចមុនទៀតឡើយ។ ខាងក្រោមនេះគឺជាប្រវត្តិសង្ខេបរបស់ ទាវ ឆុន និគមជនសង្គមរាស្ត្រនិយម និងជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម៖

ខ្ញុំឈ្មោះ ទាវ ឆុន អាយុ៨០ឆ្នាំ រស់នៅភូមិអូរស្វាយ ឃុំអូរស្វាយ ស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង។ ខ្ញុំគឺជានិគមជនសង្គមរាស្ត្រនិយមមកពីខេត្តស្វាយរៀង ដែលត្រូវបានសម្តេចព្រះ នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ បញ្ជូនមករស់នៅបុរីអូរស្វាយ នៅឆ្នាំ១៩៦៧។ ពេលនោះ ខ្ញុំទទួលបានរបបរួមមានផ្ទះ និងដីរស់នៅ ទំហំ៤០ម៉ែត្រ គុណ ៥០ម៉ែត្រ, ដីស្រែចម្ការ៥ហិចតា, គោមួយនឹម, និងប្រាក់ឧបត្ថម្ភ ៧៥០រៀលក្នុងមួយខែរយៈពេល៣០ខែ (២ឆ្នាំកន្លះ)។ ក្រោយមក ខ្ញុំបានរៀបការប្រពន្ធដែលជាប្រជាជនមកពីខេត្តព្រៃវែង និងមានកូនម្នាក់នៅពេលនោះ។ នៅថ្ងៃមួយនៅពេលដែលខ្ញុំទៅបើកប្រាក់ឧបត្ថម្ភប្រចាំខែ ខ្ញុំឃើញមានតួលេខសរុបប្រជាជនដែលត្រូវបានបញ្ជូនមករស់នៅបុរីអូរស្វាយ គឺសរុបទាំងអស់ចំនួនជាង៣០០គ្រួសារក្នុងផែនការគ្រោងទទួលប្រជាជនសរុបចំនួន៥០០គ្រួសារ។ ចំពោះហេដ្ឋារចនាសម្ព័ន្ធ ខ្ញុំឃើញមានមន្ទីរចាត់ការ, សាលាស្រុក, មន្ទីរពេទ្យ, ផ្សារសហគមន៍, ទីកន្លែងចុះចតឧទ្ធម្ភាគចក្រ, ផ្ទះ, សួនច្បារ និងស្តូបអនុស្សាវរីយ៍បុរីអូរស្វាយ។ នៅថ្ងៃទី១៧ ខែឧសភា ឆ្នាំ១៩៦៨ សម្តេចព្រះ នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ ព្រះអង្គយាងមកសម្ពោធសមិទ្ធផលនានានៅបុរីអូរស្វាយ។ ខ្ញុំ និងប្រពន្ធ រួមទាំងប្រជាជនរាប់ពាន់នាក់បានចូលរួមស្វាគមន៍ព្រះរាជដំណើរយាងមកសម្ពោធសមិទ្ធផលរបស់ព្រះអង្គ។ សម្តេចព្រះ នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ ព្រះអង្គយាងមកដល់អូរស្វាយនៅវេលាម៉ោងប្រហែល៩ព្រឹក តាមឧទ្ធម្ភាគចក្រចំនួន៣គ្រឿង និងចុះចតនៅទីកន្លែងចុះចតឧទ្ធម្ភាគចក្រ។ បន្ទាប់មក ព្រះអង្គយាងតាមក្បួនព្រះទីនាំងរថយន្តចំនួន៣គ្រឿង មកកាន់ទីតាំងអង្គពិធី។ មុនព្រះអង្គមានព្រះរាជសុន្ទរកថា ព្រះអង្គបានចែកក្រណាត់សមួយដុំ ប្រវែង២ម៉ែត្រ ដែលមានប៉ាក់អក្សរ «សង្គមរាស្ត្រនិយម» ជូនដល់ប្រជារាស្ត្រដែលជាកូនចៅរបស់ព្រះអង្គ។ ខ្ញុំ និងប្រពន្ធទទួលបានក្រណាត់សម្នាក់មួយដុំ និងបានចាប់ដៃរបស់ព្រះអង្គ។ ពេលនោះ ខ្ញុំពិតជាមានចិត្ត



វ័ន្ត ស៊ុន អតីតមេឃុំអូរស្វាយ អាយុ៨១ឆ្នាំ រស់នៅភូមិអូរស្វាយ ឃុំអូរស្វាយ ស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង និងជានិគមជនសង្គមរាស្ត្រនិយម ទទួលបានរទេះរុញពីក្រុមការងារអគាររមរតកសង្គមរាស្ត្រនិយម សម្តេចឪ- សម្តេចម៉ែ (បុរីអូរស្វាយ-សែនជ័យ)។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

សប្បាយរីករាយណាស់។ បន្ទាប់មក ព្រះអង្គមានព្រះរាជសុន្ទរកថាជិតមួយម៉ោង និងយាងទតតាមផ្ទះរបស់និគមជននៅបុរីអូរស្វាយ។ ខ្ញុំនិងក្រុមគ្រួសារបន្តប្រកបរបរធ្វើស្រែចម្ការ និងរស់នៅជាធម្មតា រហូតមានរដ្ឋប្រហារពី លន់ នល់ ទម្លាក់សម្តេចព្រះនរោត្តម សីហនុ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ទើបខ្ញុំនិងគ្រួសាររួមទាំងប្រជាពលរដ្ឋផ្សេងទៀតនៅបុរីអូរស្វាយ ទទួលរងគ្រោះដោយសារតែការទម្លាក់គ្រាប់បែក និងការចាប់យកទៅសម្លាប់ដោយសារតែជាប់ប្រវត្តិជានិគមជនសង្គមរាស្ត្រនិយម ក្នុងរបបខ្មែរក្រហម។

ប៉ុន្មានខែបន្ទាប់ពីរដ្ឋប្រហាររបស់ លន់ នល់ កងទ័ពខ្មែរក្រហមបានចូលមកគ្រប់គ្រងតំបន់អូរស្វាយ ដែលនាំឱ្យមានការទម្លាក់គ្រាប់បែកយ៉ាងសន្ធឹកសន្ធាប់ពីសហរដ្ឋអាមេរិក និងទាហាន លន់ នល់ រហូតបំផ្លាញហេដ្ឋារចនាសម្ព័ន្ធស្ទើរតែទាំងស្រុង។ បុរីអូរស្វាយ បានក្លាយជាសមរភូមិប្រយុទ្ធ រហូតដល់ឆ្នាំ១៩៧៣ ហើយខ្ញុំ និងគ្រួសារ មិនអាចរត់គេចខ្លួនទៅណាឡើយ ពីព្រោះបុរីអូរស្វាយ ហ៊ុមព័ទ្ធទៅដោយព្រៃក្រាស់ ហើយការធ្វើដំណើរចាកចេញគឺមានតែការជិះទូកតាមទន្លេមេគង្គ។ ក្រោយពីខ្មែរក្រហមបានកាន់កាប់បុរីអូរស្វាយទាំងស្រុង ប្រជាជនទាំងអស់ត្រូវខ្មែរក្រហមប្រមូលចូលក្នុងកងប្រវាស់ដៃដើម្បីធ្វើស្រែចម្ការ។ បន្ទាប់ពីខ្មែរក្រហមចូលកាន់កាប់ទីក្រុងភ្នំពេញ និងជម្លៀសប្រជាជនដោយបង្ខំ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ប្រជាជន១៧មេសា ឬប្រជាជនថ្មី សរុបចំនួនប្រហែល៥-៦គ្រួសារ បានធ្វើដំណើរមកដល់បុរីអូរស្វាយ ប៉ុន្តែភាគច្រើនបានស្លាប់ដោយសារជំងឺ កង្វះអាហារ ឬត្រូវចោទប្រកាន់ថាជា ភ្នាក់ងារ សេ-អ៊ី-អា ហើយត្រូវបានយកទៅសម្លាប់ចោល។

នៅឆ្នាំ១៩៧៦ ខ្មែរក្រហមបង្កើតសហករណ៍ចំនួនពីរនៅបុរីអូរស្វាយ ដែលតម្រូវឱ្យប្រជាជនធ្វើការជាទម្ងន់នៅតាមការដ្ឋាននានាឆ្ងាយពីភូមិ។ នៅឆ្នាំ១៩៧៧ ទោះបីជាប្រពន្ធខ្ញុំទើបសម្រាលកូនបានរយៈពេល៧ថ្ងៃ ខ្ញុំនិងប្រពន្ធត្រូវបានខ្មែរក្រហម

បំបែកនិងបង្ខំឱ្យទៅធ្វើការងាររៀងៗខ្លួន។ ខ្ញុំត្រូវបានបញ្ជូនឱ្យទៅលើកទំនប់តំបន់នៅអូរពួក ស្ថិតនៅស្រុកសេសាន ដោយទទួលបានរបបអាហារមិនគ្រប់គ្រាន់ឡើយ។ អ្វីដែលខ្ញុំមិនអាចបំភ្លេចបាននោះ គឺចាប់ពីពាក់កណ្ដាលឆ្នាំ១៩៧៨ ប្រជាជនទាំងអស់ត្រូវបានជម្លៀសទៅខាងកើតទន្លេសេកុង។ ពេលនោះ ខ្មែរក្រហមបានសើរើប្រវត្តិរូបដើម្បីកំណត់ប្រជាជន១៧ មេសា ដែលនៅសេសសល់ និងប្រជាជនជាប់ប្រវត្តិរបបសង្គមរាស្ត្រនិយមយកទៅសម្លាប់ចោល។ ខ្មែរក្រហមបង្ខំខ្ញុំ និងនិគមជនសង្គមរាស្ត្រនិយមផ្សេងទៀតឱ្យជីករណ្ដៅ ដោយបានភូតកុហកថា ជីកលេណដ្ឋានទុកការពារខ្លួន ប៉ុន្តែការពិតគឺសម្រាប់សម្លាប់ និងកប់និគមជនសង្គមរាស្ត្រនិយម ឬប្រជាជនរបស់សម្ដេចព្រះ នរោត្តម សីហនុ។ ជាសំណាងល្អ ខណៈពេលដែលយើងខ្ញុំកំពុងតែជីករណ្ដៅ កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា បានវាយរំដោះប្រជាជនពីការសម្លាប់របស់ខ្មែរក្រហម។ ខ្ញុំអាចគេចផុតពីសេចក្ដីស្លាប់ និងបានត្រឡប់មកភូមិវិញ ប៉ុន្តែមាននិគមជនសង្គមរាស្ត្រនិយមជាច្រើន ត្រូវបានខ្មែរក្រហមសម្លាប់។ នៅឆ្នាំ១៩៨០ ខ្ញុំត្រូវបានជ្រើសរើសឱ្យធ្វើជាមេភូមិ បន្ទាប់មកឡើងធ្វើជាមេឃុំរយៈពេល៧ឆ្នាំ ទើបចូលនិវត្តន៍។

**រ័ត្ន ស៊ុន** អតីតមេឃុំអូរស្វាយ អាយុ៨១ឆ្នាំ រស់នៅភូមិអូរស្វាយ ឃុំអូរស្វាយ ស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង និងជានិគមជនសង្គមរាស្ត្រនិយម។ រ័ត្ន ស៊ុន បានធ្លាក់ខ្លួនពិការ ដោយសារគ្រោះថ្នាក់ចរាចរណ៍។ បន្ទាប់ពីសម្រាកព្យាបាលមួយរយៈកន្លងមក រ័ត្ន ស៊ុន អាចដើរដោយប្រើប្រាស់ឈើច្រត់នៅក្បែរៗផ្ទះបាន។ ក្រោយពីធ្លាក់ខ្លួនឈឺ និងពិការ រ័ត្ន ស៊ុន មានការភ្លេចភ្លាំងរឿងរ៉ាវ និងបទពិសោធន៍របស់ខ្លួនរស់នៅក្នុងរបបខ្មែរក្រហម។ រ័ត្ន ស៊ុន បានរំឭកថា នៅក្នុងទសវត្សរ៍ឆ្នាំ១៩៦០ បុរីអូរស្វាយ មិនមែនត្រឹមតែជាភូមិឋានដាច់ស្រយាលមួយប៉ុណ្ណោះទេ ប៉ុន្តែជាទីដែលសម្ដេចព្រះ នរោត្តម សីហនុ បង្កើតឡើងដើម្បីការពារដែនអធិបតេយ្យភាពរបស់កម្ពុជា។ នៅក្នុងឆ្នាំ១៩៦៤ សម្ដេចព្រះ នរោត្តម សីហនុ បានយាងទស្សនកិច្ចមកកាន់បុរីអូរស្វាយ និងយាងជួបសំណេះសំណាលប្រជានុរាស្ត្រនៅក្នុងភូមិ ក្នុងនាមជានិមិត្តរូបនៃសេចក្ដីប្ដេជ្ញាចិត្តរបស់កម្ពុជា ដើម្បីរក្សាការពារទល់ដែនរបស់ខ្លួន។ មន្ត្រីរាជការចូលនិវត្តន៍ ដែលរួមមាន ទាហាន និងក្រុមគ្រួសារប្រជាជន ត្រូវបានបញ្ជូនឱ្យមករស់នៅក្នុងបុរីអូរស្វាយ ចំណែកហេដ្ឋារចនាសម្ព័ន្ធក្នុងតំបន់ ត្រូវបានរៀបចំកសាងជាបន្តបន្ទាប់។ ប្រសិនបើអំពើប្រល័យពូជសាសន៍ពុំបានកើតឡើងទេ បុរីអូរស្វាយអាចនឹងមានការអភិវឌ្ឍន៍កាន់តែល្អប្រសើរ ដែលរីកដុះដាលទាំងហេដ្ឋារចនាសម្ព័ន្ធ ការអប់រំ និងវិស័យកសិកម្ម។



ចេវ សន អាយុ៧៧ឆ្នាំ រស់នៅភូមិអូរស្វាយ ឃុំអូរស្វាយ ស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង និងជានិគមជនសង្គមរាស្ត្រនិយម ទទួលបានរទេះរុញពីក្រុមការងារអគារមរតកសង្គមរាស្ត្រនិយម សម្ដេចឪ-សម្ដេចម៉ែ (បុរីអូរស្វាយ-សែនជ័យ)។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

**ចេវ សន** អាយុ៧៧ឆ្នាំ រស់នៅភូមិអូរស្វាយ ឃុំអូរស្វាយ ស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង និងជានិគមជនសង្គមរាស្ត្រនិយម ដែលបានផ្លាស់ទីលំនៅពីខេត្តព្រៃវែង មករស់នៅបុរីអូរស្វាយ នៅក្នុងទសវត្សរ៍ឆ្នាំ១៩៦០។ ចេវ សន បានធ្លាក់ខ្លួនពិការមួយចំហៀងខ្លួន ដោយសារជំងឺលើសឈាម។ បច្ចុប្បន្ន ចេវ សន មានការចងចាំអំពីបទពិសោធន៍ក្នុងរបបខ្មែរក្រហមតិចជាងមុន ប៉ុន្តែគាត់នៅបន្តធ្វើលំហាត់ប្រាណជាប្រចាំដោយដើរក្បែរៗផ្ទះ។ ខាងក្រោមនេះ គឺជា

ប្រវត្តិសង្ខេបរបស់ ចេវ សន និគមជនសង្គមរាស្ត្រនិយម និងជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម៖

ខ្ញុំឈ្មោះ ចេវ សន អាយុ៧៧ឆ្នាំ រស់នៅភូមិអូរស្វាយ ឃុំអូរស្វាយ ស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង។ ខ្ញុំគឺជានិគមជនសង្គមរាស្ត្រនិយមមកពីខេត្តព្រៃវែង ដែលត្រូវបានសម្តេចព្រះ នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ បញ្ជូនឱ្យមករស់នៅបុរីអូរស្វាយ។ ខ្ញុំមានទីកន្លែងកំណើត នៅឃុំដូនកឹង ស្រុកកំចាយមារ ខេត្តព្រៃវែង។ ខ្ញុំមានប្រពន្ធឈ្មោះ វ៉ាត និងមានកូនប្រុសស្រីចំនួន៦នាក់ គឺស្រី១នាក់ និងប្រុស៥នាក់។ ខ្ញុំបានផ្លាស់មករស់នៅបុរីអូរស្វាយ តាំងពីសម័យសង្គមរាស្ត្រនិយម នៅពេលដែលសម្តេចព្រះ នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ បានកៀងគរប្រជាជនឱ្យមកតាំងទីលំនៅក្បែរព្រំដែន ដើម្បីចាប់ផ្តើមជីវិតរស់នៅលើទឹកដីថ្មី និងការពារបូរណភាពទឹកដី។ នៅពេលនោះ សម្តេចព្រះ នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ បានប្រគល់ផ្ទះមួយខ្នង, ដីស្រែចម្ការ៥ហិកតា, ដីភូមិ៦០ម៉ែត្រការ៉េ ព្រមទាំងឧបត្ថម្ភប្រាក់ខែអង្ករអំបិល និងសម្ភារប្រើប្រាស់ចាំបាច់ផ្សេងៗ ដល់ប្រជាជនដែលមកតាំងទីលំនៅនៅបុរីអូរស្វាយ។ នៅពេលដែលមកដល់ដំបូង ខ្ញុំបានឃើញការអភិវឌ្ឍន៍ជាច្រើនដូចជា សាលារៀន សួនច្បារ វត្តអារាម និងបន្ទាយទាហាន ហើយខ្ញុំធ្លាប់បានជួបសម្តេចព្រះ នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ ដោយផ្ទាល់ នៅពេលព្រះអង្គស្តេចយាងមកសម្ពោធសមិទ្ធផលនានា នៅបុរីអូរស្វាយ និងទទួលបានក្រណាត់សមួយដុំ។ នៅសម័យលន់ នល់ បុរីអូរស្វាយបានក្លាយជាគោលដៅទម្លាក់គ្រាប់បែកយ៉ាងខ្លាំងក្លាពីសំណាក់ទាហានអាមេរិក និងលន់ នល់ ដែលបំផ្លិចបំផ្លាញហេដ្ឋារចនាសម្ព័ន្ធស្ទើរតែទាំងស្រុង ហើយគ្រួសារខ្ញុំ និងអ្នកភូមិផ្សេងទៀតត្រូវនាំគ្នាជីកលេណដ្ឋានដើម្បីគេចពីគ្រាប់បែក។ ក្រោយមកទៀតបុរីអូរស្វាយ ត្រូវបានគ្រប់គ្រងដោយខ្មែរក្រហម ហើយខ្ញុំត្រូវបានជ្រើសរើសធ្វើជាកងទ័ពខ្មែរក្រហម។ ខ្ញុំត្រូវបានបញ្ជូនទៅប្រយុទ្ធនៅសមរភូមិរហូតដល់ជាយទីក្រុងភ្នំពេញ។ នៅពេលនោះ ខ្ញុំត្រូវបានទាហាន លន់ នល់ បាញ់បាក់ដៃឆ្វេង។ បន្ទាប់ពីខ្មែរក្រហមចូលកាន់កាប់ទីក្រុងភ្នំពេញ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំត្រូវបានដាក់ឱ្យធ្វើការងារនៅតាមអង្គភាព។ នៅពេលដែលកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា បានវាយរំដោះទីក្រុងភ្នំពេញ នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ អង្គភាពរបស់ខ្ញុំបានជិះរថយន្តគេចខ្លួនទៅដល់ព្រំដែនថៃ។ ដោយសារតែមិនមានផ្លូវអាចបន្តការធ្វើដំណើរតទៅមុខទៀត យើងសម្រេចចិត្តដុតបំផ្លាញរថយន្តទាំង១២គ្រឿងចោល ហើយបន្តដំណើរដោយថ្មើរជើង ចូលទៅក្នុងទឹកដីថៃ។ នៅទីនោះ អង្គការកាកបាទក្រហមអន្តរជាតិបានជួយព្យាបាលជំងឺ និងផ្តល់ស្បៀងអាហារ។ ក្រោយមក ខ្ញុំបានសម្រេចចិត្តវិលត្រឡប់មករស់នៅក្នុងប្រទេសកម្ពុជាវិញ ដោយបានមករស់នៅភូមិអូរស្វាយ រហូតមកដល់បច្ចុប្បន្ន។

សកម្មភាពប្រគល់រទេះរុញ និងការចុះសួរសុខទុក្ខផ្ទាល់ដល់លំនៅឋានអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមមិនត្រឹមតែជាជំនួយសម្ភារសម្រាប់សម្រួលដល់ការរស់នៅប្រចាំថ្ងៃ ដល់ការផ្លាស់ទីរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាការផ្តល់នូវការគាំទ្រផ្នែកស្មារតីឱ្យប្រសើរជាងមុនៗ ដោយសារវ័យកាន់តែច្រើនរួមជាមួយជំងឺប្រចាំកាយ ធ្វើឱ្យការចងចាំរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមមួយចំនួនស្ទើរតែបាត់បង់ ដែលទាមទារឱ្យមានការយកចិត្តទុកដាក់ថែរក្សាសុខភាពគាត់កាន់តែខ្លាំងថែមទៀត។



កុមាររស់នៅភូមិអូរស្វាយ ឃុំអូរស្វាយ ស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# យើងទាំងអស់គ្នាកំពុងរស់នៅលើ «ចំណុចពណ៌ខៀវស្លេក» តែមួយ តើហេតុអ្វីបានជាយើងនៅតែជ្រើសរើសសង្គ្រាម?

ព្រំ ផល្លា



កងទ័ពថៃចូលមកកាន់ប្រាសាទតាក្របី ស្ថិតនៅក្នុងឃុំគោកមន ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ ដោយខុសច្បាប់ អំឡុងពេលឈ្លានពានប្រទេសកម្ពុជា កាលពីខែកក្កដា និងខែធ្នូ ឆ្នាំ២០២៥។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅខែកុម្ភៈ ឆ្នាំ១៩៩០ យានអវកាស Voyager 1 របស់ NASA បានបង្វែរកាមេរ៉ារបស់ខ្លួនត្រឡប់មកថតផែនដីពីចម្ងាយប្រមាណ ៦,៤ ពាន់លានគីឡូម៉ែត្រ។ ផែនដីបានបង្ហាញខ្លួនជាចំណុចពន្លឺតូចមួយ ដែលអណ្តែតនៅក្នុងភាពងងឹតនៃលំហអាកាស។ លោក Carl Sagan បានហៅថា «ចំណុចពណ៌ខៀវស្លេក» (Pale Blue Dot)។ ពីចម្ងាយបែបនោះ គឺមិនមានព្រំដែនប្រទេសរបស់មនុស្សលោកយើងទេ។ គ្មានកម្ពុជា ឬថៃ រុស្ស៊ី ឬអ៊ុយក្រែន អ៊ីស្រាអែល ឬប៉ាឡេស្ទីន ឡើយ។ គ្មានកងទ័ព ទង់ជាតិ ឬមនោគមវិជ្ជានយោបាយទេ គឺមានតែដុំតូចមួយប៉ុណ្ណោះ។

ប៉ុន្តែទោះជាយ៉ាងនេះក្តី មនុស្សជាតិនៅតែបន្តធ្វើសង្គ្រាម។ សង្គ្រាមនៅអ៊ុយក្រែននៅតែបន្ត។ តំបន់ហ្គាហ្សានៅតែរងការបំផ្លិចបំផ្លាញ។ ប្រទេសស៊ូដង់នៅតែជាប់គាំងក្នុងសង្គ្រាម។ មីយ៉ាន់ម៉ានៅតែទទួលរងការប្រយុទ្ធប្រដាប់អាវុធផ្ទៃក្នុងប្រទេស។ កម្ពុជា និងថៃបានប៉ះទង្គិចក្នុងសង្គ្រាមជម្លោះព្រំដែនធ្ងន់ធ្ងរក្នុងឆ្នាំ២០២៥ ហើយភាពតានតឹងនេះនៅតែមានតាមបណ្តោយព្រំដែន។ ជម្លោះពាក់ព័ន្ធនឹង

សហរដ្ឋអាមេរិក អ៊ីស្រាអែល និងអ៊ីរ៉ង់ បានបង្ហាញថា ការប្រឈមមុខផ្នែកយោធាអាចរីករាលដាលយ៉ាងឆាប់រហ័ស ខណៈភាពតានតឹងនៅច្រកសមុទ្រតៃវ៉ាន់ នៅតែជាបញ្ហាគួរឱ្យព្រួយបារម្ភ។ ក្នុងពេលជាមួយគ្នានេះ ការចំណាយយោធាទូទាំងពិភពលោកបានកើនដល់កម្រិតខ្ពស់រហូតដល់ ២,៨៨៧ ពាន់លានដុល្លារអាមេរិក ក្នុងឆ្នាំ២០២៥។ គ្រោះថ្នាក់មិនមែនមានត្រឹមតែការដែលសង្គ្រាមនៅតែមាននោះទេ ប៉ុន្តែគ្រោះថ្នាក់ដែលពិភពលោកកំពុងប្រឈមគឺ យោធានិយមកំពុងក្លាយជារឿងធម្មតាឡើងវិញ។

ដើម្បីយល់ពីបញ្ហានេះ យើងត្រូវមើលថា តើព្រំដែន និងអត្តសញ្ញាណបានក្លាយជាអំណាចនយោបាយយ៉ាងដូចម្ដេច។ អាណានិគមនិយមបានកំណត់ឥទ្ធិពលលើព្រំដែន ស្ថាប័ន និងប្រព័ន្ធចំណេះដឹងជាច្រើននៅសម័យទំនើប។ ឧទាហរណ៍ ព្រំដែនកម្ពុជា–ថៃ ត្រូវបានប៉ះពាល់ដោយកិច្ចព្រមព្រៀងរវាងបារាំង និងសៀម។ នៅឆ្នាំ១៩៦២ តុលាការយុត្តិធម៌អន្តរជាតិបានសម្រេចថា ប្រាសាទព្រះវិហារ ស្ថិតនៅក្នុងដែនអធិបតេយ្យភាពរបស់កម្ពុជា។ ប៉ុន្តែប្រវត្តិសាស្ត្រមិនបានបញ្ចប់ត្រឹមសាលក្រមនោះទេ។ ព្រំដែនបានភ្ជាប់ជាមួយជាតិនិយម អធិបតេយ្យភាព និងការចងចាំអំពីប្រវត្តិសាស្ត្រ។ ខ្សែបន្ទាត់មួយនៅលើដែនទីអាចក្លាយជានិមិត្តសញ្ញានៃមោទនភាពជាតិ។ មោទនភាពអាចបង្កើតសម្ពាធនយោបាយ ហើយសម្ពាធនយោបាយអាចនាំទៅរកការចល័តកម្លាំងយោធា និងទីបំផុតនាំទៅរកសង្គ្រាម។

ទស្សនៈ «ការប៉ះទង្គិចរវាងអរិយធម៌» (Clash of Civilizations) របស់ Samuel Huntington ផ្ដល់នូវទស្សនៈមួយផ្សេងទៀត។ មនុស្សកំណត់អត្តសញ្ញាណខ្លួនថាជាខ្មែរ ថៃ អ៊ុយក្រែន រុស្ស៊ី ចិន តៃវ៉ាន់ អ៊ីស្រាអែល ប៉ាឡេស្ទីន ឬអ៊ីរ៉ង់។ អត្តសញ្ញាណផ្ដល់ឱ្យយើងនូវអារម្មណ៍ថា យើងជាសមាជិកនៃសហគមន៍មួយ ប៉ុន្តែវាអាចបង្កើតការបែងចែកជា «យើង» និង «ពួកគេ»។ ភាពខុសគ្នាអាចក្លាយជាការសង្ស័យ ការសង្ស័យអាចក្លាយជាការភ័យខ្លាច ហើយការភ័យខ្លាចអាចក្លាយជាការស្អប់។ ទោះជាយ៉ាងណា Huntington មិនអាចពន្យល់អំពីជម្លោះទាំងអស់បាននោះទេ។ អ្នកប្រាជ្ញនៅបន្ទាប់ពីអាណានិគម ដូចជា Edward Said រំឭកឱ្យយើងសួរថា តើអ្នកណាមានអំណាចក្នុងការកំណត់ថា «អ្នកដទៃ» ជានរណា ហើយតើចំណេះដឹង និងអំណាចរបស់អ្នកណាត្រូវបានទទួលស្គាល់។ អាណានិគមនិយម ជាតិនិយម និងអំណាច នៅតែបន្តមានឥទ្ធិពលលើរបៀបដែលសង្គមនានាយល់ពីខ្លួនឯង និងអ្នកដទៃ។

អ៊ុយក្រែន ហ្គាហ្សា និង ស៊ូដង់ បង្ហាញថា សង្គ្រាមមិនអាចត្រូវបានកាត់បន្ថយឱ្យនៅត្រឹមការប៉ះទង្គិចរវាងអរិយធម៌នោះទេ។ អ៊ុយក្រែនឆ្លុះបញ្ចាំងពីការប៉ះទង្គិចរវាងអត្តសញ្ញាណជាតិ ទឹកដី ប្រវត្តិសាស្ត្រ និងអំណាចយោធា។ ហ្គាហ្សា ឆ្លុះបញ្ចាំងពីការប្រសព្វគ្នារវាងទឹកដី អត្តសញ្ញាណ សន្តិសុខ ការបង្ខំឱ្យផ្លាស់ទីលំនៅ និងរបួសផ្លូវចិត្តខាងប្រវត្តិសាស្ត្រ។ ស៊ូដង់បង្ហាញថា សង្គ្រាមដ៏សាហាវអាចកើតឡើងជាចម្បងបណ្ដាលមកពីការតស៊ូដើម្បីអំណាចនយោបាយ និងយោធា។ មនុស្សមិនចាំបាច់មានអរិយធម៌ខុសគ្នាទេ ដើម្បីបង្កើតសត្រូវ។ យើងអាចធ្វើសង្គ្រាមជាមួយមនុស្សមកពីប្រទេសផ្សេងជាមួយមនុស្សក្នុងប្រទេសតែមួយ ឬសូម្បីតែជាមួយមនុស្សដែលនិយាយភាសាដូចគ្នា និងកាន់សាសនាដូចគ្នា។

ច្រកសមុទ្រ Hormuz ផ្ដល់នូវការព្រមានមួយទៀត។ ផ្លូវទឹកតូចចង្អៀតនេះ គឺជាចំណុចយុទ្ធសាស្ត្រដ៏សំខាន់សម្រាប់ការដឹកជញ្ជូនតាមសមុទ្រអន្តរជាតិ ហើយថាមពលសកលមួយភាគដ៏សំខាន់ត្រូវឆ្លងកាត់ទីនេះ។ ខ្ញុំមានអារម្មណ៍រន្ធត់ នៅពេលខ្ញុំបានអានសេចក្ដីថ្លែងការណ៍ថ្មីៗរបស់ Donald Trump ដែលថា លោកនឹងប្រកាសឱ្យច្រកសមុទ្រ Hormuz ក្លាយជាទឹកដីរបស់សហរដ្ឋអាមេរិកក្នុងពេលឆាប់ៗ។ សម្ដីនេះមិនថាវាជាវោហារសាស្ត្រនយោបាយ ឬជាសំណើជាក់ស្ដែងក៏ដោយ ប៉ុន្តែសេចក្ដីថ្លែងការណ៍នេះបានធ្វើឱ្យខ្ញុំមានការព្រួយបារម្ភយ៉ាងខ្លាំង។ វាធ្វើឱ្យខ្ញុំគិតថា បញ្ហាអធិបតេយ្យភាព និងការគ្រប់គ្រងទឹកដីអាចប្រែក្លាយយ៉ាងឆាប់រហ័សទៅជាដើមហេតុនៃការប្រឈមមុខគ្នា ដូចដែលប្រទេសមហាអំណាចបានដើរវាយដណ្ដើមយកប្រទេសតូចគ្មានអំណាចដើម្បីគ្រប់គ្រង នៅក្នុងគោលបំណងពង្រីកពង្រឹងសេដ្ឋកិច្ចរបស់ខ្លួននៅអំឡុងសករាជវាតទីអាណានិគម។ នៅពេលមេដឹកនាំដែលមានអំណាចនិយាយដូចជាទឹកដីអាចត្រូវបានរំលោភបំពានដើម្បីកាន់កាប់ ឬរៀបចំឡើងវិញតាមអំពើចិត្ត

គំនិតនេះនឹងអាចធ្វើទៅបានដូចជាធម្មតា ប៉ុន្តែវាជាអ្វីដែលយើងគួរព្រួយបារម្ភយ៉ាងខ្លាំង។

ច្រកសមុទ្រតៃវ៉ាន់បង្ហាញពីបញ្ហាសន្តិសុខស្រដៀងគ្នានេះដែរ។ ចិនចាត់ទុកតៃវ៉ាន់ថាជាទឹកដីរបស់ខ្លួន និងមិនបានបោះបង់ជម្រើសប្រើកម្លាំង ខណៈតៃវ៉ាន់កំពុងពង្រឹងសមត្ថភាពការពារខ្លួន ហើយសហរដ្ឋអាមេរិកនៅតែមានតួនាទីយុទ្ធសាស្ត្រដ៏សំខាន់នៅក្នុងតំបន់។ ភាគីនីមួយៗអាចចាត់ទុកសកម្មភាពរបស់ភាគីម្ខាងទៀតថាជាការគំរាមកំហែង។ ចិនពង្រឹងកងទ័ព តៃវ៉ាន់ពង្រឹងការការពារ ហើយសហរដ្ឋអាមេរិកពង្រឹងវត្តមានយុទ្ធសាស្ត្ររបស់ខ្លួននៅក្នុងតំបន់។ ការទប់ស្កាត់អាចជួយការពារសង្គ្រាម ប៉ុន្តែវាអាចបង្កើតអសន្តិសុខជាអចិន្ត្រៃយ៍។ គ្រោះថ្នាក់មិនមែនមានត្រឹមការឈ្លានពានទេ។ វាអាចជាការវាយតម្លៃខុស ដូចជាសមយុទ្ធយោធាត្រូវបានយល់ច្រឡំ ការតាមស្កាត់យន្តហោះចម្បាំង ជាដើម ឬសេចក្តីថ្លែងការណ៍នយោបាយមួយត្រូវបានបកស្រាយថាជាការបង្កហេតុ។ ទាំងអស់នេះសុទ្ធតែជាកង្វល់ដែលជាហេតុនៃភាពតានតឹង និងការប៉ះទង្គិច។

ការផ្លាស់ប្តូររបស់ប្រទេសជប៉ុនពីសន្តិភាពនិយម និងការកើនឡើងនៃសមត្ថភាពយោធារបស់ពិភពលោក រួមជាមួយការបន្តមានអាវុធនុយក្លេអ៊ែរ បង្ហាញពីភាពផ្ទុយគ្នាដ៏គួរឱ្យព្រួយបារម្ភមួយទៀត។ ប្រសិនបើគ្រប់ប្រទេសឆ្លើយតបនឹងអសន្តិសុខដោយបង្កើនការបំពាក់អាវុធឱ្យកាន់តែច្រើន ពិភពលោកអាចនឹងកាន់តែមិនមានសុវត្ថិភាព។ SIPRI ប៉ាន់ប្រមាណថា នៅដើមឆ្នាំ២០២៦រដ្ឋចំនួន៩ មានក្បាលគ្រាប់នុយក្លេអ៊ែរប្រមាណ ១២,១៨៧ គ្រាប់។ ការទប់ស្កាត់ដោយប្រើអាវុធនុយក្លេអ៊ែរ នៅទីបំផុតពឹងផ្អែកលើការវិនិច្ឆ័យរបស់មនុស្ស ហើយមនុស្សអាចធ្វើការវាយតម្លៃខុស។

ប្រហែលជាអាវុធដែលគ្រោះថ្នាក់បំផុត មិនមែនជាមីស៊ីល ឬនុយក្លេអ៊ែរទេ ប៉ុន្តែជាគំនិតអំពី«សត្រូវ»។ អាវុធមិនចេះស្អប់ទេ។ មនុស្សជាអ្នកបង្កើតគំនិតថា តើអ្នកណាគួរត្រូវបានការពារ និងអ្នកណាគួរត្រូវបានចាត់ថាជាក្រុមគ្រោះថ្នាក់សម្រាប់ក្រុមខ្លួន។ ប្រវត្តិសាស្ត្ររំឭកយើងអំពីរបៀបដែលអំណាចអាចកំណត់ព្រំដែន និងអត្តសញ្ញាណរបស់មនុស្ស។ Huntington រំឭកយើងថា អត្តសញ្ញាណអាចបែងចែកមនុស្ស។ ចំណែក Sagan រំឭកយើងថា ការបែងចែកទាំងអស់នេះកើតឡើងនៅលើភពតូច និងងាយរងគ្រោះតែមួយនេះ។

សូមស្រមៃថា Voyager 1 កំពុងសម្លឹងមើលផែនដីពីចម្ងាយនៅថ្ងៃនេះ ដែលនឹងមិនឃើញ អ៊ុយក្រែន ហ្គាហ្សា ស៊ូដង់ ព្រំដែនកម្ពុជា–ថៃ តៃវ៉ាន់ អ៊ីរ៉ង់ ឬឃ្លាំងអាវុធនុយក្លេអ៊ែរទេ។ វានឹងឃើញតែពិភពពណ៌ខៀវតូចមួយដដែល។

នេះមិនមានន័យថា ព្រំដែន អធិបតេយ្យភាព ឬសន្តិសុខជាតិមិនសំខាន់នោះទេ។ វាសំខាន់។ ប៉ុន្តែខ្សែព្រំដែនគ្រប់ប្រទេស និងកងទ័ពទាំងអស់ សុទ្ធតែមានទីតាំងនៅលើភពតែមួយ។ គ្រប់សង្គ្រាមកើតឡើងនៅទីនេះ។ ជនភៀសខ្លួនគ្រប់រូបត្រូវបានបង្ខំឱ្យចាកចេញពីកន្លែងមួយទៅកន្លែងមួយនៅលើភពនេះ។ ទីក្រុងដែលត្រូវបានបំផ្លាញគ្រប់ទីកន្លែង សុទ្ធតែជាផ្នែកមួយនៃភពនេះ។ កុមារគ្រប់រូបដែលកើតក្នុងសង្គ្រាម កើតនៅទីនេះដែរ។ យើងគ្មានកន្លែងផ្សេងទៀតឡើយ។

Sagan បានពិពណ៌នាផែនដីថា ជា «ដុំដីតូចមួយនៅក្នុងលំហអាកាសដ៏ធំធេង»។ លោកបានព្រមានអំពីទន្លេឈាមដែលត្រូវបានបង្ហូរដោយមេទ័ព និងអធិរាជ ដើម្បីស្វែងរកការគ្រប់គ្រងជាបណ្តោះអាសន្នលើផ្នែកតូចមួយនៃពិភពលោកដ៏តូចនេះ។ ទស្សនរបស់លោកនៅតែមានភាពពាក់ព័ន្ធយ៉ាងឈឺចាប់ជាមួយពិភពលោកសព្វថ្ងៃ។

យើងបានរៀនពីរបៀបធ្វើដំណើរទៅកាន់លំហអាកាស បំបែកអាតូម បង្កើតអាវុធដែលអាចបំផ្លាញទីក្រុង និងបញ្ជូនម៉ាស៊ីនទៅឆ្ងាយហួសពីភពផែនដីរបស់យើង។ ប៉ុន្តែ តើយើងបានរៀនពីរបៀបរស់នៅជាមួយគ្នាដែរឬទេ?

អង្គការសហប្រជាជាតិអំពាវនាវឱ្យយើងជ្រើសរើសសន្តិភាព ការចរចា និងច្បាប់អន្តរជាតិ។ យើងគ្មានផែនដីទីពីរ គ្មានផ្ទះទីពីរ និងគ្មានឱកាសទីពីរឡើយ។

យើងទាំងអស់គ្នាកំពុងរស់នៅលើផែនដីដែលជាចំណុចពណ៌ខៀវតូចស្តួចតែមួយ។ ប្រហែលជាដល់ពេលហើយ ដែលយើងគួរគិតឡើងវិញថា ប្រសិនបើយើងមិនអាចរស់នៅជាមួយគ្នាបាន តើមានកន្លែងណាទៀតដែលយើងអាចរស់នៅបាន?

# យុវនារីក្នុងស្រុកអន្លង់វែងទស្សនកិច្ចសិក្សា នៅកាន់សារមន្ទីរផ្ទះ តាម៉ុក

**មេក ឌិន**





យុវនារីនៅស្រុកអន្លង់វែងធ្វើទស្សនកិច្ចសិក្សាសារមន្ទីរផ្ទះ តាម៉ុក នៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២៦ ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២៦ យុវនារីនៅស្រុកអន្លង់វែង បានធ្វើដំណើរមកទស្សនកិច្ចសិក្សានៅសារមន្ទីរផ្ទះ តាម៉ុក ក្រោមការសម្របសម្រួលពីមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។ ដំណើរទស្សនកិច្ចសិក្សានាថ្ងៃនេះ មានគោលបំណងលើកកម្ពស់ការយល់ដឹងអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ព្រឹត្តិការណ៍ក្រោយឆ្នាំ១៩៧៩ និងការកសាងសន្តិភាពដល់យុវជនជំនាន់ក្រោយ។

យុវនារីនឹងបានស្វែងយល់ពីប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ និងការធ្វើសមាហរណកម្មរបស់កម្លាំងខ្មែរក្រហមចុងក្រោយនៅស្រុកអន្លង់វែងជាមួយរាជរដ្ឋាភិបាលកម្ពុជា តាមរយៈការធ្វើបទបង្ហាញអំពីសន្តិភាពរបស់បុគ្គលិកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។ នៅក្នុងនោះ មានការលើកឡើងអំពីការផ្សះផ្សា និងការយល់ដឹងពីតម្លៃសន្តិភាព ការផ្លាស់ប្តូរផ្នត់គំនិត ការពង្រឹងស្មារតីអត់ឱនដើម្បីផ្សះផ្សាជាតិ និងការទប់ស្កាត់អំពើប្រល័យពូជសាសន៍មិនឱ្យកើតមានជាសាជាថ្មី រួមទាំងការស្រាវជ្រាវផ្ទាល់ពីវត្ថុតាងបណ្តុះជំនាញវិភាគ សាកសួរព័ត៌មាន និងការកត់ត្រាប្រវត្តិសាស្ត្រទាក់ទងទីតាំងជាក់ស្តែង។

នៅទីតាំងសារមន្ទីរផ្ទះ តាម៉ុក ក្នុងស្រុកអន្លង់វែង គឺផ្ទះបញ្ចាំងពីប្រវត្តិសាស្ត្រយ៉ាងជូរចត់ និងការវិវត្តនៃរបបខ្មែរក្រហម តាំងពីចំណុចចាប់ផ្តើមរហូតដល់ថ្ងៃដួលរលំចុងក្រោយ តាមរយៈការតាំងពិព័រណ៍រូបថតចំនួន១០០ផ្ទាំង។ ផ្ទះទី៣របស់ តាម៉ុក ដើមឡើយ ត្រូវបានប្រើប្រាស់សម្រាប់ទទួលសមាជិកគ្រួសារ និងប្រជាជនដែលមកស្នើសុំស្រូវអង្ករ ឬគោក្របី។ ប៉ុន្តែបច្ចុប្បន្ន នៅក្នុងបរិវេណផ្ទះទាំងនេះ ត្រូវប្រែក្លាយជា

កន្លែងដាក់តាំងរូបថតប្រវត្តិសាស្ត្រ និងផ្ទាំងរូបថតចំនួន ១០០ ដើម្បីទុកជាមេរៀនអប់រំសន្តិភាព។ រូបថតទាំង ១០០សន្លឹក គឺជាភស្តុតាងមិនអាចប្រកែកបាននៃរបបវាលពិឃាត។ រូបភាពនៃពិព័រណ៍បានបង្ហាញពីការរស់នៅយ៉ាងវេទនា ការបង្អត់អាហារ និងការកាប់សម្លាប់ ដែលយុវជនជំនាន់ក្រោយត្រូវសិក្សាដើម្បីយល់ពីផលវិបាកនៃសង្គ្រាមស៊ីវិល។ រូបភាពខ្លះបង្ហាញពីព្រឹត្តិការណ៍ធ្វើសមាហរណកម្ម និងការទម្លាក់អាវុធរបស់កងទ័ពខ្មែរក្រហមចុងក្រោយនៅស្រុកអន្លង់វែង ក្នុងឆ្នាំ១៩៩៨។ រូបភាពទាំងនេះបង្ហាញពីការបិទទំព័រប្រវត្តិសាស្ត្រដ៏ខ្មៅងងឹត និងការចាប់ផ្តើមកសាងនយោបាយ ឈ្នះ-ឈ្នះ ដែលនាំមកនូវឯកភាពជាតិពេញលេញ។

ដំណើរទស្សនកិច្ចសិក្សាបានប្រព្រឹត្តទៅយ៉ាងរលូនដោយមានការណែនាំយ៉ាងយកចិត្តទុកដាក់ពីក្រុមការងារមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។ បន្ថែមលើនេះ សិស្សបានស្តាប់បទបង្ហាញដោយសង្ខេបអំពីប្រវត្តិស្រុកអន្លង់វែង និងការជ្រើសរើសទីតាំង ផ្ទះតាម៉ុក នៅក្បែរប្រព័ន្ធទឹក ដែលជាចំណុចយុទ្ធសាស្ត្ររបស់យោធាខ្មែរក្រហម។

តាមរយៈការផ្តួចផ្តើមរបស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ដំណើរទស្សនកិច្ចសិក្សានេះទទួលបានលទ្ធផលគួរឱ្យកត់សម្គាល់ ការផ្លាស់ប្តូរការយល់ដឹងរបស់សិស្សមិនត្រឹមតែស្គាល់ប្រវត្តិសាស្ត្រតែប៉ុណ្ណោះទេ ប៉ុន្តែបានយល់កាន់តែច្បាស់ពីផលវិបាកនៃសង្គ្រាម និងតម្លៃដ៏មហាសាលនៃសន្តិភាពដែលកំពុងមានសព្វថ្ងៃ។ នៅក្នុងដំណើរទស្សនកិច្ចនេះ សិស្សានុសិស្សទទួលបានសៀវភៅ ឯកសារ និងខិត្តប័ណ្ណព័ត៌មានទាក់ទងនឹងប្រវត្តិសាស្ត្រ ដែលចងក្រងដោយមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង សម្រាប់សិក្សាបន្ថែម។ លើសពីនេះ ដំណើរទស្សនកិច្ចសិក្សានេះបានបង្កើនភាពស្និទ្ធស្នាល បង្កើតស្មារតីចេះជួយគ្នា និងការសហការគ្នាយ៉ាងស្អិតរមួតរវាងយុវជន និងសហគមន៍។

ដំណើរទស្សនកិច្ចសិក្សាទៅកាន់សារមន្ទីរផ្ទះតាម៉ុក ក្រោមការផ្តួចផ្តើមរបស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ពិតជាមានតម្លៃ និងអត្ថន័យជ្រាលជ្រៅបំផុតសម្រាប់ការអប់រំ និងបំប្លែងអតីតសមរភូមិសង្គ្រាមឱ្យទៅជាថ្នាក់រៀនអប់រំសន្តិភាពដ៏រស់រវើក។



សារមន្ទីរផ្ទះ តាម៉ុក នៅក្នុងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ថតនៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២៦។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)





បុគ្គលិកថែទាំសារមន្ទីរផ្ទះ តាម៉ុក ដាំបន្លែ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# សិស្សសាលាបឋមសិក្សា ប៊ុន រ៉ានី ហ៊ុន សែន កោះថ្ម មកទស្សនាពិព័រណ៍រូបថត និងសិក្សា

## ស្វែងយល់ពីប្រវត្តិសាស្ត្រខ្មែរក្រហម នៅមជ្ឈមណ្ឌលឯកសារកោះថ្ម

*ឈុំ វ៉ា*



សិស្សសាលាបឋមសិក្សា ប៊ុនរ៉ានី ហ៊ុនសែន កោះថ្ម ចំនួន១៨នាក់ មកទស្សនាពិព័រណ៍រូបថត និងសិក្សាស្វែងយល់ពីប្រវត្តិសាស្ត្រខ្មែរក្រហម នៅមជ្ឈមណ្ឌលឯកសារកោះថ្ម នៅព្រឹកថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២៦ ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



នៅព្រឹកថ្ងៃទី១៧ ខែសីហាឆ្នាំ២០២៦ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្មបានទទួលសិស្ស សាលាបឋមសិក្សា ប៊ុនរ៉ានី ហ៊ុនសែន កោះថ្មចំនួន១៨នាក់ មកទស្សនាពិព័រណ៍រូបថតទាក់ទងនឹងប្រវត្តិសាស្ត្រខ្មែរក្រហម។

ជាកិច្ចចាប់ផ្តើម លោក ឈុំ វ៉ា បុគ្គលិកប្រចាំការនៅមជ្ឈមណ្ឌលឯកសារកោះថ្មដឹកនាំសិស្សទស្សនាពិព័រណ៍រូបថតដែលបានបន្សល់ទុកតាំងពីទសវត្សរ៍ឆ្នាំ១៩៦០ ដល់ ទសវត្សរ៍ឆ្នាំ១៩៩០ នៅក្នុងទីតាំងមជ្ឈមណ្ឌលឯកសារកោះថ្ម។ បន្ថែមលើនេះ សិស្សអាចទស្សនាពិព័រណ៍រូបថតនិងផ្ទាំងគំនូរ ស្តីពីប្រវត្តិ-សាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងពិព័រណ៍ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនៃដំណើរឆ្ពោះទៅផ្តួលរំលំរបបប្រល័យពូជសាសន៍ថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៧។

លោក ឈុំ វ៉ា រៀបរាប់ថា នៅឆ្នាំ១៩៧៥ ប្រជាជនរស់នៅតំបន់កោះថ្ម ត្រូវបានខ្មែរក្រហមចាត់តាំងឱ្យធ្វើការងារស្រែចម្ការ ជាក្រុមប្រវាស់ដៃ ដោយជួយធ្វើការងារគ្នាទៅវិញទៅមក។ នៅពេលប្រជាជនធ្វើស្រែចម្ការមួយកន្លែងរួច ទើបបន្តទៅធ្វើមួយកន្លែង

ទៀត រហូតទាល់តែរួចរាល់គ្រប់ទីតាំងទើបឈប់។ បន្ទាប់មក ខ្មែរក្រហមបានបង្កើតជាសហករណ៍កម្រិតទាប។ នៅខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញឱ្យមករស់នៅតាមជនបទស្រុកស្រែចម្ការ។ ខ្មែរក្រហមចាត់តាំងប្រជាជនមកដល់ថ្មីទាំងនោះឱ្យទៅរស់នៅភូមិបេងកោង ភូមិក្តុលលើ ភូមិកោះថ្ម ស្ថិតនៅក្នុងឃុំទន្លូង ឃុំរំចេក និងឃុំជាំតាម៉ៅ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។

នៅឆ្នាំ១៩៧៦ ខ្មែរក្រហមបានបង្កើតជាសហករណ៍កម្រិតខ្ពស់ឱ្យធ្វើការងាររួម ហូបរួម ដេករួម នៅតំបន់កោះថ្ម។ សូម្បីសត្វគោ ក្របី ទ្រព្យសម្បត្តិ មាស ប្រាក់ ចាន ឆ្នាំង គឺខ្មែរក្រហមប្រមូលពីប្រជាជនយកទៅដាក់ក្នុងសហករណ៍រួម។ បន្ទាប់មកខ្មែរក្រហមជ្រើសរើសកម្លាំងយុវជនយុវនារីយកទៅធ្វើជាយោធា កងចល័ត និងធ្វើជាគ្រូពេទ្យទៅតាមភូមិ ឃុំ ស្រុក។ នៅឆ្នាំ១៩៧៧ ក្រោយពេលខ្មែរក្រហមជ្រើសរើសកម្លាំងឱ្យចូលទៅធ្វើការងារតាមអង្គភាពនីមួយៗរួច បក្សកុម្មុយនីស្តកម្ពុជាបានធ្វើការចោទប្រកាន់ថា ប្រជាជននៅភូមិភាគបូព៌ាបានចូលដៃចូលជើងជាមួយវៀតណាម «មនុស្សក្បាលយួនខ្លួនខ្មែរ» ដែលក្បត់បដិវត្តន៍ និងក្បត់អង្គការ។

នៅឆ្នាំ១៩៧៨ កងទ័ពភូមិភាគនិរតីចូលមកចាប់អ្នកធ្លាប់ធ្វើជាប្រធានកងតូច ប្រធានកងធំ អតីតទាហានលន់ នល់ គ្រូបង្រៀន គ្រូពេទ្យនៅតាមភូមិ ឃុំ ក្នុងភូមិភាគបូព៌ាយកទៅកសាង និងសម្លាប់ចោល។ ខ្មែរក្រហមជម្លៀសប្រជាជនរស់នៅតំបន់កោះថ្មដោយបង្ខំឱ្យទៅបង្កបង្កើនផលនៅតាមភូមិ ឃុំ ស្រុកមួយចំនួននៃខេត្តក្រចេះ ខេត្តកំពង់ចាម និងខេត្តកំពង់ធំ។ ចំណែកប្រជាជនមួយចំនួនទៀតបានរត់គេចខ្លួនទៅប្រទេសវៀតណាម។ ប្រជាជនរស់នៅតំបន់កោះថ្មត្រូវខ្មែរក្រហមចាត់ទុកជាប្រជាជនថ្មី ឬជាប្រជាជនត្រៀម។ ប្រជាជនជាច្រើនបានស្លាប់នៅឃុំស្វាយជ្រះ ឃុំឃ្សឹម ស្រុកស្នួល ខេត្តក្រចេះ ដោយសារធ្វើការងារលើសកម្លាំង ឃ្លាន គ្មានថ្នាំពេទ្យព្យាបាល គ្មានអាហារហូបគ្រប់គ្រាន់ និងត្រូវខ្មែរក្រហមសម្លាប់។

នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ របបប្រល័យពូជសាសន៍ប៉ុល ពត ដួលរលំ ពេលនោះប្រជាជននាំគ្នាត្រឡប់មកភូមិស្រុករៀងៗខ្លួនវិញ។ ប្រជាជនខ្លះត្រូវធ្វើដំណើរដោយថ្មើរជើង និងអ្នកខ្លះទៀតបានសុំរថយន្តកងទ័ពវៀតណាមជិះ។ ពេលប្រជាជនត្រឡប់ដល់ភូមិដំបូង គឺមានការខ្វះខាតស្រូវ អង្ករហូបចុក ដូច្នេះគ្រួសារមួយចំនួនបានយកមាស ប្រាក់ និងសម្ភារមានតម្លៃទៅប្តូរយកស្រូវពូជនៅប្រទេសវៀតណាម និងប្រជាជខ្លះទៀតត្រូវទៅរកស្រូវពូជនៅស្រុកស្នួល ខេត្តក្រចេះ ដែលសេសសល់ពីភ្លើងឆេះ។

ក្រោយពីនេះ លោក ឈុំ វ៉ា បានលើកយករឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ឈ្មោះ គង់ ឈន មកអានឱ្យសិស្សស្តាប់ ដូចខាងក្រោម៖

ខ្ញុំឈ្មោះ **គង់ ឈន** ភេទប្រុស អាយុ៧៦ឆ្នាំ កើតនៅភូមិល្វា ឃុំទន្លូង ស្រុកមេមត់ ខេត្តកំពង់ចាម។ បច្ចុប្បន្នខ្ញុំរស់នៅភូមិល្វាលើ ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ខ្ញុំមានឪពុកឈ្មោះ គង់ ម្តាយឈ្មោះ ញឹង និងមានបងប្អូនចំនួន៤នាក់ ហើយខ្ញុំគឺជាកូនទី៣។ ឪពុកម្តាយខ្ញុំបានស្លាប់នៅក្នុងរបបខ្មែរក្រហមដោយសារអត់បាយ។ ខ្ញុំមានប្រពន្ធឈ្មោះ ញឿក សាប៊ិន អាយុ៦៧ឆ្នាំ និងមានកូនចំនួន១០នាក់។ កូនរបស់ខ្ញុំបានស្លាប់អស់ចំនួន៤នាក់ ហើយរាល់ថ្ងៃនៅរស់តែ៦នាក់ប៉ុណ្ណោះ។

កាលពីកុមារភាពខ្ញុំបានរៀននៅវត្តកន្ទួត ឃុំជាំតាម៉ៅ ស្រុកមេមត់ ដោយមានគ្រូបង្រៀនជាព្រះសង្ឃ។ ខ្ញុំបានដើរកាត់ព្រៃទម្រាំដល់វត្តកន្ទួត ដោយប្រើពេលវេលាសឹងពេញមួយថ្ងៃ។ ពេលនោះមានក្មេងៗស្របាលខ្ញុំបានទៅធ្វើជាកូនសិស្សលោកដូចខ្ញុំដែរ។ ក្នុងមួយថ្ងៃ ខ្ញុំរៀនពីរវេន គឺវេនព្រឹកបន្ទាប់ពីព្រះសង្ឃឆាន់រួច និងវេនយប់។ ខ្ញុំបានរៀនអក្សរខ្មែរ និងរៀនធម៌។ កាលនៅក្មេងឪពុកម្តាយជំរុញឱ្យខ្ញុំបួស ព្រោះជំនាន់នោះអ្នកដែលបានបួសរៀន គឺជាអ្នកចេះដឹង ហើយទៅណាមកណាមានប្រជាជនស្រឡាញ់ចូលចិត្តច្រើន។ ប៉ុន្តែខ្ញុំរៀននៅវត្តបានរយៈពេល៣ខែតែប៉ុណ្ណោះ ខ្ញុំត្រឡប់មកផ្ទះវិញ។

នៅដើមឆ្នាំ១៩៧៥ កងទ័ពរំដោះខ្មែរក្រហមបានចាប់ផ្ដើមរៀបចំកងឈ្លបការពារនៅក្នុងភូមិ និងជ្រើសរើសប្រជាជនឱ្យធ្វើជាកងឈ្លប។ នៅឆ្នាំ១៩៧៦ ខ្មែរក្រហមជម្លៀសប្រជាជនចេញពីភូមិឱ្យទៅនៅភូមិពងទឹក ឃុំទន្លូង ស្រុកមេមត់។ ខ្ញុំនិងប្រពន្ធកូនត្រូវខ្មែរក្រហមជម្លៀសឱ្យទៅឃុំស្វាយជ្រះ ស្រុកស្នួល ខេត្តក្រចេះ។ ប្រធានឃុំស្វាយជ្រះ ចាត់តាំងខ្ញុំឱ្យទៅលើកទំនប់ និងជីកប្រឡាយសម្រាប់ស្តុកទឹកបញ្ចូលស្រែ។ ចំណែកប្រពន្ធខ្ញុំត្រូវទៅស្ទូងស្រូវនៅក្រុមផ្សេង ចំណែកឪពុកម្ដាយខ្ញុំត្រូវខ្មែរក្រហមបញ្ជូនឱ្យទៅនៅម្ចិប ស្ថិតនៅក្នុងឃុំស្វាយជ្រះ ស្រុកស្នួល ខេត្តក្រចេះ ដើម្បីកាស់គល់ឈើរានដីធ្វើស្រែ។

ពេលនោះកូនខ្ញុំអាយុ២ឆ្នាំ ត្រូវយកទៅផ្ញើជាមួយចាស់ៗឱ្យមើលថែ ស្រាប់តែពេលខ្ញុំត្រឡប់មកពីលើកទំនប់វិញ ខ្ញុំឃើញកូនដេកស្លាប់នៅក្នុងកូនខ្ទមតូចមួយស្ថិតនៅកណ្ដាលវាលស្រែ។ ខ្ញុំបានបីសពកូនយកទៅកប់នៅក្នុងព្រៃក្បាលស្រែឃុំស្វាយជ្រះ ស្រុកស្នួល ខេត្តក្រចេះ។ ពេលប្រពន្ធខ្ញុំត្រឡប់មកពីស្ទូងបានសួរខ្ញុំថា ឯណាអាអូន? ខ្ញុំអួលដើមកនិយាយមិនចង់ចេញឡើយ។ ខ្ញុំបានប្រាប់ប្រពន្ធថាកូនយើងស្លាប់បាត់ហើយ សូម្បីបងមកដល់មិនបានទាន់ដង្ហើមកូន។ ក្រៅពីកូនខ្ញុំ មានបងប្រុសខ្ញុំធ្វើយោធាខ្មែរក្រហមស្លាប់នៅព្រែកទេរ ឃុំបុសលាវ ស្រុកចិត្របុរី ខេត្តក្រចេះ អំឡុងពេលវាយប្រយុទ្ធគ្នា។ ចំណែកឪពុកខ្ញុំស្លាប់នៅម្ចិបដោយសារអត់បាយ។ គ្រួសារខ្ញុំត្រូវខ្មែរក្រហមជម្លៀសចេញពីឃុំស្វាយជ្រះ ទៅនៅថ្មគ្រែ ឃុំថ្មគ្រែ ស្រុកចិត្របុរី ខេត្តក្រចេះ ដើម្បីរង់ចាំកប៉ាល់ដឹកឆ្លងទៅស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម។ ពេលទៅដល់ស្រុកស្ទឹងត្រង់ខ្ញុំនិងប្រពន្ធឡើងរថយន្តទៅស្រុកចំការលើ ខេត្តកំពង់ចាម ដើម្បីប្រូតស្រូវទុំ។ នៅទីនោះខ្ញុំហូបចុកគ្រប់គ្រាន់ មិនខ្វះខាតទេ។ ខ្ញុំរស់នៅចំការលើបានរយៈពេល២ខែ កងទ័ពវៀតណាមចូលមកដល់និងប្រកាសឱ្យប្រជាជនត្រឡប់មកស្រុកកំណើតរៀងៗខ្លួន។

ជាចុងបញ្ចប់នៃការទស្សនាពិព័រណ៌រូបថត និងការសិក្សាស្វែងយល់ពីប្រវត្តិសាស្ត្រខ្មែរក្រហម បុគ្គលិកមជ្ឈមណ្ឌលឯកសារកោះថ្ម បានចែកទស្សនាវដ្ដីស្វែងរកការពិតដល់សិស្សានុសិស្សសម្រាប់ សិក្សាស្រាវជ្រាវ ហើយសិស្សានុសិស្សបង្ហាញពីចំណាប់អារម្មណ៍ដូចខាងក្រោម៖

**នី ស្រីលាប** ៖ «ខ្ញុំពិតជាមានអារម្មណ៍សប្បាយរីករាយ ពេលបានចូលរួមទស្សនាពិព័រណ៌នៅក្នុងមជ្ឈមណ្ឌលឯកសារកោះថ្ម។ ខ្ញុំបានដឹងពីបងៗក្រុមការងារធ្វើបទបង្ហាញទាក់ទងអំពីផ្ទាំងរូបថត និងនិយាយប្រាប់ពីហេតុការណ៍ជម្លៀសប្រជាជនចេញពីស្រុកកំណើតឱ្យទៅរស់នៅតាមភូមិស្រុកផ្សេងៗ និងឱ្យប្រជាជនធ្វើការងារគ្មានពេលឈប់សម្រាក។ ខ្ញុំពិតជាមានអារម្មណ៍ឈឺចាប់ និងអាណិតចំពោះយាយតាដែលធ្លាប់ឆ្លងកាត់របបយោរយៅនេះ»។

**ភារុណា ភាគុណា** ៖ «នៅព្រឹកនេះ ខ្ញុំបានទស្សនាពិព័រណ៌រូបថតក្នុងមជ្ឈមណ្ឌលឯកសារកោះថ្ម ធ្វើឱ្យខ្ញុំមានអារម្មណ៍អាណិតប្រជាជនរងគ្រោះជាខ្លាំង។ រូបថតទាំងនោះបានបង្ហាញឱ្យក្មេងជំនាន់ក្រោយ និងខ្ញុំដឹងរឿងរ៉ាវប្រវត្តិសាស្ត្រជាច្រើន។ នៅក្នុងរបបខ្មែរក្រហម យាយតារបស់ខ្ញុំបានជួបការលំបាកវេទនាយ៉ាងខ្លាំង។ ខ្មែរក្រហមធ្វើបាប និងបង្ខំគាត់ឱ្យការងារគ្មានពេលឈប់សម្រាក និងបង្អត់បាយទឹក។ ចំណែកកុមារតូចៗ មិនបានរៀនសូត្រជ្រៅជ្រះឡើយ»។

**រតនា ឆានីកា** ៖ «ខ្ញុំសប្បាយរីករាយជាខ្លាំងដែលបានចូលមកទស្សនាផ្ទាំងរូបថតបង្ហាញពីសកម្មភាពប្រជាជនធ្វើការនៅក្នុងរបបខ្មែរក្រហម។ ខ្ញុំទទួលបានចំណេះដឹងថ្មីទាក់ទងតំបន់កោះថ្មដែលជាទីតាំងចំណុចចាប់ផ្ដើមនៃការរំដោះប្រទេសពីរបបប្រល័យពូជសាសន៍ ប៉ុល ពត»។

**ជា ជាទីត** ៖ «ខ្ញុំសប្បាយរីករាយ ដែលមានឱកាសទស្សនាពិព័រណ៌នៅក្នុងមជ្ឈមណ្ឌលឯកសារកោះថ្ម ដែលបង្ហាញពីសកម្មភាពប្រជាជនធ្វើការងារ និងដែនទីរណ្ដៅសាកសពដែលខ្មែរក្រហមបានសម្លាប់ប្រជាជន»។















# ការិយាល័យព័ត៌មានសាធារណៈ

«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូន សិស្ស និស្សិត អ្នកសិក្សាស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍អំពីការវិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសស្នាមទឹកដែលមានចំនួនជិតមួយលានទំព័រ។ ប្រភេទឯកសារទីពីរ គឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចស្រាវជ្រាវឯកសារទាំងនេះបាន។ ឯកសារខ្លះទៀតរួមមាន៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្ធនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ ១១ ផ្លូវលេខ ២៥៦ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។ ការិយាល័យរបស់យើងបើកជូនសាធារណជនចាប់ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង ៨÷០០ ដល់ម៉ោង ១២÷០០ និងពេលរសៀលពីម៉ោង ២÷០០ ដល់ ម៉ោង ៥÷០០។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង រស់ សំពៅ អ្នកសម្របសម្រួល តាមរយៈទូរសព្ទលេខ៖ ០១២ ៨៨២ ៥០៥ ឬ

អ៊ីម៉ែល ៖ truthsampeou.r@dccam.org

សូមអរគុណ!














# លោក ហែម បូរ៉ាវុធ ស្វែងរកសាច់ញាតិ ដែលបានបាត់ខ្លួនក្នុងរបបខ្មែរក្រហម

ផេង ពង្សរ៉ាស៊ី



រូបរាប់ពីស្តាំ៖ លោក ហែម បូរ៉ាវុធ ប្រពន្ធ និងកូនៗ បានអញ្ជើញមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជា សាខា ខេត្តតាកែវ ដើម្បីស្រាវជ្រាវរកសមាជិកគ្រួសារដែលបាត់ខ្លួនក្នុងរបបខ្មែរក្រហម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២៦ លោក ហែម បូរ៉ាវុធ និងគ្រួសារ បានអញ្ជើញមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជា សាខាខេត្តតាកែវ ដើម្បីស្វែងរកសមាជិកគ្រួសារដែលបានបែកគ្នាតាំងពីរបបខ្មែរក្រហមគ្រប់គ្រងប្រទេស។ នេះជាលើកទីពីរហើយដែលលោក ហែម បូរ៉ាវុធ បានធ្វើដំណើរពីប្រទេសបារាំងមកកាន់កម្ពុជា ដើម្បីបន្តបេសកកម្មស្រាវជ្រាវស្វែងរកសាច់ញាតិដែលបានបាត់ខ្លួន។

បុគ្គលិកប្រចាំការនៅមជ្ឈមណ្ឌលឯកសារខេត្តតាកែវ បានផ្តល់កិច្ចសហការយ៉ាងយកចិត្តទុកដាក់ ដោយបានពិភាក្សាជុំវិញព័ត៌មាននៃការបាត់ខ្លួន ដើម្បីជួយស្រាវជ្រាវតាមប្រព័ន្ធអ៊ីនធឺណិតលើគេហទំព័រ databases.dccam.org/paper-documents ព្រមទាំងបានផ្តល់បញ្ជីឈ្មោះឯកសារដែលមានតម្កល់នៅក្នុងការិយាល័យ ជូនលោក និងក្រុមគ្រួសារដើម្បីពិនិត្យ និងស្វែងរកឈ្មោះសមាជិកគ្រួសាររបស់លោក។

ជាមួយគ្នានេះ លោក ហែម បូរ៉ាវុធ និងគ្រួសារ បានស្នើសុំឱ្យមជ្ឈមណ្ឌលឯកសារកម្ពុជាជួយផ្សព្វផ្សាយដំណឹងនេះដល់សាធារណជន ដោយសង្ឃឹមថា នឹងបានទទួលព័ត៌មានបន្ថែមពីសមាជិកគ្រួសារ តាមរយៈបងប្អូនប្រជាពលរដ្ឋដែលធ្លាប់ស្គាល់ ឬដឹងពីស្ថានភាពគ្រួសាររបស់លោកនាអតីតកាល។ សមាជិកគ្រួសារចំនួន ៨ នាក់ ដែលបានបាត់ខ្លួន រួមមាន៖ ហែម បូរ (ឪពុកបង្កើត), កោះ ដាន់ណា (ម្តាយបង្កើត), ហែម ចាន់បូរី (បងស្រី), ហែម សុខបូរ៉ា (បងប្រុស), ហែម ប៊ុនណារី (ប្អូនស្រី), ហែម បុប្ផាគន្ធ (ប្អូនស្រី), ហែម បុប្ផារដ្ឋ (ប្អូនស្រី) និង ហែម បូរិទ្ធី (ប្អូនប្រុស)។

ដោយសារសមាជិកគ្រួសារទាំងអស់បានបាត់ខ្លួនក្នុងរបបខ្មែរក្រហម ហើយពុំដែលមានសាច់ញាតិណាម្នាក់បានជួបលោក ហែម បូរ៉ាវុធវិញ ទើបព័ត៌មានលម្អិតអំពីប្រវត្តិគ្រួសារក្នុងរបបខ្មែរក្រហមមិនបានដឹងច្បាស់លាស់។ យ៉ាងណាមិញ លោក ហែម បូរ៉ាវុធ ទទួលបានព័ត៌មានតែមួយគត់ពីអ្នកស្គាល់គ្នាម្នាក់ដែលបានប្រាប់ថា គ្រួសាររបស់លោកត្រូវបានខ្មែរក្រហមជម្លៀសចេញពីទីក្រុងភ្នំពេញជាមួយប្រជាជនជាច្រើនទៀតឆ្ពោះទៅកាន់ខេត្តតាកែវ។ លោកបានបញ្ជាក់តាមសម្តីអ្នកស្គាល់គ្នានោះថា៖ «បន្ទាប់ពីខ្មែរក្រហមចូលកាន់កាប់ទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ អង្គការបានជម្លៀសក្រុមគ្រួសាររបស់ខ្ញុំទាំង៨ នាក់ឱ្យទៅរស់នៅម្តុំដើមចាប ក្នុងខេត្តតាកែវ»។ គួរបញ្ជាក់ថា «ដើមចាប» ជាឈ្មោះវត្ត

មួយកន្លែងស្ថិតក្នុងឃុំរនាម ស្រុកទ្រាំង ខេត្តតាកែវ។ កាលពីសម័យខ្មែរក្រហម វត្តនេះត្រូវបានប្រើប្រាស់ជាទីកន្លែងឃុំឃាំង សួរចម្លើយ និងសម្លាប់មនុស្ស ដោយជនរងគ្រោះភាគច្រើនគឺជា «ប្រជាជន១៧ មេសា» ដែលត្រូវខ្មែរក្រហមជម្លៀសចេញពីភ្នំពេញ។

លោក ហែម ប៉ូរ៉ាវុធ មិនបានស្ថិតនៅក្នុងព្រឹត្តិការណ៍ជម្លៀសដោយបង្ខំក្នុងឆ្នាំ១៩៧៥ ទេ ព្រោះលោកត្រូវបានឪពុកបញ្ជូនឱ្យទៅសិក្សានៅប្រទេសបារាំងតាំងពីវ័យជំទង់ ក្នុងសម័យសង្គមរាស្ត្រនិយម។ ដោយសារកម្ពុជាបានធ្លាក់ចូលក្នុងភ្លើងសង្គ្រាមស៊ីវិលរ៉ាំរ៉ៃ លោកមិនអាចវិលត្រឡប់មកកាន់ប្រទេសវិញ ហើយបានបន្តរស់នៅប្រទេសបារាំងរហូតមកដល់បច្ចុប្បន្ន។

លោក ហែម បូរ ដែលត្រូវជាឪពុកលោក ប៉ូរ៉ាវុធ គឺជាឥស្សរជនជាន់ខ្ពស់ និងជាអ្នកជំនាញផ្នែកភស្តុភារកម្មដ៏លេចធ្លោមួយរូប ដែលបានដឹកនាំស្ថាប័នរថភ្លើងជាតិឆ្លងកាត់របបនយោបាយធំៗចំនួនពីរ គឺសម័យសង្គមរាស្ត្រនិយម និងសម័យសាធារណរដ្ឋខ្មែរ។ ក្នុងសម័យសង្គមរាស្ត្រនិយម ក្រោមព្រះរាជតម្រិះដឹកនាំរបស់សម្តេចព្រះ នរោត្តម សីហនុ ក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធជាតិ លោក ហែម បូរ ត្រូវបានតែងតាំងជាអគ្គនាយកនៃក្រុមហ៊ុនរថភ្លើងរដ្ឋកម្ពុជា។ ស្នាដៃដ៏ធំបំផុតរបស់លោកគឺការដឹកនាំបច្ចេកទេស និងគ្រប់គ្រងការដ្ឋានផ្ទាល់ក្នុងការស្ថាបនាខ្សែផ្លូវរថភ្លើងទី២ តភ្ជាប់ពីរាជធានីភ្នំពេញទៅកាន់ក្រុងព្រះសីហនុ ប្រវែង ២៧០គីឡូម៉ែត្រ ដោយឆ្លងកាត់ខេត្តតាកែវ កំពត និងកែប រហូតបានសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនៅខែធ្នូ ឆ្នាំ១៩៦៩។ ក្នុងបេសកកម្មនេះ លោក ហែម បូរ បានចុះបំពេញភារកិច្ច និងសហការយ៉ាងជិតដិតជាមួយអាជ្ញាធរខេត្តតាកែវ ដោយសារស្ថានីយខេត្តតាកែវជាចំណុចឈប់ចតយុទ្ធសាស្ត្រដំបូងគេបន្ទាប់ពីភ្នំពេញ។ លោក ហែម ប៉ូរ៉ាវុធ បានបញ្ជាក់ថា ថ្វីត្បិតតែឪពុកគាត់មានស្រុកកំណើតនៅទីក្រុងភ្នំពេញពិតមែន ប៉ុន្តែគាត់បានមកស្នាក់នៅ និងធ្វើការនៅក្នុងខេត្តតាកែវអស់រយៈពេលយ៉ាងយូរ។

នៅក្នុងសម័យសាធារណរដ្ឋខ្មែរ (ក្រោយរដ្ឋប្រហារឆ្នាំ១៩៧០) លោក ហែម បូរ មិនបានចាកចេញពីប្រទេសឡើយ ដោយលោកនៅតែបន្តកាន់តំណែងជាអគ្គនាយកក្រុមហ៊ុនរថភ្លើងជាតិដដែល។ ក្នុងបរិបទសង្គ្រាមស៊ីវិលរ៉ាំរ៉ៃនៅកម្ពុជា បេសកកម្មរបស់លោកបានប្រែប្រួលពី «ការកសាង» មកជា «ការការពារ និងជួសជុល» ផ្លូវរថភ្លើងវិញ។ នៅពេលផ្លូវជាតិលេខ៤ ត្រូវកាត់ផ្តាច់ ខ្សែផ្លូវដែកទិសខាងត្បូងបានក្លាយជាផ្លូវដង្ហើមសេដ្ឋកិច្ចតែមួយគត់។ រាល់ពេលមានការដាក់មីនបំផ្លាញផ្លូវដែក និងស្ពានពីកងទ័ពខ្មែរក្រហម លោក ហែម បូរ តែងតែដឹកនាំក្រុមវិស្វករចុះជួសជុលភ្លាមៗ ទាំងគ្រោះថ្នាក់ ដើម្បីរក្សាចរន្តដឹកជញ្ជូន។ លោកបានសហការជាមួយកងទ័ពជាតិក្នុងការបំពាក់កាំភ្លើងយន្តលើក្បាល និងទូររថភ្លើង ដើម្បីការពារការវាយឆ្មក់។ លោក ហែម បូរ បានបំពេញភារកិច្ចជាអ្នកបច្ចេកទេសជាន់ខ្ពស់ បម្រើវិស័យផ្លូវដែកកម្ពុជាដោយស្មោះត្រង់ រហូតដល់ថ្ងៃដួលរលំនៃរបបសាធារណរដ្ឋខ្មែរ នៅខែមេសា ឆ្នាំ១៩៧៥។




លោក ហែម ប៉ូរ៉ាវុធ និងក្រុមគ្រួសារបានអញ្ជើញមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជា សាខា ខេត្តតាកែវ ដើម្បីស្រាវជ្រាវរកសមាជិកគ្រួសារដែលបាត់ខ្លួនក្នុងរបបខ្មែរក្រហម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ជាតិនេះ ខ្ញុំបិះតែនឹងស្លាប់ចំនួន១៤លើក (ត)

ស្មៀវ សុផុន



ស្មៀវ សុផុន បួសជាព្រះសង្ឃនៅវត្តល្វាអំ ឡុងឆ្នាំ១៩៧០ និងឆ្នាំ១៩៧១។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

មុខម្នាងខ្មៅ និងម្នាងទៀតពណ៌សរបស់គាត់ឱ្យខ្ញុំលាក់ទុកជាមួយនា ឡិកាដៃរបស់ខ្ញុំម៉ាក RADO.999 និងខ្សែកមាសមួយខ្សែទៀត នៅក្រោមបន្ទះស្បែករឹងក្នុងបាតកាបូបស្ពាយ។ នៅពេលយើងដើរចេញមក គឺតែងតែមានយោធាខ្មែរក្រហមឈរចាំចន្លុះផ្លូវ និងបង្គាប់ឱ្យដើរទៅមុខៗ យើងដើរចូលមកដល់វិថីម៉ៅសេទុង គឺពុំមែនបត់ស្តាំទៅស្ទឹងមានជ័យដូចពេលព្រឹកឡើយ គឺយោធាខ្មែរក្រហមឱ្យបត់ទៅខាងឆ្វេងដៃ ឆ្ពោះទៅកាន់មហាវិថីព្រះមុនីវង្ស។ លុះមកដល់ផ្លូវធំ ខ្ញុំជួបប្រជាជនជម្លៀសយ៉ាងច្រើនហាក់ដូចជាហែកឋិន ឆ្ពោះទៅកាន់ក្បាលថ្នល់ច្បារអំពៅ និងផ្លូវជាតិលេខ១ (ភ្នំពេញ- ស្វាយរៀង)។

នៅថ្ងៃនោះ នៅវេលាម៉ោង១២យប់ ទើបខ្ញុំបានដេក។ នៅយប់នោះ ខ្មែរក្រហមបានដុតផ្ទះប្រជាជននៅច្បារអំពៅ ដើម្បីបំភ្លឺជំនួសឱ្យភ្លើងអគ្គិសនី អស់ជាច្រើនខ្នង ដោយឆេះអស់ផ្ទះមួយ ខ្មែរក្រហមដុតផ្ទះមួយទៀតៗ ខ្ញុំប្រហែលជាខុសពីប្រជាជនជម្លៀសផ្សេងទៀត ព្រោះត្រូវខ្មែរក្រហមជម្លៀសពីរលើកក្នុងថ្ងៃតែមួយ គឺពេលព្រឹកខ្មែរក្រហមបញ្ជាឱ្យបត់ទៅខាងស្តាំដៃទៅស្ទឹងមានជ័យ លុះដល់ល្ងាចឡើងខ្មែរក្រហមឱ្យបត់ខាងឆ្វេងដៃសំដៅទៅក្បាលថ្នល់។ ក្រោយឆ្នាំ១៩៧៩ គឺនៅថ្ងៃសុក្រទី៧ ខែកុម្ភៈ ឆ្នាំ២០១៨ ខ្ញុំបានចំណាយពេលមួយថ្ងៃធ្វើដំណើរពីភ្នំពេញទៅកាន់ខេត្តតាកែវ ដើម្បីស្វែងរកបងប្រុស ដែលជានិស្សិតពេទ្យទាំងបីរូប នៅស្រុកកំណើតរបស់ពួកគាត់ គឺក្នុងផ្សារស្វាយព្រៃ ស្ថិតនៅក្នុងភូមិលំចង់ ឃុំលំចង់ ស្រុកសំរោង ខេត្តតាកែវ ប៉ុន្តែពុំបានឃើញអ្នកទាំងបីឡើយ។ ម្យ៉ាងទៀត នៅក្រោយថ្ងៃដែលខ្ញុំចាកចេញពីក្រុងភ្នំពេញចំនួនបីថ្ងៃ គឺប្រជាជនមុំផ្ទះខ្ញុំស្នាក់នៅរៀនសូត្រនោះ ត្រូវបានខ្មែរក្រហមជម្លៀសមកកាន់ផ្លូវជាតិលេខ១ ហើយត្រូវខ្មែរក្រហមដឹកតាមកាណូតធំៗមានដំបូលពីរជាន់ឆ្ពោះទៅកាន់ខេត្តពោធិ៍សាត់ ដែលនៅទីនោះ ប្រជាជនថ្មីស្លាប់ច្រើនណាស់។ ខ្ញុំគិតថាអ្នកទាំងបីប្រហែលជាបាត់បង់ជីវិតនៅខេត្តពោធិ៍សាត់។ ខ្ញុំពិតជាមានសំណាងបានរស់រានមានជីវិត ជាលើកទី៦ បន្តទៀត ព្រោះខ្ញុំបានចាកចេញពីពួកគាត់។

### លើកទី៧ ត្រឡប់ចូលភ្នំពេញដើម្បីរុករកស្បៀង (ថ្ងៃទី២២ ខែមេសា ឆ្នាំ១៩៧៥)

អង្គការកុហកប្រជាជននៅភ្នំពេញថា ឱ្យចាកចេញពីផ្ទះរយៈពេលបីថ្ងៃតែប៉ុណ្ណោះ។ ពេលខ្ញុំដើរមកដល់ជ្រោយអំពិល ក្នុងសង្កាត់ព្រែកឯង អង្គការឃាត់ខ្ញុំឱ្យនៅទីរត្រង់នេះអស់ជាច្រើនថ្ងៃ។ នៅទីនោះ មានប្រជាជនរាប់សែននាក់បានដេកត្រៀបត្រានៅក្នុងចម្ការល្ហុត ហើយប្រជាជនភាគច្រើនខ្វះស្បៀងអាហារហូបចុក។ ខ្ញុំបានជួបអ្នកមកពីភ្នំពេញចំនួនបីនាក់ ដែលរស់នៅជិតខ្ញុំពេលនៅភ្នំពេញ និងបានបបួលគ្នាចូលទៅរកស្បៀងក្នុងក្រុងភ្នំពេញ ព្រោះយើងឮដំណឹងខ្សឹបខ្សៀវគ្នាថា មានអ្នកលួចចូលក្រុងភ្នំពេញស្ងាត់ៗ និងរកបានអង្ករយកមកវិញ។ ពេលព្រឹកព្រលឹម ថ្ងៃអង្គារ ទី២២ ខែមេសា ឆ្នាំ១៩៧៥ យើងទាំងបួននាក់ គឺ ១) បង វ៉េង គឺជាគ្រូភ្លេងផ្នែកសម័យកាន់ហ្គីតាសូឡូ ២) ឈ្មោះ ជា គឺជាទាហានស្រោចស្រង់ជាតិ (កោរសក់ក្បាល)។ ទី៣) ឈ្មោះ ឌី គឺជាទាហានស្រោចស្រង់ជាតិ (ជា និង ឌីគឺជាកូនកាត់ដែលមានម្តាយជាជនជាតិវៀតណាម និងត្រូវជាបងប្អូនបង្កើត) និងទី៤ គឺខ្ញុំ។ យើងត្រូវធ្វើដំណើរលួចលាក់ពីភ្នែកយោធាខ្មែរក្រហម ដូច្នេះយើងត្រូវដើរកាត់តាមគុម្ពោធព្រៃដោយពុំមានអ្នកនាំផ្លូវឡើយ។ យើងបានយកដងទន្ទេមេកន្តធ្វើជាត្រីវិស័យដើម្បីកុំឱ្យវង្វេងភូមិសាស្ត្រ។ យើងដើរលើផ្លូវលំប្រមាណជា១០គីឡូម៉ែត្រ ទើបបានមកដល់កំពង់ទូកមួយដែលមានខ្ទមចាំចម្ការ និងមានមនុស្សប្រុសស្រី៥ទៅ៦នាក់អង្គុយនៅទីនោះ។ តាមពិតអ្នកអង្គុយទាំងនោះ គឺមានបំណងឆ្លងទៅត្រើយម្ខាង ដែលយើងសម្លឹងមើលពីចម្ងាយ គឺឃើញ

(តទៅលេខក្រោយ)

រូបក្របមុខ៖

ប៊ូ ម៉េង កំពុងគូរគំនូរនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងឆ្នាំ២០០៨។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

រូបក្របក្រោយ ៖

ប៊ូ ម៉េង (រូបខាងឆ្វេង) កំពុងគូរគំនូរ និងលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងឆ្នាំ២០០៨។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)




**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**

ផ្ទះលេខ១១ ផ្លូវ២៥៦ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ៖ (៨៥៥) ៧៨ ៦៩៨ ៣៣៣

DC-Cam/PIR: #11 ◆ Street 256 ◆ Sangkat Chaktomuk ◆ Khan Daun Penh ◆ Phnom Penh ◆ Cambodia 1110

Tel: (855) 23 211 875 ◆ dccam@online.com.kh ◆ www.dccam.org

A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Issue 320, August 2026

Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 375 P.M. PRA. KA, 30 October 2018.